ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការចូលរួមរបស់គ្រូបង្រៀនស្ម័គ្រចិត្តជាមួយគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា
- ទំនាក់ទំនងប្រចាំថ្ងៃរវាងប្រជាជនកម្ពុជា និងប្រជាជនវៀតណាម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២២៣ ខែកក្កដា ឆ្នាំ២០១៨

# ស្វែងរកការពិត

លេខ២២៣ ខែកក្កដា ឆ្នាំ២០១៨

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ

◆ ការចូលរួមរបស់គ្រូបង្រៀនស្ម័គ្រចិត្តជាមួយគម្រោងអប់រំ ...................... ១

### ផ្នែកឯកសារ

◆ លោកទស្សនៈបដិវត្តន៍ចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យ .................... ៣
◆ ពិព័រណ៍ដង្ហើមនាសហសម័យ រូបថតស្តីពីការបំពុលបរិស្ថាន.................. ៩

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ សង្គ្រាមអាចធ្វើឲ្យមនុស្សភ្លេចភាសា ............................................ ១២
◆ តំបន់អន្លង់វែងជាកន្លែងដែលមានសុវត្ថិភាពបំផុតសម្រាប់ខ្ញុំ.................. ១៧
◆ តំបន់ដាច់ស្រយាលដ៏រីករាយក្នុងជីវិតខ្ញុំ........................................ ២២
◆ ង៉ែត ខេង អតីតជានារីពេទ្យខ្មែរក្រហម.......................................២៥
◆ វេទិកាថ្នាក់រៀន ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ ..................២៧
◆ ឪពុកម្តាយរបស់ សន ត្រូវបានសម្លាប់ដោយសារមិនពេញចិត្ត ............. ៣១

### ផ្នែកច្បាប់

◆ សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ...........៣៥
◆ ឯកសារសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ .................. ៤៤

### វេទិកាពិភាក្សាសាធារណៈ

◆ ទំនាក់ទំនងប្រចាំថ្ងៃរវាងប្រជាជនកម្ពុជា និងប្រជាជនវៀតណាម ........... ៤៩

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ........................៥២
◆ អ៊ីង សុភ័ក្រ ៖ ក្រឡាបញ្ជី............................................................ ៥៦



និស្សិតច្បាប់ចូលរួមដំណើរទស្សនកិច្ចតំបន់អន្លង់វែង
កំពុងជម្រះស្មៅដើម្បីដាំកូនឈើ

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៧៩១ពម៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ៖** សោម ប៊ុនថន, អ៊ុន សុដាវី, ដារ៉ារដ្ឋ មេត្តា, ស៊ិន សុធីតា, អាលីសុន វែលខេស, វ៉ាន់ថាន់ ពៅដារ៉ា, ឡូរ៉ា សាន, រស់ ប៊ុណ្ណារិទ្ធិ, ផាន់ សុខុម **អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ចុនា, អ៊ុន សុដាវី, ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ៖** ផាត បូរ៉ា, អ៊ុន សុដាវី **និពន្ធនាយកទូទៅ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក៖** សោម ប៊ុនថន **ក្រាហ្វិកកំព្យូទ័រ៖** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វើង **Email:** dccam@online.com.kh, **Homepage:** www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការចូលរួមរបស់គ្រូបង្រៀនស្ម័គ្រចិត្តជាមួយគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការងារជាមួយក្រសួងអប់រំយុវជន និងកីឡា ក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមដល់គ្រូបង្រៀន សិស្សានុសិស្ស និស្សិត គរុនិស្សិត នៅទាំងប្រទេស ដោយចាប់ផ្តើមពីការសរសេរ និងបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»។ សៀវភៅទាំងនេះត្រូវបានចែកជូនដល់ សិស្សានុសិស្ស គ្រូបង្រៀន និងសាលាចំនួន១,៧០០។ ដោយឡែកការចែកជូនសៀវភៅសម្រាប់ណែនាំគ្រូបង្រៀន បានធ្វើឡើងក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនស្តីពី «ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» ដើម្បីធ្វើជាឯកសារយោងសម្រាប់មេរៀនប្រវត្តិសាស្ត្រ និងប្រើប្រាស់វិធីសាស្ត្រទំនើបក្នុងការបង្រៀនសិស្ស ដែលបានអនុវត្តដំបូងនៅឆ្នាំ២០០៩ ដោយមានគ្រូបង្គោលថ្នាក់ជាតិប្រមាណ៣៩នាក់ចូលរួម។

យោងតាមអនុស្សារណៈនៃការយោគយល់រវាងក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ បានអនុវត្តគម្រោងទី២ និងទី៣របស់ខ្លួន តាមរយៈការបង្កើតគម្រោងថ្មីៗ គឺវេទិកាថ្នាក់រៀនសម្រាប់សិស្សានុសិស្សថ្នាក់វិទ្យាល័យ ក្នុងរាជធានីភ្នំពេញ និងបានដំណើរចាប់ពីឆ្នាំ២០១៦ បន្តមកដល់បច្ចុប្បន្ន។ គម្រោងនេះបង្កើតឡើងក្នុងគោលបំណងលើកទឹកចិត្តសិស្សឲ្យស្វែងយល់ពីសារសំខាន់ក្នុងការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមនិងវិភាគទៅលើព្រឹត្តិការណ៍នានា ដែលបានកើតឡើងក្នុងអំឡុង



លោក ផេង ពង្សរ៉ាស៊ី នាយកគម្រោងអប់រំអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ និងសរសេរប្រវត្តិភូមិដល់លោកគ្រូអ្នកគ្រូបង្គោលថ្នាក់ជាតិ និងមូលដ្ឋាន ចំនួន២០រូបនៅសាលសិល្បៈសហសម័យវិទ្យាស្ថានស៊ីករីត

ពេលនៃការកាន់កាប់របស់ខ្មែរក្រហម ពីឆ្នាំ១៩៧៥-១៩៧៩។

នៅដំណាក់កាលបន្ទាប់របស់គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា គឺប្រវត្តិសាស្ត្រភូមិ ដែលជាការពង្រីកចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅកាន់មូលដ្ឋានដែលជាកន្លែងកើតហេតុផ្ទាល់ និងបង្កឲ្យមានអំពើប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហម ហើយដែលមានចែងយ៉ាងច្បាស់នៅក្នុងអនុស្សរណៈនៃការយោគយល់រវាង ក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧។ គម្រោងនេះនឹងសរសេរ ចងក្រងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងមូលដ្ឋាន និងផ្សព្វផ្សាយដើម្បីឲ្យមនុស្សបានស្វែងយល់ និងចងចាំពីរឿងរ៉ាវអតីតកាលព្រមទាំងចែករំលែកដល់ក្មេងជំនាន់ក្រោយបន្តទៀត ក្នុងន័យដើម្បីថែរក្សាប្រវត្តិសាស្ត្ររបស់ខ្លួន។ ការងារទាំងនេះនឹងធ្វើឡើងដោយស្ម័គ្រចិត្ត ពីលោកគ្រូអ្នកគ្រូដែលទទួលបានការបណ្តុះបណ្តាលពីរបៀបបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមរួចហើយ តាមរយៈការប្រមូល ចងក្រង សរសេរ បោះពុម្ព និងផ្សព្វផ្សាយ ពីសំណេរដែលខ្លួនបានសរសេរទៅកាន់សិស្សានុសិស្សនៅតាមវិទ្យាល័យ និងអនុវិទ្យាល័យនៅទូទាំងប្រទេស។

ដើម្បីជួយដល់ដំណើរការគម្រោងខាងលើមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវការជ្រើសរើសគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន៣០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរពីប្រវត្តិសាស្ត្ររឿងរ៉ាវចេញពីភូមិឃុំកំណើត ឬភូមិឃុំដែលខ្លួនកំពុងរស់នៅ ដែលជាប់ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់លោកគ្រូអ្នកគ្រូនឹងត្រូវបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនលោកគ្រូអ្នកគ្រូវិញ ដើម្បីប្រើប្រាស់ជាសម្ភារៈឧបទេ្ទសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។

មជ្ឈមណ្ឌលឯកសារកម្ពុជា



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញពីប្រធានបទ និងផ្តល់យោបល់ដល់លោកគ្រូអ្នកគ្រូបង្គោលថ្នាក់ជាតិ និងមូលដ្ឋាន ក្នុងការសរសេរប្រវត្តិភូមិ

# លោកទស្សនៈបដិវត្តន៍ចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យ

## ដកស្រង់ចេញពីឯកសារ D២១៣៩៧

ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ប្រជាជននិងយុវជន-យុវនារីកម្ពុជាយើង ក្រោមការ ដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃកបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាយ៉ាងខ្លាំងក្លាសស្រាក់សស្រាំទាំងយប់ទាំងថ្ងៃជាបន្តទៀតៗ ដោយឡែកតែយុវជន-យុវនារីបដិវត្តន៍យើង ក៏បានបន្តធ្វើពលីកម្មកម្រិតខ្ពស់តទៀត ហើយប្តេជ្ញាចិត្តលះបង់អ្វីៗទាំងអស់ជាបន្តទៀត ដើម្បីសម្រេចទិសដៅបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាឲ្យបានជោគជ័យទាំងស្រុង និងដោយល្បឿនមហាលោតផ្លោះមហាអស្ចារ្យៗ ជាពិសេសយុវជន-យុវនារីបដិវត្តន៍យើងក្រោមការដឹកនាំ និងការអប់រំថែបំប៉នជាប់ជានិច្ចរបស់ បក្សកុម្មុយនីស្តយើង បានបន្តប្រយុទ្ធធ្វើបដិវត្តន៍ខាងសតិអារម្មណ៍យ៉ាងខ្លាំងក្លាជ្រាលជ្រៅ ប្រយុទ្ធវាយកម្ទេចគោលជំហរសតិអារម្មណ៍កម្មសិទ្ធិឯកជនគ្រប់បែបយ៉ាង តាំងពីកម្មសិទ្ធិខាងសម្ភារកម្មសិទ្ធិខាងមនោសញ្ចេតនា រហូតដល់កម្មសិទ្ធិខាងលោកទស្សនៈ ជីវទស្សនៈ សីលធម៌ និងទម្លាប់ចាស់ៗ

យុវជន-យុវនារីបដិវត្តន៍យើងយល់ច្បាស់ថា បើគ្រាន់តែមានសេចក្តីប្តេជ្ញាចិត្តខ្ពស់ ហ៊ានធ្វើពលីកម្មគ្រប់បែបយ៉ាង តែបើនៅមានលោកទស្សនៈមិនត្រឹមត្រូវនោះក៏មិនអាចសម្រេចទិសដៅបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាបានជោគជ័យទាំងស្រុង និងឆាប់រហ័សដែរៗ ដូច្នេះហើយយុវជន-យុវនារីបដិវត្តន៍យើងក្នុងការកសាងខ្លួនដើម្បីវាយសម្រុកអនុវត្តភារកិច្ចបដិវត្តន៍សង្គមនិយមនិងការកសាងសង្គមនិយមឲ្យបានខ្លាំងក្លាត្រឹមត្រូវ និងមានប្រសិទ្ធភាពបំផុតបានយកចិត្តទុកដាក់វាយកម្ចាត់នូវលោកទស្សនៈចាស់ដែលជាលោកទស្សនៈចក្រពត្តិ នាយទុន សក្តិភូមិ និងវណ្ណៈជិះជាន់ផ្សេងទៀតឲ្យជ្រះស្រឡះអស់រលីងពីក្នុងខ្លួន ពីក្នុងជួរយុវជន-យុវនារីបដិវត្តន៍ ក៏ដូចពីក្នុងជួរបដិវត្តន៍ទាំងមូល និងពីក្នុងសង្គមជាតិយើងទាំងមូលដែរៗ ព្រមជាមួយនេះ យុវជន-យុវនារីបដិវត្តន៍យើង ក៏បានប្រយុទ្ធកសាងបំពាក់បំប៉នឲ្យខ្លួននូវលោកទស្សនៈបដិវត្តន៍ ដែលជាលោកទស្សនៈត្រឹមត្រូវវិទ្យាសាស្ត្រ នៃវណ្ណៈអធនឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លាឡើងជាលំដាប់ៗ

ក្នុងបណ្តាលោកទស្សនៈទាំងអស់នេះ យុវជន-យុវនារីបដិវត្តន៍យើងចាំបាច់ត្រូវមានលោកទស្សនៈបដិវត្តន៍ឲ្យត្រឹមត្រូវចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យនេះនៅប្រប្លូកប្រឡប់គ្នានៅឡើយ រវាងលោកទស្សនៈវណ្ណៈនាយទុន និងលោកទស្សនៈបដិវត្តន៍នៃវណ្ណៈអធនរបស់បក្សៗ មិត្តយុវជន-យុវនារីយើងខ្លះនៅប្រប្លូកប្រឡប់រវាងសិទ្ធិសេរីភាពប្រជាធិបតេយ្យនាយទុន ដែលជាសិទ្ធិសេរីភាពប្រជាធិបតេយ្យក្លែងក្លាយជាមួយនឹងសេរីភាពប្រជាធិបតេយ្យពិតប្រាកដនៃវណ្ណៈអធនរបស់បក្សនៅឡើយៗ

### ១.យើងពិនិត្យមើលសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់វណ្ណៈនាយទុន តើយ៉ាងណា?

របបនាយទុនមានចែងនៅក្នុងច្បាប់ក្នុងរដ្ឋធម្មនុញ្ញរបស់វា ថាបើកសិទ្ធិសេរីភាពឲ្យប្រជាជនក្នុងការនិយាយស្តី មានមតិសរសេរ និងដើរហើរតាមចិត្តៗលៗ តែបើយើងពិនិត្យឲ្យស៊ីជម្រៅទៅ យើងឃើញថាសិទ្ធិសេរីភាពរបស់វានេះ គឺមានត្រឹមតែលើក្រដាសតែក្នុងការអនុវត្តន៍ជាក់ស្តែង គឺគ្មានទាល់តែសោះៗ

ឧទាហរណ៍៖ បើជនណាដែលជាដៃជើងរបស់វា សរសេរនិយាយស្តី បញ្ចេញយោបល់សរសើររបបវា លើកតម្កើងឥទ្ធិពល

វណ្ណៈវា ឬបម្រើការឃោសនាអប់រំនៃរបបវា ពួកនោះមាន សិទ្ធិសេរីភាព និងធ្វើតាមចិត្តមែនៗ តែបើប្រជាជនណា ឬ មហាជនណាហ៊ាននិយាយស្តី ហ៊ានមានមតិ ឬហ៊ានសរសេរ ការពិតជាក់ស្តែងនៅក្នុងសង្គមនាយទុនដែលជិះជាន់សង្កត់ សង្កិន និងពុករលួយពាលាអាវាសែ ឬហ៊ាននិយាយសរសេរ មានមតិយោបល់ការពារផលប្រយោជន៍ប្រទេសជាតិ ការពារ ផលប្រយោជន៍ប្រជាជន មហាជន ពលករ ដែលផ្ទុយនឹងផល ប្រយោជន៍នៃការជិះជាន់ឆក់ប្លន់របស់ពួកវា នោះមុខជានឹង ត្រូវពួកវាយកច្បាប់ យករដ្ឋធម្មនុញ្ញរបស់វាដដែលនេះ មក បកស្រាយដើម្បីចោទប្រកាន់ ចាប់ចង ដាក់គុកច្រវាក់ ធ្វើ ទារុណកម្មលើរូបរាងកាយយ៉ាងព្រៃផ្សៃ រហូតដល់ប្រហារ ជីវិតយ៉ាងកំរោលហ្វាស៊ីសទៀតផង។

មើលចុះកាលពីក្នុងសង្គមចាស់ តើមានកាសែតណា មាន ទស្សនាវដ្តីណា មានសៀវភៅណា ដែលសរសេរពីវីរភាព ពី ស្នាដៃ ពីពលកម្ម ពីសមត្ថភាព ពីទេពកោសល្យច្នៃប្រឌិតៗលៗ របស់ប្រជាជនកម្មករ-កសិករ និងពលករយើងម្តងណា? តើ មានកវីនិពន្ធណាម្នាក់អាចសរសេរសរសើរ ឬបំផុសស្មារតី ស្នេហាជាតិមាតុភូមិឲ្យបានត្រឹមត្រូវពិតប្រាកដ? កាលនៅក្នុង សង្គមចាស់សៀវភៅច្រើនណាស់ កាសែតច្រើនមែន ទស្សនាវដ្តី ក៏សម្បូរណ៍បែបមែន តែបើរើសយកជាការគឺគ្មានបានមួយ ទេ ព្រោះក្រដាសទាំងនេះវាឃោសនាអប់រំ និងផ្សាយតែអំពើ អបាយមុខ និងអំពើពាលាអាវាសែភូតភរបោកប្រាស់ កេង ប្រវ័ញ្ចគ្រប់បែបយ៉ាង នៃរបបនឹងមនោគមន៍វិជ្ជានាយទុន ទាំងអស់។ នេះហើយជាន័យ ជាធាតុពិតក្លែងក្លាយបោក ប្រាស់នៃសិទ្ធិសេរីភាពរបស់វណ្ណៈនាយទុន។

ន័យបោកប្រាស់ក្លែងក្លាយមួយទៀតគឺ ពួកនាយទុនវា បើកសិទ្ធិសេរីភាពឲ្យនិយាយស្តីមានមតិ និងសរសេរតាមចិត្ត ប៉ុន្តែជាក់ស្តែង ពួកនាយទុនវាក្តាប់សេដ្ឋកិច្ចទាំងអស់ ក្តាប់ មធ្យោបាយផលិតកម្មទាំងអស់។ ដូច្នេះ ប្រជាជន កម្មករ កសិករ ពលករដែលមានតែបាតដៃទទេ ហើយត្រូវលក់កម្លាំង ពលកម្មស៊ីឈ្នួលពួកវា ធ្វើម្តេចនឹងហ៊ានមានមតិយោបល់ យ៉ាងម៉េចៗ! ព្រោះត្រូវរណបវាខាងសេដ្ឋកិច្ចទាំងស្រុងទៅ ហើយៗ ដូច្នេះសិទ្ធិសេរីភាពរបស់នាយទុន គ្រាន់តែជាសិទ្ធិ សេរីភាពបោកប្រាស់ក្លែងក្លាយប៉ុណ្ណោះ។

ន័យទី៣ នៃសិទ្ធិសេរីភាពក្លែងក្លាយរបស់នាយទុន គឺនៅ ក្នុងសង្គមនាយទុនពួកវាបើកឲ្យរកស៊ីដោយសេរី អ្នកណាចង់ រកស៊ីយ៉ាងម៉េចក៏រកទៅ។ តែការពិតជាក់ស្តែងបើរដ្ឋអំណាច នៅក្នុងកណ្តាប់ដៃពួកវាទាំងស្រុង ទុន និងមធ្យោបាយផលិត កម្មសព្វបែបយ៉ាងទាំងអស់ នៅក្នុងកណ្តាប់ដៃពួកវាអស់ទៅ ហើយ តើប្រជាជន កម្មករ កសិករ ពលករនានាដែលមាន ចំនួនច្រើនលើសលប់ដល់ទៅជាង៩០ភាគរយនោះ ធ្វើម្តេច នឹងអាចរកស៊ីប្រណាំងប្រជែងដោយសេរីជាមួយពួកវាបាន។ ដូច្នេះទីចុងបំផុត មានតែត្រូវវិនាសហិនហោចធ្លាក់ខ្លួនកាន់តែ



នួន ជា អតីតប្រធានសភាជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ ចុះពិនិត្យការដ្ឋ

ក្រទៅៗ រហូតដល់លក់កម្លាំងពលកម្មពួកវា ហើយរណបពួកវាទាំងស្រុងប៉ុណ្ណោះៗ រីឯពួកនាយទុនវិញ ដែលមានសិទ្ធិអំណាចក្នុងដៃទាំងស្រុង មានទុន និងមធ្យោបាយផលិតកម្មគ្រប់បែបយ៉ាងទាំងអស់នៅក្នុងដៃ វាគ្មានទៅចាំរកស៊ីប្រណាំងប្រជែង គឺប្រជាជន កម្មករ កសិករ ពលករយើងឡើយៗ ការពិតវាចាំតែដេករឹបជាន់ ឆក់ប្លន់ ជញ្ជក់ឈាមអន្ទៀមឆ្អឹងប្រជាជនក្រីក្រយើង ហើយចាប់បង្ខំប្រជាជនក្រីក្រយើង ឲ្យបម្រើផលប្រយោជន៍ពួកវាដោយសេរី តាមទំនើងចិត្តវាតែប៉ុណ្ណោះៗ នេះហើយជាធាតុពិតក្លែងក្លាយបោកប្រាស់នៃសិទ្ធិសេរីភាពរបស់វណ្ណៈនាយទុន ដែលវាបើកឲ្យប្រជាជន កម្មករ កសិករ និងពលករផ្សេងៗ។ គឺសិទ្ធិសេរីភាពក្នុងការអត់ឃ្លានដាច់ពោះស្លាប់ សិទ្ធិសេរីភាពក្នុងការធ្វើខ្ញុំកញ្ជះគេៗលៗ



អំពីប្រជាធិបតេយ្យរបស់នាយទុនវិញ គឺវាបើកសិទ្ធិអំណាចឲ្យប្រជាជនទូទៅអាចបង្កើតគណៈបក្សច្រើន អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងធ្វើនេះធ្វើនោះ ហើយមានសិទ្ធិ អាចទៅបោះឆ្នោតជ្រើសរើសតំណាងរបស់យួនដោយសេរីៗ តើការពិតជាក់ស្តែងតើយ៉ាងណា?

ទី១) ព្រមជាមួយនឹងច្បាប់ បើកសិទ្ធិប្រជាធិបតេយ្យខាងលើនេះពួកវាធ្វើច្បាប់មួយដាក់លក្ខខណ្ឌសេដ្ឋកិច្ចហិរញ្ញវត្ថុ នយោបាយ និងសីលធម៌នាយទុនជាមុនហើយស្រេច ដើម្បីរាំងរា និងបំបិទសិទ្ធិសេរីភាពប្រជាធិបតេយ្យខាងលើនេះទៅវិញៗ

ឧទាហរណ៍៖ ក្នុងការឈរឈ្មោះជាបេក្ខជនឲ្យគេបោះឆ្នោតពួកវាតម្រូវឲ្យបង់ពន្ធជាលុយកាក់ ជាធនធានទ្រព្យសម្បត្តិផ្សេងៗយ៉ាងច្រើនសម្រាប់ធានាៗ ដូច្នេះ តើមានប្រជាជនកម្មករ កសិករ ពលករយើងណាម្នាក់អាចបំពេញលក្ខខណ្ឌផ្សេងៗទៀតជាច្រើនៗ ដូច្នេះសម្រេចសម្រួចទៅអ្នកដែលមានសិទ្ធិទៅឈរឈ្មោះឲ្យគេបោះឆ្នោត គឺមានតែពួកវា និងដៃជើងវាប៉ុណ្ណោះៗ

ឧទាហរណ៍មួយទៀត៖ ក្នុងការបោះឆ្នោតទៀតសោត ពួកវាជាអ្នកកាន់កាប់ច្បាប់ទម្លាប់ ជាអ្នកចាត់ចែងរៀបចំការបោះឆ្នោត ជាអ្នកកាន់កាប់ហិបឆ្នោត ជាអ្នករាប់សន្លឹកឆ្នោត ជាអ្នកប្រកាសលទ្ធផលនៃការបោះឆ្នោតៗលៗ ដូច្នេះ វាចាត់ចែងតាមចិត្ត វាលួចសន្លឹកឆ្នោតតាមចិត្ត វាប្រកាសលទ្ធផលទៅតាមតែផលប្រយោជន៍ នៃវណ្ណៈជិះជាន់របស់ពួកវាតែប៉ុណ្ណោះៗ

ដូច្នោះ តើសិទ្ធិសេរីភាពប្រជាធិបតេយ្យដែលវណ្ណៈនាយទុនវាប្រកាសឲ្យប្រជាជន កម្មករ កសិករ ពលករយើងនៅឯណា?

- គឺគ្មានទាល់តែសោះ គឺគ្រាន់តែជាការបោកប្រាស់បន្លំភ្នែក បំភាន់មតិប្រជាជនមហាជនតែប៉ុណ្ណោះៗ នេះហើយជាធាតុពិត និងជាខ្លឹមសារពិតប្រាកដនៃសិទ្ធិសេរីភាពប្រជាធិប

គេយ្យនាយទុនៗ

២. តើខ្លឹមសារ និងធាតុពិតនៃសិទ្ធិសេរីភាពប្រជាធិបតេយ្យបដិវត្តន៍យ៉ាងម៉េច?

- បច្ចុប្បន្ននេះ រដ្ឋអំណាចបដិវត្តន៍យើងបើកសិទ្ធិសេរីភាពប្រជាធិបតេយ្យពេញទី ដូចជាប្រជាជន កម្មករ កសិករ ពលករក្នុងការបង្កបង្កើនផលចញ្ចឹមជីវិតនិងរួមចំណែកកសាងប្រទេស ការពារប្រទេសបានទាំងអស់គ្នាៗបច្ចុប្បន្ននេះ ប្រជាជនយើងមានមធ្យោបាយផលិតកម្មទាំងអស់គ្នា ដូច្នេះមានលទ្ធភាពបង្កបង្កើនផលខបត្តម្ភខ្លួន និងរួមចំណែកកសាងប្រទេសការពារប្រទេសបានទាំងអស់គ្នាៗ នៅក្នុងសង្គមកម្ពុជាថ្មីនេះគ្មានអ្នកណាស៊ីឈ្នួលអ្នកណាគ្មានអ្នកណាជំពាក់បំណុលអ្នកណាទៀតឡើយៗ ទាំងអស់គ្នាជាម្ចាស់ប្រទេស ម្ចាស់បដិវត្តន៍ និងម្ចាស់លើវាសនាអនាគតរបស់ខ្លួនស្មើៗគ្នា ដូចៗគ្នាៗ បច្ចុប្បន្ននេះ ប្រជាជន កម្មករ កសិករ សមូហភាពយើងទាំងអស់គ្នា កំពុងវាយសម្រុកបង្កបង្កើនផលកសាងប្រទេស ការពារប្រទេសដោយឯករាជ្យម្ចាស់ការ ដោយគំនិតផ្តើមច្នៃប្រឌិតរស់រវើក យ៉ាងសស្រាក់សស្រាំផុលផុស នៅគ្រប់ទីកន្លែងទូទាំងកម្ពុជាយើងៗ ប្រជាជនយើងអស់ព្រួយបារម្ភអស់ភ័យភិតពីរឿងគេទារបំណុល គេទារពន្ធដារអាករសព្វសារពើពីរឿង ម្ចាស់បំណុលមករឹបអូសយកដីធ្លី ភូមិករ ផ្ទះសម្បែង គោក្របី រទេះសាឡីៗលៗ ទៀតហើយៗ ដូច្នេះប្រជាជនយើងមានសិទ្ធិសេរីភាពប្រជាធិបតេយ្យ ក្នុងការ



កងយោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

មានហូបគ្រប់គ្រាន់ មានសម្លៀកបំពាក់ បិទបាំងកាយជិត មានជម្រករស់នៅគត់មត់ៗ ប្រជាជនយើងមានសិទ្ធិសេរីភាពក្នុងការរៀនសូត្រវប្បធម៌ នយោបាយ និងបច្ចេកទេសវិទ្យាសាស្ត្រផ្សេងៗដើម្បីរួមចំណែកការពារ និងកសាងប្រទេសឲ្យបម្រើនថ្កុំថ្កើងរុងរឿង និងខ្លាំងពូកែយ៉ាងឆាប់រហ័សៗ

ឧទាហរណ៍៖ កាលនៅក្នុងសង្គមចាស់ ពួកវណ្ណៈជិះជាន់ ជាចក្រពត្តិ សក្តិភូមិ នាយទុន ស៊ីដីកចាក់ច្រាស់ តែប្រជាជនក្រីក្រយើង រស់នៅគោកយ៉ាកអត់ឃ្លាន ដាច់ពោះស្លាប់ៗ ក្រោយរំដោះ ទោះបីយើងទើបចេញផុតពីសង្គ្រាមវិនាសកម្ម មានការខ្វះខាតសព្វគ្រប់បែបយ៉ាងណាក្តី រដ្ឋអំណាចបដិវត្តន៍យើងខំរត់ដោះស្រាយអស់លទ្ធភាពផ្តួចផ្តើមឲ្យប្រជាជនយើងមានហូបដូចៗគ្នា ទោះបីបាយក្តី បបរក្តី ឲ្យមានមធ្យោបាយ និងមានលទ្ធភាពបង្កបង្កើនផលបានទាំងអស់គ្នាៗ ហើយបានផលមកយើង ក៏ចេះបែងចែករំលែកចែកគ្នាហូបទាំងអស់គ្នា គ្មានអ្នកណាចាក់ច្រាសតែម្នាក់ឯង ហើយទុកឲ្យអ្នកដទៃទៀតដាច់ពោះស្លាប់នោះឡើយៗ

ឧទាហរណ៍៖ កាលពីសង្គមចាស់ ខ្មាំងមានបើកសាលាតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សាមែនពិត តែជាក់ស្តែងមានតែកូនចៅពួកវាទេដែលបានចូលរៀនសូត្រ ចំណែកឯប្រជាជនជាង៨០ភាគរយមិនចេះអក្សរៗ ឥឡូវពិតមែនតែយើងពុំទាន់បានបើកសាលាមធ្យមសិក្សា ឧត្តមសិក្សា ជាខ្សែសង្វាក់ដូចពួកវា តែប្រជាជនយើង កូនចៅប្រជាជនយើងទាំងអស់ ទាំងនៅទីក្រុង ទាំងនៅជនបទ ទាំងនៅព្រៃភ្នំចុងកាត់មាត់ញក សុទ្ធតែបានរៀនអក្សរ រៀននយោបាយ និងរៀនបច្ចេកទេសផ្សេងៗ ដើម្បីបម្រើភារកិច្ចការពារប្រទេស និងការកសាងប្រទេសឲ្យបានសក្តិសិទ្ធិបំផុតៗ

អំពីសិទ្ធិសេរីភាពប្រជាធិបតេយ្យ ក្នុងការបោះឆ្នោតកន្លងមក ក្នុងការជ្រើសរើសសមាជិកសភាតំណាងប្រជាជនក្តី ក្នុងការជ្រើសគណៈកម្មាធិការ សហករណ៍ភូមិ-ឃុំ-ស្រុក-ខេត្តក្តី ពិតមែនតែយើងគ្មានចាត់តាំងបោះឆ្នោតដូចក្នុងរបបនាយទុន ក៏ប៉ុន្តែយើងជ្រើសរើសតាមលក្ខណៈសម្បត្តិ និងលក្ខណៈវិនិច្ឆ័យដូចតទៅ៖

- មានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន បម្រើប្រជាជន កម្មករ កសិករ ពលករដោយអស់ពីចិត្តពីថ្លើម និងដោយស្មោះសរ សោមនស្សរីករាយជ្រះថ្លាបំផុតៗ
- សកម្មភាពប្រយុទ្ធក្នុងកិច្ចការការពារប្រទេស កសាងប្រទេសគ្រប់ពេលវេលា
- មានគោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍រឹងប៉ឹងត្រឹមត្រូវល្អដោយប្រៀបធៀបៗ
- មានមហាជនស្រឡាញ់ ជឿទុកចិត្ត កក់ក្តៅច្រើនកុះករៗលៗ

ដូច្នេះ លក្ខណៈវិនិច្ឆ័យទាំងប៉ុន្មានខាងលើនេះ វាជាតំណាងពិតប្រាកដឲ្យប្រជាជនរួចស្រេចទៅហើយៗ ម្យ៉ាងទៀត ក្នុងការស៊ើបពិនិត្យលក្ខណៈសម្បត្តិទាំងប៉ុន្មានខាងលើនេះ ក៏យើងបានធ្វើការស៊ើបអង្កេតនៅក្នុងប្រជាជនកម្មករ កសិករ ពលករ ស្ទង់មតិ ស្តាប់យោបល់ប្រជាជន កម្មករ កសិករ ពលករ ជាមុនស្រេចទៅហើយៗ ដូច្នេះ ការជ្រើសរើសរបៀបនេះ គឺពិតជាប្រជាធិបតេយ្យ១០០ភាគរយៗ ការជ្រើសរើសយ៉ាងនេះ គឺពិតជាប្រជាជនស្រឡាញ់ពេញចិត្តថ្លើម គឺពិតជាតំណាងផលប្រយោជន៍ប្រជាជនកម្មករកសិករ ពលករពិតជាបម្រើ និងការពារផលប្រយោជន៍ប្រជាជនកម្មករ កសិករ ពលករ យ៉ាងពិតប្រាកដណាស់ៗ

នេះហើយជាសិទ្ធិសេរីភាពប្រជាធិបតេយ្យពិតប្រាកដ ដែលរដ្ឋអំណាចបដិវត្តន៍យើងផ្តល់ជូន ប្រជាជន កម្មករ កសិករ និងពលករនានាទាំងអស់ៗ សិទ្ធិសេរីភាពប្រជាធិបតេយ្យនេះ យើងគិតគូរដោះស្រាយជីវភាពប្រជាជន កម្មករ កសិករ និងពលករនានាឲ្យចម្រើនធូរធាឡើងជានិច្ច រហូតដល់បានសម្បូរណ៍ សប្បាយ ថ្កុំថ្កើង រុងរឿង ទៀត នៅពេលខាងមុខៗ

ដូច្នេះ សិទ្ធិសេរីភាពប្រជាធិបតេយ្យមិនមែនសំខាន់នៅលើរូបភាពចាត់តាំងទេ តែសំខាន់គឺនៅលើខ្លឹមសារៗ តើខ្លឹមសារវាបម្រើវាការពារផលប្រយោជន៍វណ្ណៈជិះជាន់មួយក្តាប់

តូច នោះប្រជាជន កម្មករ កសិករ និងពលករនានាដែលមានចំនួនច្រើនលើសលប់រហូតដល់ជាង៩០ភាគរយនៅក្នុងសង្គមជាតិកម្ពុជា យើងទាំងមូលគ្មានសិទ្ធិសេរីភាពអីទេ ចង់អ្នកណាប្រកាសឃោសនាកក្រើកមេឃដីថា គេបើកសិទ្ធិសេរីភាពប្រជាធិបតេយ្យជូនប្រជាជនច្រើនយ៉ាងណាក៏ដោយៗ តែបើវាបម្រើ និងការពារផលប្រយោជន៍ប្រជាជនកម្មករ កសិករ ពលករដែលជាភាគច្រើនលើសលប់ដាច់ខាតនៅក្នុងសង្គមជាតិហើយ នោះបានសេចក្តីថាប្រជាជនយើងមានសិទ្ធិសេរីភាពពេញបរិបូរណ៍ៗ

ដូច្នេះ យុវជន-យុវនារីបដិវត្តន៍យើងត្រូវមានលោកទស្សនៈបដិវត្តន៍ត្រឹមត្រូវចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យពិតប្រាកដ និងប្រជាធិបតេយ្យក្លែងក្លាយបោកប្រាស់របស់វណ្ណៈនាយទុនៗ យើងត្រូវមានព្រំដែនបែងចែកឲ្យដាច់ស្រឡះរវាងសិទ្ធិសេរីភាពប្រជាធិបតេយ្យក្លែងក្លាយ របស់នាយទុន និងសិទ្ធិសេរីភាពប្រជាធិបតេយ្យពិតប្រាកដ នៃរដ្ឋអំណាចបដិវត្តន៍យើងដែលគិតគូរបម្រើ និងការពារផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ប្រទេសជាតិទាំងមូល របស់ប្រជាជន កម្មករ កសិករ និងពលករនានាគ្រប់ពេលវេលា និងគ្រប់កាលៈទេសៈលំបាកស្រួលទាំងអស់ៗ ដូច្នោះយុវជន-យុវនារីបដិវត្តន៍យើងកុំភាន់ច្រឡំរូបភាពចាត់តាំងក្លែងក្លាយ ទោះបីជាល្អ ស្រស់ពិរោះយ៉ាងណាក៏ដោយ ជាមួយនឹងខ្លឹមសារពិតប្រាកដនៃសិទ្ធិសេរីភាពប្រជាធិបតេយ្យបដិវត្តន៍យើងៗ ដូច្នេះ យុវជន-យុវនារីបដិវត្តន៍យើងត្រូវមានលោកទស្សនៈឲ្យត្រឹមត្រូវច្បាស់លាស់នៅក្នុងខ្លួន តើយើងស្រឡាញ់ យើងចង់បាន យើងការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យដើម្បីអ្វី? ដើម្បីខ្លួនយើងសប្បាយភ្នែក ពេញចិត្តពេញថ្លើម ពិរោះស្តាប់ ឬក៏ដើម្បីការពារប្រទេសជាតិយើងឲ្យឋិតថេរគង់វង់រឹងប៉ឹង និងខ្លាំងក្លាពូកែក្នុងក្របខណ្ឌព្រំដែនដ៏ពិសិដ្ឋរបស់យើង ដើម្បីកសាងប្រទេសឲ្យបានចម្រើនថ្កុំថ្កើងរុងរឿងឆាប់រហ័សបំផុត និងដើម្បីដោះស្រាយជីវភាព និងលើកតម្កើងជីវភាពប្រជាជនកម្មករ កសិករ ពលករដ៏ច្រើនកុះករឲ្យមានស៊ីចុកស្លៀកពាក់គ្រប់គ្រាន់ មានជម្រកគត់មត់សមរម្យ មានសុភមង្គលពិតប្រាកដ បានរៀនសូត្រចេះដឹងទាំងវប្បធម៌ នយោបាយ បច្ចេកទេសវិទ្យាសាស្ត្រគ្រប់ៗគ្នាទាំងអស់ៗ

បើយុវជន-យុវនារីបដិវត្តន៍យើងគ្មានលោកទស្សនៈត្រឹមត្រូវទេ នៅច្របូកច្របល់រវាងរូបភាពចាត់តាំងក្លែងក្លាយ និងខ្លឹមសារពិតប្រាកដនៃសិទ្ធិសេរីភាពប្រជាធិបតេយ្យនៅឡើយ នោះយើងប្រាកដជាយល់ច្រឡំថា នៅក្នុងសង្គមនាយទុនមានសិទ្ធិសេរីភាពប្រជាធិបតេយ្យ ជាងក្នុងសង្គមសង្គមនិយម ហើយៗ បើយល់ច្រឡំយ៉ាងនេះហើយ ខ្មាំងអាចឃោសនាញុះញង់ បំបែកបំបាក់ផ្ទៃក្នុងជួរយុវជន-យុវនារីយើងបាន ហើយវាអាចប្រមូលអូសទាញកម្លាំងយុវជន-យុវនារីបដិវត្តន៍យើង ឲ្យទៅបម្រើអំពើក្បត់ជាតិបដិវត្តន៍ ក្បត់បក្ស និងក្បត់ប្រជាជនឯងវិញ ដើម្បីធ្វើឲ្យរបបនាយទុនងើបក្បាលវិញនៅក្នុងសង្គមកម្ពុជាយើងៗ ដូច្នេះ បើយុវជន-យុវនារីបដិវត្តន៍យើង មានលោកទស្សនៈមិនត្រឹមត្រូវចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យនេះទេ យើងមិនគ្រាន់តែសម្រេចទិសដៅបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាមិនបានជោគជ័យលឿនលោតផ្លោះប៉ុណ្ណោះទេ តែវាជាគ្រោះអាសន្នដល់ប្រទេសជាតិ ដល់បដិវត្តន៍សង្គមនិយម ដល់ប្រជាជន និងចំពោះខ្លួនផ្ទាល់ទៀតផងៗ

ដូច្នេះ យុវជន-យុវនារីបដិវត្តន៍យើង ចាំបាច់ត្រូវពង្រឹងលោកទស្សនៈបដិវត្តន៍ចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យឲ្យបានរឹងប៉ឹងដាច់ខាត ហើយពិនិត្យពិចារណាលើធាតុពិតនៃសិទ្ធិសេរីភាពប្រជាធិបតេយ្យបដិវត្តន៍យើងឲ្យបានស៊ីជម្រៅច្បាស់លាស់ថែមទៀតជានិច្ច ទើបឃើញថាសិទ្ធិសេរីភាពប្រជាធិបតេយ្យបដិវត្តន៍យើងបច្ចុប្បន្ននេះ ជាសិទ្ធិសេរីភាពប្រជាធិបតេយ្យពិតប្រាកដរបស់ប្រជាជន កម្មករ កសិករ ពលករនានា ហើយយើងពេញចិត្តពេញថ្លើម និងប្តេជ្ញាការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យនេះដាច់ខាត មិនឲ្យខ្មាំងសត្រូវណាប៉ះពាល់វាយប្រហារ ឬបំភ្លៃបំផ្លើសបានឡើយៗ

# ពិព័រណ៍ដង្ហើមនាសហសម័យ រូបថតស្តីពីការបំពុលបរិស្ថាន

និស្សិតមួយក្រុមមកពីដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចាប់អារម្មណ៍បង្កើតកម្មវិធីថតរូបថតជាច្រើនសន្លឹក ដែលនាំឲ្យមានការបំពុលបរិស្ថាននៅទីក្រុងភ្នំពេញ បណ្តាលមកពីប្រភពផ្សេងៗ ដូចជាយានយន្ត ការសាងសង់ផ្លូវ និងអគាររោងចក្រ ឧស្សាហកម្ម ដែលបញ្ចេញឧស្ម័នពុលទៅក្នុងបរិយាកាស។ ភាគល្អិតនិងសារធាតុគីមីនៃឧស្ម័នពុល បង្កឲ្យមានបម្រែបម្រួលអាកាសធាតុ ដែលបណ្តាលឲ្យមានផលប៉ះពាល់សុខភាព។ ស្របពេលទីក្រុងភ្នំពេញ ក្លាយជាទីក្រុងសេដ្ឋកិច្ចឈានមុខជាមួយការអភិវឌ្ឍន៍រីកលូតលាស់ ដែលជាសញ្ញាវិជ្ជមាន ការអភិវឌ្ឍន៍ដោយនិរន្តរភាព តម្រូវឲ្យមានការចូលរួមអនុវត្ត និងសហការពីគ្រប់មជ្ឈដ្ឋាន ពីព្រោះការបំពុលបរិយាកាសជាបញ្ហាសកល។

រូបថតទាំងនេះត្រូវបានតាំងបង្ហាញនៅក្នុងកម្មវិធីពិព័រណ៍រូបថត «ដង្ហើមនាសហសម័យ» នៅក្នុងវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស្ទីកវីត ក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ដែលមានរយៈពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃទី១៨-២០ ខែកក្កដា ឆ្នាំ២០១៨។ គោលបំណងនៃការបង្កើតកម្មវិធីនេះឡើង គឺដើម្បីជួយលើកកម្ពស់ការយល់ដឹងដល់សាធារណជនពីកត្តាដែលបណ្តាលឲ្យមានបរិស្ថានមិនស្អាត។ ពិព័រណ៍ «ដង្ហើមសហសម័យ» មានរូបភាពជាច្រើន ដែលបានផ្តិតចេញពីកែវថតរូបសហសម័យ ចេញពីទស្សនៈវិស័យសារព័ត៌មាន។ ពិព័រណ៍នេះបានបង្ហាញពីភាពច្នៃប្រឌិត និងឆ្លុះបញ្ចាំងពីបញ្ហាដែលនាំឲ្យមានការបំពុលបរិយាកាស និងបង្ហាញពីវិធីសាស្រ្តក្នុងការផ្តិតយករូបភាព ឆ្លុះបញ្ចាំងពីលក្ខខណ្ឌនៃអាជីពសារព័ត៌មាន ជៀសជាងការផ្តិតយករូបភាពគ្រាន់តែចង់បង្ហាញពីព័ត៌មាន ដែលសាធារណៈជនមើលឃើញតែប៉ុណ្ណោះ។ ដូច្នេះ សាធារណៈជនដើរតួយ៉ាងសំខាន់ក្នុងការបំពេញអត្ថន័យពេញលេញនៃរឿងរ៉ាវក្នុងពិព័រណ៍ «ដង្ហើមសហសម័យ»។

កម្មវិធីតាំងពិព័រណ៍នេះ បានដឹកនាំដោយកញ្ញា ម៉ិច សេរីរ័ត្ន ជានិស្សិតឆ្នាំទី៤ មកពីដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ សេរីរ័ត្ន ជាអ្នកស្រឡាញ់បរិស្ថាន និងសិល្បៈថតរូបជាពិសេស គឺសិល្បៈនៃការថតរូបតាមដងផ្លូវ។ សេរីរ័ត្ន បានបង្កើតស្នាដៃ



សាធារណជនទស្សនាពិព័រណ៍ដង្ហើមសហសម័យ នៅវិចិត្រសាសិល្បៈសហសម័យវិទ្យាស្ថានស្ទីកវីត

មួយនេះឡើង «ដង្ហើមនាសហសម័យ» សម្រាប់និក្ខេបបទរបស់ខ្លួន។ សេរីរ័ត្ន បានបញ្ចូលប្រធានបទបរិស្ថាន ខ្យល់កខ្វក់ អមជាមួយនឹងសិល្បៈរូបភាព ដើម្បីចែករំលែកពីកិច្ចការស្រាវជ្រាវ និងផ្សព្វផ្សាយពីបញ្ហាខ្យល់កខ្វក់ទៅកាន់សាធារណជន។ «ដង្ហើមនាសហសម័យ» មានទម្រង់ជាសៀវភៅកម្រាស់ ៨២ទំព័រ រំលេចពីប្រភពនៃខ្យល់កខ្វក់ក្នុងទីក្រុងភ្នំពេញ តាមរយៈរូបភាពនិងអត្ថបទដែលមានលក្ខណៈស្របតាមវិជ្ជាជីវៈសារព័ត៌មាន ក្នុងន័យឆ្លុះបញ្ចាំងពីទិដ្ឋភាពពិតនៃបញ្ហាអមជាមួយសិល្បៈរូបភាព បែបសហសម័យដែលតម្រូវឲ្យទស្សនិកជនស្វែងយល់ពីអត្ថន័យរូបភាព និងរឿងរ៉ាវនីមួយៗតាមរយៈខ្លួនឯងដោយផ្ទាល់។ កម្មវិធីនេះ ក៏មានការចូលរួមពីបុគ្គលិកអង្គការ អ្នកសារព័ត៌មាន សាស្ត្រាចារ្យ និងសិស្ស-និស្សិត ជាច្រើននាក់។

នៅក្នុងកម្មវិធីបើកសម្ពោធការតាំងពិព័រណ៍«ដង្ហើមនាសហសម័យ» មានរយៈពេលមួយម៉ោងកន្លះ រួមមានការឡើងចំណាប់អារម្មណ៍របស់កញ្ញា ម៉ិច សេរីរ័ត្ន អ្នកដឹកនាំកម្មវិធី ការដើរមើលពិព័រណ៍រូបថត ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារខ្លី បន្ទាប់មកមានសំណួរនិងចម្លើយពីអ្នកចូលរួមក្នុងកម្មវិធីនេះ។ អ្នកចូលរួមម្នាក់បានសួរសំណួរថា តើអ្នកមានទស្សនៈ និងមានការយល់ឃើញយ៉ាងណានៅមុនពេលថតរូបទាំងនេះ? តើអ្នកជួបភាពលំបាក និងដោះស្រាយយ៉ាងណា នៅពេលចេញទៅថតរូបទាំងនេះ? ជាមួយបទពិសោធន៍ក្នុងការងារថតរូប សេរីរ័ត្ន បានរៀបរាប់ថា គាត់ត្រូវរៀបចំផែនការនៅមុនពេលចេញទៅថតរូប និងត្រូវជិះម៉ូតូជាមួយក្រុមការងារទៅថត ហើយពេលខ្លះគាត់ត្រូវទៅថតនៅកន្លែងផ្សេងៗដោយគ្មានការរៀបចំជាមុន ដូចជា កន្លែងដែលកំពុងមានភ្លើងឆេះ។ ការងារទាំងនេះជាការប្រឈមសម្រាប់ខ្លួន ហើយជួនកាល ក៏មិនបានសម្រេចទៅតាមបំណងដែលខ្លួនចង់បានដែរ។

សេរីរ័ត្នក៏បានសម្តែងអារម្មណ៍ត្រេកអរដែលមានឱកាសបានដាក់តាំងពិព័រណ៍រូបថតដែលខ្លួនបានថត និងសរសេរ ជាពិសេសគឺ បានដាក់តាំងពិព័រណ៍នៅក្នុងវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស្លឹករឹត ដែលជាទីកន្លែងអប់រំបណ្តុះបណ្តាលនិងលើកកម្ពស់ការអប់រំប្រវត្តិសាស្ត្រនិងកេរដំណែលដែលបានបន្សល់ទុកពីរបបខ្មែរក្រហម ហើយក៏ជាទីកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ មិនតែប៉ុណ្ណោះ វិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស្លឹករឹតក៏បានចូលរួមចំណែកក្នុងការលើកកម្ពស់និងគាំទ្រដល់វិចិត្រករខ្មែរទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍កិច្ចការសិល្បៈរបស់ខ្លួន។

ហូ ថុនា



រូបថតពិព័រណ៍ដង្ហើមសហសម័យ

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៨ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្ដី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្ដី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ១ច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាមុីខ្លួន។

២) ប្រវត្តិរូបសង្ខេប១ច្បាប់ (Resume) ។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org ។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ៖ ០២៣ ២១៨ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# សង្គ្រាមអាចធ្វើឲ្យមនុស្សភ្លេចភាសា

ដោយសារសង្គ្រាម និងការភៀសខ្លួនចេញពីស្រុកកំណើត ទៅចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហមបានធ្វើឲ្យចាំង គីមញ៉ាត ជាជនជាតិស្មៀង អាយុ ៧៣ឆ្នាំ ស្ទើរតែភ្លេចភាសាកំណើតរបស់ខ្លួន ដោយសារគាត់ប្តូរមកប្រើប្រាស់ភាសាខ្មែរ ដើម្បីទំនាក់ទំនងប្រចាំថ្ងៃ និងធ្វើការងារ។ សព្វថ្ងៃនៅក្នុងភូមិ១០៥ ដែល គីមញ៉ាត បានមករស់នៅមានជនជាតិស្មៀងពីរគ្រួសារតែប៉ុណ្ណោះ ហើយក្រៅពីនេះមានជនជាតិភាគតិចព្នង ទំពួន រដែ ចារ៉ាយ ក្រោល និងខ្មែរ សរុបប្រមាណជាង២០០គ្រួសាររស់នៅលាយឡំគ្នា។ គីមញ៉ាត មានប្រសាសន៍ថា ដោយសារកូនៗ និងចៅៗរបស់គាត់មិនបានរៀនសូត្រ និងមិនចេះនិយាយភាសាស្មៀងដូចគាត់ ទើបគាត់ភ័យខ្លាចបាត់បង់ភាសានេះនៅថ្ងៃខាងមុខ។ ដូច្នេះហើយ គាត់ចង់ឲ្យមានការអភិរក្សភាសា វប្បធម៌ ប្រពៃណី ជនជាតិស្មៀងនេះឡើងវិញ។

គីមញ៉ាត មានប្រសាសន៍ថា តាំងពីនៅតូច គាត់បានដឹងថាជនជាតិស្មៀងរស់នៅប្រមូលផ្តុំនៅឃុំស្រែខ្ទុំ ស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី ហើយទំនៀមទម្លាប់ប្រពៃណីសាសនារបស់ជនជាតិស្មៀង ក្នុងពិធីបុណ្យសព ពិធីរៀបការ គឺកូនប្រុសចូលស្តីដណ្តឹងកូនស្រីដូចជនជាតិខ្មែរដែរ ដោយមានកាប់ជ្រូក មាន់ទា គោ ក្របី ដប់លៀង ប៉ុន្តែមិនមានផ្លែឈើសម្រាប់សែនព្រេន និងមិនមានអាចារ្យទេ គឺមានតែម្ចាស់ស្រុក ដែលប្រជាជនក្នុងភូមិជ្រើសរើសធ្វើជាអ្នកដឹកនាំ និងចាត់ចែងពិធី។ រីឯការប្រណិបត្តិសាសនា ជនជាតិស្មៀងមួយចំនួន បានទៅវត្តអារ៉ាម និងធ្វើបុណ្យដូចជនជាតិខ្មែរដែរ។ ជនជាតិស្មៀង មានតែភាសានិយាយប៉ុណ្ណោះ។ ភាសានិយាយរបស់ជនជាតិស្មៀងខ្លះប្រហាក់ប្រហែលនឹងភាសាខ្មែរដែរ។

គីមញ៉ាត មានបងប្អូនបង្កើតបីនាក់ ស្រីពីរ ប្រុសមួយ ហើយគាត់ជាកូនទីពីរក្នុងគ្រួសារ។ គីមញ៉ាត បានក្លាយជាក្មេងកំព្រាតាំងពីនៅវ័យកុមារ ព្រោះឪពុកម្តាយរបស់គាត់បានស្លាប់ដោយសារជំងឺ។ គីមញ៉ាត បានរស់នៅក្រោមការថែទាំ និងចិញ្ចឹមបីបាច់ពីបងស្រីដែលប្រកបរបរធ្វើស្រែ និងចម្ការ។ នៅឆ្នាំ១៩៥៩ គីមញ៉ាត បានចូលរៀនភាសាខ្មែរនៅសាលាស្រែខ្ទុំបានរយៈពេលពីរឆ្នាំ ក្រោយមកគាត់បានប្តូរមករៀននៅអនុវិទ្យាល័យអូររាំងចាប់ពីថ្នាក់ទី១០ ដល់ថ្នាក់ទី៧ (សង្គមចាស់)។ បន្ទាប់ពីប្រលងជាប់មធ្យមសិក្សា គីមញ៉ាត បានទទួលអាហាររូបករណ៍មករៀនបន្តនៅវិទ្យាល័យក្នុងទីរួមខេត្តមណ្ឌលគិរី ដោយស្នាក់នៅ និងហូបបាយនៅសាលា ដែលសម្តេចព្រះ នរោត្តុ សីហនុ ជាអ្នកឧត្ថម្ភ។ សិស្សនៅក្នុងថ្នាក់របស់ គីម ញ៉ាត នៅពេលនោះភាគច្រើនជាជនជាតិស្មៀង ព្នង និងជនជាតិខ្មែរតិចតួច ដែលជាកូនចៅរបស់នាយទាហ៊ាន។ នៅពេលរៀននៅវិទ្យាល័យ គីមញ៉ាត មិនសូវបានមកលេងស្រុកកំណើតទេ ទោះក្នុងឱកាស ឈប់បុណ្យភ្ជុំបិណ្ឌ អុំទូក និងចូលឆ្នាំប្រពៃណីខ្មែរ ក៏ដោយ ព្រោះផ្លូវលំបាកធ្វើដំណើរ។ គីមញ៉ាត បានមកលេងស្រុកកំណើត តែនៅពេលសិស្សឈប់សម្រាកវិស្សមកាលតែប៉ុណ្ណោះ ហើយគាត់ត្រូវធ្វើ ដំណើរដោយថ្មើរជើងដោយត្រូវសុំបាយ និងផ្ទះប្រជាជននៅតាមផ្លូវស្នាក់នៅមួយយប់ទើបបន្តដំណើរទៅដល់ផ្ទះរបស់គាត់។

គីមញ៉ាត បានរៀននៅវិទ្យាល័យក្នុងក្រុងមណ្ឌលគិរីរហូតដល់រដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧០ ទើបឈប់រៀន ព្រោះសភាពការណ៍ច្របូកច្របល់ ដោយមានកងទ័ពវៀតកុង និងកងកម្លាំងរំដោះ (បដិវត្តន៍) វាយចូលក្នុងក្រុងមណ្ឌលគិរី រយៈពេលពីរថ្ងៃរហូតដណ្តើមកាន់កាប់ក្រុងនេះបាន។ នៅពេលនោះ ប្រជាជនក្នុងក្រុងមណ្ឌលគិរីបាននាំគ្នាចាកចេញពីផ្ទះរៀងៗខ្លួន ចំណែក គីមញ៉ាត មិនហ៊ានត្រឡប់ទៅផ្ទះនៅភូមិស្រែខ្ទុំទេ ព្រោះមិនហ៊ាន

ដើរម្នាក់ឯង ដូច្នេះគាត់ក៏ទៅនៅជាមួយកង កម្លាំងរំដោះ ដែលបោះទីតាំងនៅលើភ្នំដោះក្រមុំ។ រយៈពេលពីខែក្រោយ មកកងទ័ព លន់ នល់ វាយ យកបានក្រុងមណ្ឌលគិរីមកវិញ ទើប គឹមញ៉ៅត រត់ភៀសខ្លួនមកនៅជាមួយជនជាតិព្នងនៅ ភូមិយៀក ឃុំសណ្ដាយ ស្រុកសម្បូរណ៍ ខេត្តក្រចេះ។ ដោយ សារ មានមនោសញ្ចេតនាជាមួយ គឹមញ៉ៅត និងដឹងថា គឹម ញ៉ៅត នៅលីវ ទើបជនជាតិព្នងនៅក្នុងភូមិយៀក បានឃាត់ គឹមញ៉ៅត ឲ្យរស់នៅក្នុងភូមិជាមួយ និងចង់ឲ្យ គឹមញ៉ៅត រក ប្រពន្ធក្នុងភូមិនេះទៀតផង។ គឹម ញ៉ៅត រស់នៅក្នុងភូមិយៀក បានរយៈពេលពីរថ្ងៃ ក៏ត្រូវបានអង្គការដែលចុះមកធ្វើការ នៅតាមភូមិជ្រើសរើសគាត់ឲ្យចូលបម្រើបដិវត្តន៍ ហើយ រយៈពេល៦ខែក្រោយមក គាត់ក៏ត្រូវបានចាត់តាំងឲ្យចូល ធ្វើឈ្លបឃុំសណ្ដាយ។

មួយរយៈក្រោយមក គឹមញ៉ៅត បានទទួលដំណឹងថា នៅភូមិកំណើតរបស់គាត់ត្រូវកងកម្លាំងបដិវត្តន៍ ចូលមក គ្រប់គ្រងហើយ ទើបគាត់សុំអង្គការត្រឡប់ទៅភូមិកំណើត វិញ។ ប៉ុន្តែ គឹមញ៉ៅត មិនបានទៅដល់ភូមិទេ គឺអង្គការបាន ចាត់តាំងឲ្យគាត់ចូលធ្វើការនៅមន្ទីរនយោបាយ ស្ថិតក្នុងភូមិ ខ្ទង់ ឃុំខ្ទង់ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី តំបន់១០៥ ក្រោម ការគ្រប់គ្រងរបស់ឈ្មោះ ប៉ុក អាយុប្រមាណ៣០ឆ្នាំ ជា ប្រធានមន្ទីរ និង កាស៊ី ជនជាតិចារ៉ាយ ជាចៅហ្វាយស្រុកកែវ សីមា។ នៅក្នុងមន្ទីរនយោបាយភូមិខ្ទង់ ដែល គឹម ញ៉ៅត ធ្វើ ការមានសមាជិកសរុបទាំងអស់ប្រមាណ ជាង១០០នាក់ ជា ជនជាតិភាគតិចស្ទៀង និងជនជាតិ ភាគតិចព្នង និងមានស្រី ប្រុសនៅលីវរស់នៅលាយឡំគ្នា។ ការងារប្រចាំថ្ងៃរបស់ គឹម ញ៉ៅត នៅមន្ទីរពេល នោះ គឺលើកភ្លឺស្រែ ដកស្ទូង និងចុះទៅ ជួយសហករណ៍។ ជាដំបូងអង្គការបែងចែកជាសហករណ៍ តូច ដែលមានសមាជិកចាប់ពីប្រាំ ទៅប្រាំមួយគ្រួសារ ហើយ ត្រូវហូបបាយរួមជុំគ្នា។ ក្រោយមក ទើបអង្គការពង្រីកទៅ ជាសហករណ៍ធំ ដោយបញ្ចូលប្រជាជនក្នុងភូមិទាំងមូល ដែល មានចំនួនរហូតដល់រាប់រយគ្រួសារ។ នៅពេលនោះទោះបី មិនមានការហាមឃាត់ក្នុងការប្រើប្រាស់ភាសា តែ គឹមញ៉ៅត


ចាំង គឹមញ៉ៅត ជនជាតិស្ទៀងនៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

និងសមាជិកនៅមន្ទីរទាំងអស់ត្រូវប្រើប្រាស់ភាសាខ្មែរ ដើម្បីទំនាក់ និងធ្វើការងារ។ ក្រៅពីការងារពលកម្ម គឹមញ៉ាត ត្រូវរៀនសូត្រពីការតស៊ូបដិវត្តន៍ ពីអនាម័យរស់នៅ ដូចជា ដាំទឹកផឹក ដុសសម្អាតខ្លួនប្រាណ។ ប៉ុន្តែនៅសម័យនោះ មិនមានសាប៊ូដុសខ្លួនទេដូច្នេះស្រីៗជនជាតិភាគតិចបានយកផ្លែពោនដាំជាមួយទឹកបាយរហូតដល់ពុះ ទើបទុកឲ្យត្រជាក់ ហើយយកមកកក់សក់ឲ្យទន់។ ជនជាតិភាគតិចខ្លះទៀត បានយកសម្បកពពេលមកដំឲ្យទក់ និងចេញពពុះ ទើបមកដុសខ្លួន និងកក់សក់។

នៅរៀងរាល់ម៉ោង៦ល្ងាច ប្រធានមន្ទីរបានកោះហៅ គឹមញ៉ាត និងសមាជិកក្នុងមន្ទីរនយោបាយ ទាំងអស់មកប្រជុំដកពិសោធន៍ និងឲ្យសមាជិកទាំងអស់ឡើងរាយការណ៍ពីការងារប្រចាំថ្ងៃ និងឡើងធ្វើស្វ័យទិតៀន ពីការប្រព្រឹត្តខុសឆ្គងសីលធម៌ជាមួយនារី និងការប្រើពាក្យសម្តីខុសឆ្គងដើម្បីកែលម្អ។ បន្ទាប់ពីប្រជុំចប់ ប្រធានមន្ទីរបានដាក់ការងារដែលគណស្រុកកែវសីមា កំណត់មកឲ្យសមាជិកនៅក្នុង មន្ទីរទាំងអស់អនុវត្តនៅថ្ងៃបន្ទាប់។ ដូច្នេះនៅរៀងរាល់ម៉ោង៦ព្រឹក សមាជិកក្នុងមន្ទីរទាំងអស់ត្រូវចាកចេញទៅធ្វើការរៀងៗខ្លួន ដូចជា ទៅកាប់ឬស្សី បោចវល្លិ៍មកចងធ្វើរបង រកត្រី និងទៅភ្ជួររាស់ ដក ស្ទូង ដែលជាការងារស្នូលរបស់មន្ទីរ។

នៅឆ្នាំ១៩៧២ គឹមញ៉ាត ត្រូវបានអង្គការដកឲ្យទៅធ្វើការនៅមន្ទីរយោធាក្នុងភូមិរហូត ឃុំរហូត ស្រុកកោះញែកវិញ ដោយអង្គការប្រាប់ថា «មិត្តមានសមត្ថភាព ដូច្នេះមិត្តមិនសមនៅមន្ទីរ (នយោបាយ) នេះទេ ត្រូវទៅមន្ទីរយោធា» ដោយទុកអ្នកដែលពិការ កាយសម្បទាមិនរឹងមាំ និងមិនសូវមានសមត្ថភាពឲ្យនៅធ្វើការក្នុងមន្ទីរនយោបាយដដែល។ នៅមន្ទីរយោធា ដែល គឹមញ៉ាត ផ្លាស់ទៅមានសមាជិកសរុបប្រមាណ ជាង១០០នាក់ និងមានប្រធានមន្ទីរឈ្មោះ គង់ ជា



ឡសម្ងួតថ្នាំជក់ក្នុងស្រុកឆ្លូង ខេត្តក្រចេះ

ជនជាតិចារ៉ាយ។ ទៅដល់ដំបូង គឹមញ៉ាត ត្រូវរៀនសូត្រពីវិន័យ ក្បួនយុទ្ធសាស្ត្រយោធា ដូចជា របៀបគោរព និងលួនក្រាបពេលមានការវាយប្រយុទ្ធគ្នា និងដោះកាំភ្លើង។ បន្ទាប់មក ទើបប្រធានមន្ទីរបែងចែកជា ១) ពួក (១ពួក មានសមាជិក ៣នាក់) ២) ក្រុម (១ក្រុម មានសមាជិក១២នាក់) និង ៣) កង (១កង មាន សមាជិក៣៦នាក់) ឲ្យដើរយាមការពារតាមភូមិ ដូចជា ភូមិខ្ពព ភូមិរយ៉ង ភូមិរហួត និងភូមិដើមស្វាយ។ របបអាហារនៅពេលនោះ មន្ទីរយោធាជាអ្នកបែងចែកឲ្យ គឹមញ៉ាត ដោយពេលព្រឹកមន្ទីរចែកអង្ករមួយកំប៉ុងសម្រាប់ដាំហូប និងល្ងាចមួយកំប៉ុងទៀត ចំណែក ត្រី សាច់ ត្រូវដើររកដោយខ្លួនឯង។ ប៉ុន្តែ សម្រាប់ជនជាតិភាគតិចមិនប្រើខ្ទឹមរីប្រេងសម្រាប់ ចម្អិនម្ហូបទេ។ គឹមញ៉ាត នៅធ្វើការនៅមន្ទីរយោធារហូតដល់អង្គការចុះមកផ្សព្វផ្សាយថា «ភ្នំពេញបែក» ទើបគាត់ដឹងថា «ប្រទេសជាតិទាំងមូលត្រូវបានរំដោះ រួចសមាជិកមន្ទីរទាំងអស់ ក៏នាំគ្នាស្រែកហ៊ោរអបអរសាទរ។ ពេលនោះ ក្នុងមន្ទីររបស់ គឹមញ៉ាត សម្បូរណ៍អាហារ និងគ្រឿងសម្ភារប្រើប្រាស់ រួមមាន ទឹកត្រី ទឹកស៊ីអ៊ីវ ប៊ីចេង សាប៊ូ ដែលអង្គការបញ្ជូនមកឲ្យ។

រហូតមកឆ្នាំ១៩៧៦ គឹមញ៉ាត ក៏បានស្នើ ទៅអង្គការ និងមន្ទីរយោធាដើម្បីរៀបការប្រពន្ធ ជាជនជាតិស្មៀងដូចគ្នាដែលធ្វើការនៅមន្ទីរពេទ្យស្រុកកែវសីមា ខេត្តមណ្ឌលគិរី។ នៅពេលនោះ មានជនជាតិភាគតិចស្មៀង និងព្នងមួយចំនួន ក៏បានស្នើសុំរៀបការប្រពន្ធជាមួយជនជាតិផ្សេងដែរ ដោយអាស្រ័យទៅលើការយល់ព្រមរបស់សាម៉ីខ្លួនខាងស្រី។

គឹមញ៉ាត ធ្វើការនៅមន្ទីរយោធារហូតដល់កងទ័ពវៀតណាមវាយចូលមក នៅឆ្នាំ១៩៧៩ ទើបគាត់ជាមួយប្រពន្ធ និងកូនស្រីម្នាក់ រួមទាំងសមាជិកនៅក្នុងមន្ទីរមួយចំនួន និង អន ស៊ី ជនជាតិព្នងកាត់ចារ៉ាយ (អន ស៊ី ឡើងជាលេខាតំបន់បន្ទាប់អង្គការដក ឡាំង ដែលត្រូវជាប្អូនប្រុសរបស់គាត់ចេញ) ជាលេខាតំបន់១០៥ បានរត់ភៀសខ្លួនមកនៅម្តុំភ្នំដី ក្នុងខេត្តកំពង់ធំ។ នៅទីនោះដោយសារគ្មានស្រូវអង្ករ ដូច្នេះ គឹមញ៉ាត ត្រូវរកក្តួច និងដំឡូងមកហូបជំនួសបាយ រហូតដល់អង្គការប្រមូល និងរៀបចំកម្លាំង និងបង្កើតទៅជាកងពល១០៥ ក្រោមការដឹកនាំរបស់ អន ស៊ី ទើបការរស់ និងជីវភាពរបស់ គឹមញ៉ាត បានប្រសើរខ្លះ។ នៅពេលនោះ គឹមញ៉ាត បានចូលជាសមាជិកកងពល១០៥ ដែលត្រូវវាយប្រយុទ្ធទប់ទល់ជាមួយកងទ័ពវៀតណាម ហើយពេលវាយប្រយុទ្ធគ្នាម្តងៗ យោធាខ្មែរក្រហម តែងប្រើដំបូក និងដើមឈើធំៗដើម្បីការពារខ្លួនព្រោះត្រូវចល័តកងយោធាទៅកន្លែងផ្សេងទៀតដែលខុសពីកងទ័ពវៀតណាមដឹកលេណដ្ឋានដើម្បីការពារខ្លួនក្នុងពេលប្រយុទ្ធ។ គឹមញ៉ាត នៅចាំពាក្យគាត់ និងយោធាខ្មែរក្រហមបានទន្ទេញចាំជាប់មាត់ ដើម្បីជៀសគ្រោះថ្នាក់ពេលប្រយុទ្ធគ្នាម្តងៗ៖«គុណម៉ែគុណឪគុណដំបូកគុណដើមឈើធំៗ ឲ្យកូនចៅបានរួចពីគ្រោះថ្នាក់» រហូតមកដល់សព្វថ្ងៃ។ គឹមញ៉ាត បានបញ្ជាក់ថា ការដឹកលេណដ្ឋានការពារខ្លួនក្នុងពេលប្រយុទ្ធមានភាពកក់ក្តៅនិងមានសុវត្ថិភាពជាងដើមឈើ និងដំបូកដែលយោធាខ្មែរក្រហមបានប្រើប្រាស់។

មកដល់ឆ្នាំ១៩៨០ គឹមញ៉ាត បានចេញពីភ្នំដី មកនៅភ្នំដងរែកម្តុំប្រូក១០០១ (តំបន់មុំបីជាប់ព្រំប្រ ទល់ប្រទេសកម្ពុជា ឡាវ និង ថៃ)។ នៅពេលនោះ យោធាក្នុងកងពល ១០៥ ក្រោមការគ្រប់គ្រងរបស់ អន ស៊ី មួយចំនួនត្រូវបានរក្សាទុកសម្រាប់វាយទប់ទល់ជាមួយកងទ័ពវៀតណាម នៅតាមបណ្តោយជួរ ភ្នំដងរែក ព្រំដែនខ្មែរ-ថៃ ចំណែកកងយោធាមួយចំនួនទៀតត្រូវបានចាត់តាំងឲ្យចូលធ្វើការ និងស៊ើបការណ៍នៅខាងក្នុងប្រទេសកម្ពុជា។ ក្រោយមកគឹមញ៉ាត និងប្រពន្ធបានផ្លាស់ពីតំបន់១០០១ ទៅរស់នៅជំរំស៊ីងចាន់ក្នុងខេត្តស៊ីសាកេត ប្រទេសថៃ ដោយគាត់ត្រូវបានអង្គភាព និងប្រពន្ធរបស់យោធាខ្មែរក្រហម ជ្រើសរើសឲ្យធ្វើជាគ្រូបង្រៀនក្មេងៗដែលភាគច្រើនភៀសខ្លួនមកពីខេត្តមណ្ឌលគិរី។ នៅជំរំ គឹមញ៉ាន បានបង្រៀនទៅតាមអង្គភាព (ទ័ព) របស់គាត់រៀបចំពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី៣ ហើយត្រូវបង្រៀនលេខ អក្សរ ដែលមាននៅក្នុងសៀវភៅដែលខ្មែរក្រហមបាន

សរសេរ និងបោះពុម្ព។ ក្រៅពី គឹមញ៉ាត មានគ្រូ យ៉ុត និង គ្រូ អុន (បច្ចុប្បន្ននាយកសាលាបឋមសិក្សាថ្នល់កែង) នៅបង្រៀននៅទីនោះ។ គឹមញ៉ាត បានបន្តថា ជំនួយសម្ភារសម្រាប់ការបង្រៀនសិស្សនៅពេលនោះក្រៅពីអង្គភាព គឺបានមកពីអង្គការយូនីសេហ្វ អង្គការសិទ្ធិមនុស្ស ទទួលបន្ទុកជនភៀសខ្លួន និងកាកបាទក្រហមអន្តរជាតិ។ ចំណែករបបសម្រាប់គ្រូនៅពេលនោះ មានអង្ករ ត្រីខ ខោអាវក្នុងមួយឆ្នាំទទួលបានពីរកំប្លេ ប៉ុន្តែមិនមានប្រាក់ខែទេ។

នៅឆ្នាំ១៩៨៧ គឹមញ៉ាត និងសិស្សបានផ្លាស់ពីជំរំស៊ីងចាន់ មកនៅជំរំត្រាវជូរ នៅជិតច្រកជាំ ក្នុងខេត្តស៊ីសាកេត ប្រទេសថៃ ដដែល។ មកដល់ជំរំអង្គភាព១០៥របស់ គឹមញ៉ាត បានសាងសង់សាលាថ្មី សម្រាប់សិស្សដែលមានចំនួនប្រមាណ៥០នាក់ ដែលមានឪពុកធ្វើជាយោធាខ្មែរក្រហម ហើយត្រូវបញ្ជូនឲ្យឡើងទៅប្រយុទ្ធនៅសមរភូមិមុខ។ បន្ទាប់ពីកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ គឹមញ៉ាត ប្រពន្ធ និងកូន៤នាក់ និងសមាជិកនៅក្នុងអង្គភាពកងពល១០៥ទាំងមូល បានចាកចេញពីជំរំ ត្រាវជូរ មករស់នៅម្តុំអូរជីក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យវិញ។ ប៉ុន្តែដោយសារនៅអូរជីកទឹកលិចខ្លាំង ទើបនៅឆ្នាំ១៩៩១ គឹមញ៉ាត និងអង្គភាពរបស់គាត់បានប្តូរមករស់នៅក្នុងភូមិ១០៥ (យកតាម ឈ្មោះកងពល១០៥ ហើយក្រោយមកភូមិនេះត្រូវបានកាត់ចូលទៅក្នុងស្រុកត្រពាំងប្រាសាទ) ដែលជាទីទួល។ ពេលមកដល់ដំបូង ភូមិ១០៥មិនមានផ្លូវសម្រាប់ប្រជាជន និងកងទ័ពធ្វើដំណើរទេដូច្នេះសមាជិកកងពល១០៥ទាំងមូលរួមទាំង គឹមញ៉ាត បានត្រាយព្រៃធ្វើផ្លូវដើរ រួចហើយសង់ខ្ទមតូចៗ និងប្រក់តង់កៅស៊ូស្នាក់នៅបណ្តោះអាសន្ន។ ទោះយ៉ាងណា គឹមញ៉ាត មិនហ៊ានដើរពានព្រៃជ្រៅទេ ដោយសារខ្លាចគ្រាប់មីនបង្កប់ នៅអំឡុងពេលយោធាខ្មែរក្រហមប្រយុទ្ធជាមួយវៀតណាម។ បន្ទាប់ពីរៀបសង់ផ្ទះ និងសាលារួច គឹមញ៉ាត បានចូលបង្រៀនសិស្សនៅសាលាបឋមសិក្សាថ្នល់កែង ក្នុងភូមិ១០៥ រហូតដល់ឆ្នាំ២០០០ ទើបគាត់ឈប់បង្រៀនសិស្ស ហើយផ្លាស់មកធ្វើមេភូមិ១០៥វិញ។ នៅពេលនោះ មានប្រជាជនប្រមាណ១៥០គ្រួសារ និងមានជនជាតិស្មៀងពីគ្រួសារប៉ុណ្ណោះរស់នៅក្នុងភូមិនេះ។ គឹមញ៉ាត បានធ្វើមេភូមិរហូតដល់ឆ្នាំ២០១៣ ទើបគាត់ចូលនិវត្តន៍។ សព្វថ្ងៃគាត់ប្រកបរបបធ្វើស្រែ និងចម្ការ ចំណែកកូនៗទាំង៤នាក់មានគ្រួសារពីរនាក់ និងពីរនាក់ទៀតនៅក្នុងបន្ទុក។

គឹមញ៉ាត បានមានប្រសាសន៍ថា តាំងពីចាកចេញស្រុកកំណើតនៅឆ្នាំ១៩៧០ មកដល់សព្វថ្ងៃ គាត់មិនដែលបានទទួលដំណឹងពីបងស្រីរបស់គាត់ថាស្លាប់ ឬនៅរស់យ៉ាងណាទេ។ ចំណែកប្អូនស្រីរបស់គាត់ម្នាក់ទៀត គាត់ទើបបានទទួលដំណឹងកាលពីឆ្នាំ២០០៣ថា រស់នៅក្នុងស្រុកស្នួល ខេត្តក្រចេះ។ គឹមញ៉ាត បានបន្តថា ប៉ុន្មានឆ្នាំមុនគាត់បានទៅលេងបងប្អូននៅស្រុកកំណើតនៅឃុំស្រែខ្ទុំ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ប៉ុន្តែនៅទីនោះជនជាតិស្មៀងឈប់និយាយភាសារបស់ខ្លួនទៀតហើយ គឺនិយាយតែភាសាព្នង និងភាសាខ្មែរ។ សព្វថ្ងៃគឹមញ៉ាតនិយាយភាសាស្មៀងតែពីរនាក់ប្រពន្ធរបស់គាត់តែប៉ុណ្ណោះ។ *សោម ប៊ុនថន*

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

*មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូប ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួននឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖*

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ*
*ព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទលេខ (៨៥៥) (២៣) ២១១ ៨៧៥*
*ទូរសព្ទលេខ (៨៥៥) (១២) ៩៩៦ ៧៥០*
*ទូរសព្ទលេខ (៨៥៥) (២៣) ២១០ ៣៥៨*
Email: truthbunthorn.s@dccam.org
Home Page: www.d.dccam.org

# តំបន់អន្លង់វែងជាកន្លែងដែលមានសុវត្ថិភាពបំផុតសម្រាប់ខ្ញុំ

អន្លង់វែង ជាស្រុកមួយស្ថិតនៅក្នុងខេត្តឧត្តមានជ័យ ភាគខាងជើងនៃប្រទេសកម្ពុជា ដែលលាតសន្ធឹងតាមជួរភ្នំដងរែក ហើយមានព្រំប្រទល់ជាប់និងប្រទេសថៃ។ សព្វថ្ងៃ អន្លង់វែង ជាតំបន់មួយមានសភាពស្ងប់ស្ងាត់ តែពោរពេញដោយភាពស្រស់ស្អាតដែលលំអរដោយធម្មជាតិព័ទ្ធជុំវិញ។ ប្រជាជនភាគច្រើនប្រកបរបរធ្វើស្រែចម្ការ ចិញ្ចឹមសត្វ និងមានជីវិតរស់នៅផ្សារភ្ជាប់ជាមួយនឹងធម្មជាតិ។

ផ្ទុយទៅវិញ នៅពីខាងក្រោយនៃទឹកដីដែលពោរពេញដោយភាពស្រស់ស្អាត និងសន្តិភាព តំបន់អន្លង់វែង ក៏មានរឿងរ៉ាវជាច្រើនបានកើតឡើងពីអតីតកាល ដែលយើងនឹកស្មានស្ទើរតែមិនដល់។ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជា បានធ្លាក់ចូលក្នុងសង្គ្រាម ដ៏ឃោរឃៅមួយដឹកនាំដោយ ប៉ុល ពត ដែលភាគច្រើនត្រូវបានគេហៅថារបបខ្មែរក្រហម។ របបខ្មែរក្រហមបានសម្លាប់មនុស្សប្រហែល ២លាននាក់ និងបានបន្សល់ទុកស្ត្រីមេម៉ាយ កុមារកំព្រា ជនពិការជាច្រើននៅក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ១៩៧៩ រាជ-រដ្ឋាភិបាលបានផ្តួលរំលំរបប ខ្មែរក្រហមស្ទើរតែគ្រប់តំបន់ តែទោះបីជាយ៉ាងណា មេដឹកនាំខ្មែរក្រហមមួយចំនួនមិនទាន់ចុះចាញ់ទាំងស្រុងក្នុងសង្គ្រាមនេះឡើយ។ មេដឹកនាំខ្មែរក្រហមបានប្រមូលផ្តុំគ្នាតស៊ូប្រឆាំងនឹង រាជរដ្ឋាភិបាលយ៉ាងស្វិត



កែវ ចាន់ រស់នៅឃុំរំចេក ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ស្វាញនៅក្នុងតំបន់អន្លង់វែងរហូតដល់ឆ្នាំ១៩៩៨។

កែវ ចាន់ ជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ បានចូលរួមតស៊ូជាមួយខ្មែរក្រហមប្រឆាំង នឹងរដ្ឋាភិបាលនៅក្នុងតំបន់អន្លង់វែង។ ក្នុងនាម ចាន់ ជាកម្មាភិបាលខ្មែរក្រហម គាត់ជឿថាតំបន់អន្លង់វែងជាកន្លែងតែមួយគត់ដែលអាចផ្តល់សុវត្ថិភាពសម្រាប់គាត់ និងក្រុមគ្រួសារ។ ចាន់ បន្ថែមថា ទោះបីជាក្នុងឆ្នាំ១៩៩៨ ខ្មែរក្រហមបានដួលរលំទាំងស្រុង ហើយប្រទេសជាតិចាប់ផ្តើមទទួលបានសន្តិភាព ដោយមិនមានការប្រយុទ្ធគ្នាដូចមុន តែ ចាន់ នៅតែមានការភ័យខ្លាច សង្គ្រាមកើតឡើងម្តងទៀត។ ចាន់ មិនចង់ត្រឡប់ទៅស្រុកកំណើតវិញឡើយ ហើយពេញចិត្ត នឹងការតស៊ូរស់នៅតំបន់អន្លង់វែងជាមួយនឹងកូន៥នាក់ បន្ទាប់ពីគាត់ត្រូវបានប្តីបោះបង់ចោល។ តំបន់អន្លង់វែងជាកន្លែងមួយដែលបានបង្កើតអនុស្សាវរីយ៍ជាច្រើនសម្រាប់ ចាន់ ទាំងជីវិតគ្រួសារ និងបទពិសោធន៍ចូលរួមក្នុងការធ្វើសង្គ្រាម។ ដូចច្នេះ ចាន់ សម្រេចចិត្តមិនត្រឡប់ទៅរស់នៅជាមួយម្តាយឪពុក និងសាច់ញាតិរបស់គាត់នៅស្រុកកំណើតរហូតដល់សព្វថ្ងៃនេះ។ ចាន់ ជានារីម្នាក់ក្នុងចំណោមនារីជាច្រើនទៀតដែលបានឆ្លងកាត់ក្នុងសង្គ្រាមដ៏ឃោរឃៅនេះ។ ខាងក្រោមនេះគឺជាបទពិសោធន៍ជីវិតរបស់ កែវ ចាន់៖

នៅមិនឆ្ងាយប៉ុន្មានពីក្លោងទ្វារវត្តអូរគគីរកណ្តាល មានផ្ទះឈើតូចមួយ មានដំបូលប្រក់ក្បឿង នៅដាច់ឆ្ងាយពីគេស្ថិតនៅខាងឆ្វេងដៃ ដែលមានស្ត្រីចំណាស់ម្នាក់កំពុងតែប្រលែងលេងជាមួយកុមារតូចៗ ៣នាក់នៅខាងមុខផ្ទះយ៉ាងសប្បាយរីករាយ។ ស្ត្រីចំណាស់ម្នាក់នោះឈ្មោះ កែវ ចាន់។ សព្វថ្ងៃ កែវ ចាន់ មានអាយុ៦២ឆ្នាំ រស់នៅជាមួយចៅប្រុសតូចៗ៣នាក់ ខណៈដែលកូនៗរបស់គាត់បានចាកចេញទៅធ្វើការនៅក្នុងប្រទេសថៃ។ កែវ ចាន់ មានស្រុកកំណើតនៅក្នុងស្រុកជុំគិរី ខេត្តកំពត ហើយសព្វថ្ងៃរស់នៅភូមិអូរគគីរកណ្តាល ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ចាន់ ជាស្ត្រីមេម៉ាយ មានកូនប្រុស៥នាក់។

ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលមកដល់ទីកន្លែងដែល ចាន់ រស់នៅ។ មិនខុសប្លែក អ្វីពីប្រជាជនដ៏ទៃ ចាន់ និងក្រុមគ្រួសារ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការ និងរស់នៅកន្លែងផ្សេងពីគ្នា។ ចាន់ ត្រូវខ្មែរក្រហមចាត់តាំងឲ្យធ្វើការក្នុងកងចល័តមួយក្នុងស្រុកជុំគិរី ខេត្តកំពត។ ចាន់ ប្រាប់ថាប្រជាជនទាំងអស់ទទួលបានការងារ និងរបបអាហារដូចៗគ្នា។ ការងារភាគច្រើនគឺ ធ្វើស្រែ លើកភ្លឺស្រែ លើកទំនប់ និងជីកប្រឡាយ។ នៅពេលនោះ ប្រជាជនភាគច្រើនត្រូវខ្មែរ-ក្រហមយកទៅសម្លាប់ដោយសារតែការធ្វើពុតជាឈឺ និងខ្ជិលច្រអូសក្នុងការធ្វើការងារ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការបំពេញការងារកាន់តែលំបាកខ្លាំង តែការទទួលរបបអាហារកាន់តែតិចទៅៗ។ ប្រជាជនចាប់ផ្តើមស្លាប់ដោយសារជំងឺឈឺ ការអត់អាហារ ការសម្លាប់ដោយសារតែមានការសង្ស័យថាជាខ្មាំង និងមិនអាចអត់ធ្មត់ជាមួយការងារលើសកម្លាំងបាន។

មិនយូរប៉ុន្មាន ចាន់ ជានារីម្នាក់ក្នុងចំណោមនារីជាច្រើននាក់ ត្រូវបានខ្មែរក្រហមជ្រើស រើសឲ្យចូលហ្វឹកហាត់ធ្វើជាកងទ័ពជាមួយក្រុមនារីមួយក្រុម មានចំនួនប្រហែល១០០នាក់ ដោយ ទទួលបានការបង្ហាត់បង្រៀនពីកងយោធាប្រុសៗ។ ចាន់ ប្រាប់ថា ក្នុងពេលហ្វឹកហាត់រយៈពេល ១ខែនេះ ចាន់ និងកងទ័ពនារីដ៏ទៃទៀត បានហាត់រៀនបាញ់កាំភ្លើង រៀនបោកគ្រាប់បែក និងរត់លូតកាត់បន្ទា។ ការហាត់រៀនពិតជាលំបាកខ្លាំងណាស់ តែ ចាន់ បានទទួលបានរបបអាហារគ្រប់គ្រាន់ជារៀងរាល់ថ្ងៃ។

ក្រោយមក ចាន់ ត្រូវបានមេកងផ្លាស់ឲ្យមករស់នៅ និងធ្វើការក្នុងខេត្តសៀមរាបវិញ។ ចាន់ មិនចង់មករស់នៅខេត្តសៀមរាបទាល់តែសោះ ព្រោះគាត់មិនចង់រស់នៅឆ្ងាយពីឪពុកម្តាយ និងសាច់ញាតិរបស់គាត់។ មកដល់សៀមរាបដំបូង ចាន់ រស់នៅតាមដងស្ទឹងសៀមរាប ទទួលបានតួនាទីជាអ្នកក្តាប់ភូមិទឹកល្អក់ ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ដោយធ្វើការងារជាអ្នកអង្កេតមើលរឿងរ៉ាវដែលបានកើតឡើងក្នុងភូមិ ហើយរាយការណ៍ជូនថ្នាក់លើ។ ក្រៅពីការងារនេះ ចាន់ ត្រូវបានថ្នាក់លើចាត់ឲ្យធ្វើការងារដកស្ទូង

និងលើទំនប់។ ចាន់ ប្រាប់ថាគាត់ មានចិត្តអាណិតប្រជាជនក្រោមការគ្រប់គ្រងរបស់គាត់ណាស់ ជាពិសេសស្ត្រីដែលធ្វើការងារធ្ងន់ៗ មិនសូវមានពេលឈប់សម្រាក និងមិនទទួលបានអាហារគ្រប់គ្រាន់ឡើយ។ ប្រជាជននៅក្រោមការគ្រប់គ្រងរបស់ ចាន់ បានប្រាប់គាត់ថា អ្នកគ្រប់គ្រងមុនៗនៅក្នុងភូមិដែល ចាន់ រស់នៅ បានសម្លាប់ប្រជាជនស្លូតត្រង់ជាច្រើន ហើយអ្នកទាំងអស់នោះក៏ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ក្រោមការសង្ស័យថាជាខ្មាំងដែរ។ ក្រោយមក ចាន់ សង្កេតឃើញមានការចាប់ខ្លួនថ្នាក់លើរបស់គាត់ជាបន្តបន្ទាប់ដោយសារតែការមិនទុកចិត្តគ្នា និងមិនដែលឃើញវិលត្រឡប់មកវិញឡើយ។ ចាន់ មានការព្រួយបារម្ភណ៍យ៉ាងខ្លាំង និងមានការភ័យខ្លាចថ្នាក់លើស្រាវជ្រាវមកដល់គាត់ ហើយយកទៅសម្លាប់ដូចអ្នកដ៏ទៃៗ ចាន់ ប្រាប់ថា រឿងរ៉ាវដែលគាត់ខ្លាចបំផុតគឺ មិនដឹងថា គាត់នឹងមានជីវិតរស់នៅក្នុងថ្ងៃស្អែកដែរឬទេ ព្រោះខ្មែរក្រហមសម្លាប់មនុស្សមិនរើសមុខឡើយ ហើយរឿងរ៉ាវទាំងនេះនៅតែបន្តធ្វើឲ្យគាត់មានអារម្មណ៍ថា ភ័យខ្លាចរហូតដល់បច្ចុប្បន្ន។

នៅពេលដែលកងទ័ពវៀតណាមបានចូលមកដល់ខេត្តសៀមរាបក្នុងឆ្នាំ១៩៧៩ ចាន់ និងកម្មាភិបាលខ្មែរក្រហមដ៏ទៃទៀតបានរត់ភៀសខ្លួនពីភូមិមួយទៅភូមិមួយទៀតសំដៅទៅស្រុកអន្លង់វែង។ ក្រោយមក ចាន់ និងក្រុមរបស់ខ្លួនបានសម្រេចចិត្តរត់ចូលក្នុងព្រៃសំដៅមកស្រុកអន្លង់វែងវិញ ដោយសារតែមានប្រជាជនជាច្រើនចាំស្ទាក់ផ្លូវសម្លាប់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនារតី។ ទោះបីជាប្រឈមមុខនឹងការបាញ់សម្លាប់ពីកងទ័ពវៀតណាមយ៉ាងណា ក៏ដោយ ក៏ ចាន់ សប្បាយចិត្តណាស់ ព្រោះគាត់គិតថាគ្មានថ្នាក់លើណាស្រាវជ្រាវយកគាត់ទៅសម្លាប់ទៀតទេ។ ចាន់ បានឃើញកងទ័ពខ្មែរក្រហមជាច្រើនបានស្លាប់តាមផ្លូវ នៅពេលដែលគាត់រត់គេចពីកងទ័ពវៀតណាមកាត់តាមស្រែណូយនិងចូលទៅក្នុងព្រៃស្អាក យោធាខ្មែរក្រហម បានឲ្យកាំភ្លើង១ដើមម៉ាកកាសេទៅ ចាន់ សម្រាប់ការពារខ្លួនពីការសម្លាប់ពីប្រជាជនព្រោះពេលនោះប្រជាជនចងកំហឹងយ៉ាងខ្លាំងជាមួយនឹងកម្មាភិបាលមកពីភូមិភាគនិរតី និងមានការប៉ុនប៉ងកាប់សម្លាប់កម្មាភិបាលទាំងនោះ។ នៅតាមផ្លូវ ចាន់ ជាអ្នកបុកអង្ករ និងចម្អិនអាហារឲ្យយោធាខ្មែរក្រហមរត់គេចខ្លួនមកស្រុកអន្លង់វែង ហើយក្រៅពីនោះ ចាន់ ជួយសែងកងយោធា ដែលរបួសយកមកព្យាបាល។ លុះមកដល់អន្លង់វែង ចាន់ បានជួបជាមួយក្រុមយោធារបស់ តាម៉ុក ហើយក៏ចូលរួមជាមួយគ្នាតស៊ូប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម។ ចាន់ បានរត់ទៅរស់នៅលើភ្នំអណ្តែងមុតក្នុងកងនារីដឹកជញ្ជូនគ្រាប់។ ការងារប្រចាំថ្ងៃរបស់ ចាន់ គឺលីគ្រាប់ កាំភ្លើងមកដាក់នៅជើងភ្នំរត់ចំប៉ី ឲ្យទៅកងទ័ពខ្មែរក្រហម។

ចាន់ បានរៀបការជាមួយប្តីរបស់គាត់ក្នុងឆ្នាំ១៩៨១ ហើយមានកូនប្រុស៥នាក់។ ប្តីរបស់ ចាន់ គឺជាយោធាខ្មែរ-ក្រហម ដែលក្រោយមកគាត់មានប្រពន្ធថ្មីហើយចាកចេញចោលគាត់រហូតដល់សព្វថ្ងៃ។

ក្រៅពីនេះ កែវ ចាន់ ក៏បានចែករំលែកពីបទពិសោធន៍របស់ស្ត្រីដែលប្រឈមមុខនឹងភាពលំបាកយ៉ាងខ្លាំងចំពោះភាពអាម៉ាសទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ ក៏ដូចជាផ្នែកអនាម័យរបស់ស្ត្រីក្នុងសម័យខ្មែរក្រហមជាដើម។ ចាន់និយាយថា ស្ត្រីត្រូវបង្ខំឲ្យទៅធ្វើការទោះបីជា គេស្ថិតក្នុងស្ថានភាពណាក៏ដោយ។ តែទោះបីជាយ៉ាងណា ការរក្សាជីវិតសម្រាប់ថ្ងៃស្អែកបានធ្វើឲ្យគាត់ និងស្ត្រីដ៏ទៃទៀតមានភាពក្លាហានចំពោះការប្រឈមមុខនឹងភាពខ្មាសអៀនទាំងអស់នេះបាន។

រឿងរ៉ាវរបស់ កែវ ចាន់ បានបង្ហាញឲ្យដឹងថា ស្ត្រីជាច្រើនបានចូលរួមចំណែកក្នុងជួរ ដឹកនាំក្នុងរបបខ្មែរក្រហម ហើយកម្មាភិបាលខ្មែរក្រហម ដូចជា ចាន់ ផ្ទាល់នៅមានភាពភ័យខ្លាច និងព្រួយបារម្ភណ៍យ៉ាងខ្លាំងចំពោះការរើសអើងពីមនុស្សរស់នៅជុំវិញខ្លួន។ មូលហេតុទាំងនេះ បានធ្វើឲ្យ ចាន់ សម្រេចចិត្តតស៊ូរស់នៅក្នុងស្រុកអន្លង់វែងរហូតដល់បច្ចុប្បន្ន។

អ៊ិន សុដាវី





សកម្មភាពដាំកូនឈើ និងដំណាំផ្សេងៗរបស់និស្សិតច្បាប់ និងក្រុមការ

និងសិទ្ធិមនុស្ស ការវេញសសៃអំបោះចាស់និង











មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្នុងដំណើរទស្សនកិច្ចសិក្សាស្តីពីសន្តិភាព
ថ្មីបញ្ចូលគ្នា ៖ ការតភ្ជាប់ទីកន្លែង និងការចងចាំ





# តំបន់ដាច់ស្រយាលដ៏រីករាយក្នុងជីវិតខ្ញុំ

មឿន រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សព្វថ្ងៃបើទោះបីជា មឿន រស់នៅក្នុងភូមិដាច់ស្រយាលមួយឆ្ងាយពីទីប្រជុំជនក៏ដោយ ក៏ មឿន បានបង្ហាញពីភាពរីករាយចំពោះជីវភាពជនបទ ដែលនៅជុំវិញផ្ទះមានធម្មជាតិ រុក្ខជាតិ ហូបផ្លែ និងវាលស្រែបៃតងស្រស់។ ជាមួយសំឡេងរដឹនដូចអ្នកស្រុកមកពីខេត្តសៀមរាប មឿន បានចែករំលែកនូវបទពិសោធន៍ជីវិត រស់នៅក្នុងសម័យខ្មែរក្រហមមកកាន់ខ្ញុំដូចខាងក្រោមថា៖

គាត់មានឈ្មោះ សែម មឿន ភេទស្រី អាយុ៥៦ឆ្នាំ មានទីកន្លែងកំណើតនៅភូមិខ្នា ឃុំក្រូចគរ ស្រុកក្រឡាញ់ ខេត្តសៀមរាប។ បច្ចុប្បន្ន មឿន រស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ មឿន មានឪពុកឈ្មោះ សេប និង ម្តាយឈ្មោះ មិ។ មឿន ជាកូនទី៣ នៅក្នុងគ្រួសារដែលមានបងប្អូនបង្កើតចំនួន៦នាក់៖ ទី១) ឈ្មោះ ពុញ (ប្រុស) ទី២) ឈ្មោះ ប៉ក់ (ប្រុស) ជាអតីតទាហាន លន់ នល់ (ស្លាប់) ទី៣) មឿន ទី៤) ឈ្មោះ គេល (ប្រុស) ទី៥) ឈ្មោះ ធំ (ប្រុស) និង ទី៦) ឈ្មោះ ម៉ៃ (ស្រី)។


សែម មឿន និងចៅស្រី

មឿន មិនបានរៀនសូត្រនោះទេព្រោះម្តាយឈឺញឹកញាប់ ដូច្នេះ គាត់ត្រូវឈប់រៀននៅផ្ទះ ដើម្បីមើលថែទាំម្តាយដែលមានសុខភាពមិនល្អ។ ប្រហែលជាឆ្នាំ១៩៧២-១៩៧៣ ជារៀងរាល់ពីរទៅបីខែម្តង មឿន តែងតែឃើញកងឈ្លបរបស់ខ្មែរក្រហមចូលមកក្នុងភូមិរបស់គាត់។

នៅឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមកាន់អំណាច មឿន ត្រូវបានចាត់ឲ្យធ្វើការជាកង ចល័តនៅសហករណ៍ឃុំក្រូចគរ។ កងចល័តមានគ្នាប្រហែលជា១០នាក់ ហើយមានប្រធានកងឈ្មោះ រឿង និងប្រធានក្រុមឈ្មោះ សៀប ជាអ្នកស្រុកក្រឡាញ់។ មឿន បានធ្វើកងចល័ត ជីកប្រឡាយ និងលើកទំនប់។ នៅមុនពេលចេញទៅជីកប្រឡាយ ប្រធានកងតែងតែហៅ មឿន ទៅប្រជុំនៅពេលល្ងាចប្រាប់ពីផែនការដែលត្រូវធ្វើ។ មឿន បានធ្វើការងារក្នុងកងចល័ត និងបានចេញទៅលើកទំនប់ជីកប្រឡាយដែលស្ថិតនៅខាងកើតស្រុកក្រឡាញ់ជាញឹកញាប់។ នៅពេលទៅជីកប្រឡាយម្តងៗ មឿន បានស្នាក់នៅការដ្ឋានស្ថិតនៅខាងកើតស្រុកក្រឡាញ់ជាច្រើនខែ ទើបបានត្រឡប់មកភូមិវិញ។ នៅពេលដែលជីកប្រឡាយ និងលើកទំនប់នៅក្រឡាញ់ មឿន មិន ដែលបានមកជួបម្តាយទាល់តែសោះ។ មឿន នៅធ្វើការអស់រយៈពេលជិត១ឆ្នាំ ទើបគាត់បានសុំ ច្បាប់ប្រធានកងមកសួរសុខទុកម្តាយនៅក្នុងភូមិ ប៉ុន្តែ ម្តាយរបស់គាត់ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅកាប់

ស្បូវក្រងស្បូវនិងមើលក្មេងៗបាត់ទៅហើយ។ រីឯឪពុករបស់ មឿន បានស្លាប់ដោយសារជំងឺតាំងពីឆ្នាំ១៩៧៥មកម្ល៉េះ។ ថ្ងៃមួយនៅពេលដែល មឿន ដឹកប្រឡាយនៅខាងកើតក្រឡាញ់ ទាំងហេវហត់ និងអាកាសធាតុក្ដៅផងនោះ គាត់ក៏វិលមុខ ប៉ុន្តែ កងឈ្លបខ្មែរក្រហម បានចោទគាត់ថាមានជំងឺសតិអារម្មណ៍ ទៅវិញ។ សំណាងល្អប្រធានកងបានយល់ព្រមហៅពេទ្យមក ជួយព្យាបាលជំងឺគាត់នៅកន្លែងធ្វើការ ព្រោះមានពេទ្យពីរ នាក់នៅប្រចាំការនៅក្នុងកងចល័ត។ គ្រូពេទ្យបានកោសខ្យល់ និងចាក់ថ្នាំឲ្យ មឿន រហូតបានធូរស្បើយ។ នៅពេលជីក ប្រឡាយ និងលើកទំនប់ខាងកើតក្រឡាញ់ ក្រៅពី មឿន ក៏មាន ប្រជាជនមកពីខាងស្រុកអង្គរជុំ និងស្រុកពួក មកលើករួមគ្នា ដែរ។ ដោយមានមនុស្សច្រើនដូច្នេះ បានធ្វើឲ្យ មឿន លែង ខ្វាយខ្វល់ពីទុក្ខលំបាក។ មានប្រជាជនមួយចំនួនបានសុំរាប់ អានគ្នាជាមិត្តភក្តិ។ មឿន បានស្គាល់ មិត្តនារីម្នាក់ឈ្មោះ សួរ មកពីស្រុកអង្គរជុំ ហើយបានរាប់អានគ្នាជាមិត្តភក្តិរហូតមក ដល់ពេលបច្ចុប្បន្ននេះ។

មឿន បានបន្តថា ការហូបចុកនៅទីនោះគ្រប់គ្រាន់។ ខ្មែរ ក្រហមបានបង្កើតសហករណ៍ នៅជិតកន្លែងជីកទំនប់ និងលើក ប្រឡាយតែម្តង ហើយជារៀងរាល់មួយអាទិត្យ ខ្មែរក្រហម បាន ធ្វើបង្អែមដោយបបរសណ្តែកឲ្យហូប។ មឿន បានខិតខំ ធ្វើការ ព្រោះភ័យខ្លាចខ្មែរក្រហមយកទៅរៀនសូត្រ។ អ្នក ដែលធ្វើការជាមួយ មឿន មានបាត់ខ្លួន ជាពិសេសកងចល័ត ដែលធ្វើការជាមួយគ្នា។ មឿន នៅចាំថា មានថ្ងៃមួយខ្មែរ ក្រហមបានយកគ្រួសារកងចល័តដែលធ្វើការជាមួយ គាត់ ទៅបាត់ ហើយខ្មែរក្រហមបានតាមសួររកកូនរបស់គ្រួសារ ដែលនៅរស់ធ្វើការនៅកងចល័តជាមួយ មឿន ទៀត។ ប៉ុន្តែ ប្រធានកងចល័តរបស់ មឿន បានជួយលាក់បាំងមិនឲ្យខ្មែរ ក្រហមដឹង ព្រោះឃើញក្មេងម្នាក់នោះខស្បាហ៍ និងខិតខំធ្វើ ការ។

មឿន បានរំឭកកាលរស់នៅជាមួយម្តាយថា គាត់ឈឺ ចាប់ និងស្រណោះម្តាយពេលមានទម្ងន់ប្អូនពៅ ហើយឃ្លាន ទឹកដូង។ ម្តាយរបស់គាត់បានទៅសុំអង្គការ ហើយបើទោះបី ជាអង្គការឲ្យទឹកដូង តែម្តាយរបស់គាត់ទទួលការស្តីបន្ទោស យ៉ាងខ្លាំង។

មឿន ធ្លាប់បានជីកប្រឡាយខ្នានៅភូមិរបស់ខ្លួន។ នៅ ពេលដែល មឿន ទៅលេងស្រុកកំណើត បានឃើញប្រឡាយ ដែលខ្លួនបានជីកទាំងលំបាកវេទនាកាលពីជំនាន់ខ្មែរក្រហម ហើយឃើញទំនប់នោះ នៅសល់ដល់បច្ចុប្បន្នបានធ្វើឲ្យគាត់ មានភាពរីករាយ។ មឿន ចង្អុលប្រាប់កូនពីទីតាំងប្រឡាយ ដែលខ្លួនបានជីកកាលពីសម័យខ្មែរក្រហម ហើយបានរំឭកថា កាលនោះ ខ្មែរក្រហមបានវាស់ដី១០ម៉ែត្រ ឲ្យមនុស្ស១០នាក់ ជីក រួចហើយខ្មែរក្រហមបានវាស់ឲ្យជីកបន្តទៀត។ មឿន បាន ប្រាប់កូន និងអប់រំកូនសព្វថ្ងៃនេះឲ្យខិតខំព្យាយាម និងធ្វើ រឿងដែលមាន ប្រយោជន៍។

ថ្វីត្បិតតែនៅអន្លង់វែងនេះ ភាគច្រើនសុទ្ធតែជាអតីត យោធា និងកម្មាភិបាលខ្មែរក្រហម រស់នៅយ៉ាងណាក្តី មឿន សប្បាយចិត្តបើប្រៀបធៀបពីការរស់នៅស្រុកក្រឡាញ់ ព្រោះ ងាយ ស្រួលក្នុងការប្រកបរបរចិញ្ចឹមជីវិត ដោយធ្វើស្រែជិត ផ្ទះ ដាំដំណាំជុំវិញផ្ទះ ចិញ្ចឹមសត្វ ថែមទាំង ក្រងស្បូវលក់ ទើបធ្វើឲ្យជីវភាពគ្រួសាររបស់គាត់បានធូរស្រាលមួយកម្រិត។ មឿន បានដើរកាប់ ដើមកក់នៅជិតៗផ្ទះយកមកក្រងដោយ១ កន្ទួប លក់បានតម្លៃ៥០០រៀល ហើយមានឈ្មួញមក ទិញ នៅផ្ទះរៀងរាល់អាទិត្យ។ ក្រៅពីផ្គត់ផ្គង់ជីវភាពគ្រួសារ មឿន បានសន្សំលុយពីការលក់ស្បូវ យកទៅធ្វើបុណ្យនៅវត្ត នៅ ពេលបុណ្យភ្ជុំ ឬចូលឆ្នាំទៀត។ បើទោះបីអន្លង់វែង ជាអតីត តំបន់ខ្មែរក្រហម និងមានគ្រោះថ្នាក់សម្រាប់អ្នកចំណូលថ្មី ប៉ុន្តែឥឡូវតំបន់នេះបានប្រែក្លាយជា ទីកន្លែងរស់នៅសុខសាន្ត សម្រាប់ប្រជាជនដែលបានចំណាក់ស្រុកទៅរស់នៅទីនោះ។ ចំណែកចៅរបស់ មឿន ក៏បានទទួលការអប់រំ ហើយមិនតែ ប៉ុណ្ណោះ មឿន មានបំណងចង់ឲ្យចៅរបស់គាត់រៀនសូត្រ បានខ្ពស់មិនចង់ឲ្យដូចគាត់ដែលមិនបានរៀនសូត្រនោះទេ។

*ដារ៉ារដ្ឋ មេត្តា*

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន៣០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរពីប្រវត្តិសាស្ត្ររឿងរ៉ាវចេញពីភូមិឃុំកំណើត ឬភូមិឃុំដែលខ្លួនកំពុងរស់នៅ ដែលជាប់ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់លោកគ្រូអ្នកគ្រូ នឹងត្រូវបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនលោកគ្រូអ្នកគ្រូវិញដើម្បីប្រើប្រាស់ជាសម្ភារៈឧបទេ្ទសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។






*លក្ខខណ្ឌជ្រើសរើស*

១) អ្នកស្រាវជ្រាវ គឺត្រូវតែជាគ្រូមុខវិជ្ជាប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ កណ្តាល (ស្រុកមុខកំពូល ល្វាឯម និងខ្សាច់កណ្តាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជាការធ្វើបទសម្ភាសន៍, ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួន។

៤) មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសំឡេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

*លក្ខខណ្ឌការងារ*

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ឯកសារយោង កំណត់គោលដៅសម្រាប់សម្ភាសន៍ ការសម្ភាសន៍ វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរពីកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសំឡេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុកនិងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្តីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរចេញពីភូមិកំណើតរបស់ខ្លួន តាមអសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីម៉ែល truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ ០១២ ៦៩៦ ៩៦១ ឬអ៊ីម៉ែល truthrasy.p@dccam.org ៕

# ង៉ែត ខេង អតីតជានារីពេទ្យខ្មែរក្រហម

ស្ត្រីម្នាក់កំពុងអង្គុយវេចនំអន្សមដូងនៅលើគ្រែធ្វើអំពីឈើឫស្សី ស្ថិតនៅក្រោមផ្ទះដំបូលប្រក់ក្បឿងពណ៌ក្រហម និងមានទឹកមុខស្រស់ញញឹមរាក់ទាក់ដាក់ខ្ញុំ បានមានប្រសាសន៍ថា គាត់ឈ្មោះ ង៉ែត ខេង មានអាយុ៥៣ឆ្នាំ ជាអតីតនារីពេទ្យខ្មែរក្រហមនៅភូមិភាគបូព៌ា។ ខេង មានស្រុកកំណើតនៅភូមិព្រះធាតុ ឃុំលាយបូរណ៍ ស្រុកត្រាំកក់ ខេត្តតាកែវ។ សព្វថ្ងៃ ខេង រស់នៅឃុំថ្នាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ខេង មានឪពុកឈ្មោះ ដែន (ស្លាប់) និងម្តាយឈ្មោះ សួន នាង។ ខេង គឺជាកូនទី៦នៅក្នុងចំណោមគ្រួសារដែលមានបងប្អូនបង្កើតចំនួនប្រាំពីរនាក់ ស្រី២ និងប្រុស៥នាក់។

កាលពីក្មេង ខេង រៀនបានបន្តិចបន្តួច ហើយក៏មកជួយធ្វើការងារឪពុកម្តាយវិញ រហូត មកដល់ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខណៈពេលដែលយោធាខ្មែរក្រហមទទួលជ័យជម្នះទាំង ស្រុង។ ក្រុមគ្រួសាររបស់ ខេង ត្រូវបានយោធាខ្មែរក្រហមជម្លៀសទៅនៅម្តុំភ្នំជំរីរមៀល ស្ថិតក្នុងស្រុកជុំគិរី ខេត្តកំពត ដែលមានព្រំប្រទល់ជាប់ស្រុកត្រាំកក់ ខេត្តតាកែវ។ ខេង បានចងចាំថា កាលពីគាត់អាយុប្រហែល១២ឆ្នាំ គណៈឃុំបានមកជ្រើសរើសកុមារឲ្យចូលធ្វើពេទ្យព្យាបាលអ្នកជំងឺ។ គាត់ក៏ត្រូវបានអង្គការជ្រើសរើស និងបញ្ជូនមកឲ្យធ្វើពេទ្យនៅស្រុកត្រាំកក់ ភូមិភាគនិរតី។


ង៉ែត ខេង

នៅទីនោះ ខេង ត្រូវបានអង្គការចាត់តាំងឲ្យទទួលខុសត្រូវក្នុងការព្យាបាលអ្នកជំងឺទូទៅ។ ខេង បានមានប្រសាសន៍ថា ចំពោះថ្នាំពេទ្យ និងសេរ៉ូម គឺខាងអង្គភាពស្រុកបញ្ជូនមកឲ្យពេទ្យដើម្បីយកទៅព្យាបាលឲ្យអ្នកជំងឺ និងប្រជាជនជាទូទៅ។

នៅមន្ទីរពេទ្យស្រុកត្រាំកក់បានមួយរយៈ ខេង ត្រូវបានអង្គការបញ្ជូនមកធ្វើការនៅពេទ្យមជ្ឈិមក្នុងក្រុងភ្នំពេញវិញ។ ខេង បានធ្វើដំណើរដោយជិះឡានមកភ្នំពេញជាមួយនារីពេទ្យជាច្រើននាក់ទៀត។ នៅទីនោះ អង្គការចាត់តាំងឲ្យ ខេង ឲ្យមើលថែទាំអ្នកជំងឺ រុំរបួសឲ្យអ្នកជំងឺ និងសង្កេតមើលពេលអ្នកជំងឺក្តៅខ្លួនត្រូវចាក់ថ្នាំ និងឲ្យថ្នាំទៅអ្នកជំងឺលេប។ ក្រៅពីក្តៅខ្លួន អ្នកជំងឺខ្លះឈឺរាគ ដូច្នេះ ខេង ត្រូវដាក់សេរ៉ូមឲ្យអ្នកជំងឺទៀត។ ក្រៅពីការងារដែលបានរៀបរាប់ខាងលើ ខេង ក៏ទទួលខុសត្រូវផ្នែកលាងរបួសឲ្យយោធាខ្មែរក្រហមរងរបួសដែលអង្គភាពយោធា ដឹកទាំងឡានៗយកមកព្យាបាលនៅក្នុងមន្ទីរពេទ្យ។ ខេង បានរំឭកថា ដោយសារគាត់នៅក្មេង ដូច្នេះ ពេលសម្រាកពីការងារគាត់បាននាំគ្នារត់ប្រលែងគ្នាលេងជាមួយសមាជិកពេទ្យដែលមានវ័យប្រហាក់ប្រហែលគ្នា ដោយស្លៀកខោខ្លីតែប៉ុណ្ណោះ។

ក្រោយមក ខេង ត្រូវបានប្រធានមន្ទីរពេទ្យចាត់តាំងឲ្យទទួលខុសត្រូវព្យាបាលអ្នកជំងឺមួយអគារ ដោយមានសមាជិក

មួយក្រុមចំនួន១០នាក់ ហើយនៅពេលយប់ប្រធានមន្ទីរពេទ្យបានចាត់តាំងខេងនិងសមាជិកក្រុមទទួលខុសត្រូវយាមពេលយប់ទៀតៗ នៅពេលព្រឹកពេលដែលអ្នកជំងឺក្រោកឡើង ខេងត្រូវលាង និងសម្អាតរបួសអ្នកជំងឺទាំងនោះដែលជាការងារប្រចាំថ្ងៃៗ

នៅឆ្នាំ១៩៧៨ ខេងត្រូវបានអង្គការផ្លាស់ពីពេទ្យមជ្ឈិមឲ្យទៅធ្វើការនៅខេត្តកំពង់ចាម ភូមិភាគបូព៌ាៗ ខេង បានបន្តថា «ខ្ញុំបានចាប់ផ្ដើមធ្វើដំណើរចេញពីទន្លេបួនមុខនៅមុខវាំងដោយជិះកាណូត រួមជាមួយសមាជិកចំនួនប្រហែល៣០នាក់ទៀត»ៗ ខេង បានបន្តថា ការធ្វើដំណើរត្រូវចំណាយពេញមួយថ្ងៃ ទើបបានទៅដល់ស្រុកសួង ខេត្តកំពង់ចាមៗ ពេលមកដល់ដំបូងសមាជិកក្នុងអង្គភាពពេទ្យទាំងអស់ ត្រូវបានអង្គការបែកផ្ទះឲ្យស្នាក់នៅតាមក្រុមរៀងៗខ្លួនៗ

បន្ទាប់មក ខេង ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរពេទ្យចុងក្រង ដោយគាត់មានតួនាទីលាងសម្អាតរបួស ចាក់ថ្នាំឲ្យយោធាខ្មែរក្រហមការពារព្រំដែន ដែលរងរបួសៗ

នៅចុងឆ្នាំ១៩៧៨ ខណៈពេលដែលកងទ័ពវៀតណាមវាយប្រយុទ្ធជាមួយយោធាខ្មែរ ក្រហមនៅតាមព្រំដែន ក្នុងខេត្តកំពង់ចាម ខេង និងសមាជិកក្នុងអង្គភាពពេទ្យនៅក្នុងស្រុកសួងដដែលៗ រហូតដល់ដើមឆ្នាំ១៩៧៩ ខណៈពេលដែលកងទ័ពវៀតណាមបានចូលមករំដោះទាំងស្រុង ខេង និងសមាជិកក្នុងអង្គភាពទាំងមូល បានរត់គេចខ្លួនទាំងអស់ៗ ក្រោយមក ខេង បានសម្រេចចិត្តរត់ឡើងភ្នំដងរែកតាមច្រក ១០០៣ ដែលគ្រប់គ្រងដោយ តាម៉ុក និងបានរស់នៅលើភ្នំមួយរយៈ ដើម្បីគេចចេញពីកងទ័ពវៀតណាមៗ រហូតដល់សភាពការណ៍វាយប្រយុទ្ធគ្នារវាងកងយោធាខ្មែរក្រហម និងវៀតណាម បានស្ងប់ស្ងាត់ ខេង ក៏សម្រេចចិត្តចុះមករស់នៅឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យៗ សព្វថ្ងៃ ខេង ប្រកបមុខរបរធ្វើស្រែ និងចម្ការៗ **សុិន សុធីតា**



ទិដ្ឋភាពផ្លូវ និងផ្ទះរបស់ប្រជាជនរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

# វេទិកាថ្នាក់រៀន ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យនៅកម្ពុជា (១៩៧៥-១៩៧៩)

នៅរសៀលថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំជាវេទិកាថ្នាក់រៀនមួយស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោង ដែលមានទីតាំងនៅភូមិសំរោងខាងជើងសង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដោយមានការចូលរួមពីសិស្សានុសិស្សថ្នាក់ទី១២ ចំនួន ៥០នាក់។

នេះគឺជាវេទិកាថ្នាក់រៀនលើកទី៣៤ ដែលជាវេទិការថ្នាក់រៀន ចុងក្រោយដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំឡើងនៅក្នុងរាជធានីភ្នំពេញ។ វេទិកាថ្នាក់រៀននេះ បានរៀបចំឡើងក្នុងគោលបំណង ដើម្បីបង្កើតចំណេះដឹងប្រវត្តិសាស្ត្រ ជួយជំរុញឲ្យមានការចងចាំ ការការពារកុំឲ្យមានអំពើប្រល័យពូជសាសន៍កើតមានឡើងម្តងទៀត ការបណ្តុះឲ្យមានការគិតពិចារណាទៅលើប្រវត្តិសាស្ត្រ និងដើម្បីឲ្យសិស្សានុសិស្សពិភាក្សាគ្នាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលខ្លួនបានដឹង និងបានរៀនសូត្រកន្លងមក។

នៅក្នុងវេទិកាថ្នាក់រៀននេះ លោក ផេង ពង្សរ៉ាស៊ី នាយកនៃកម្មវិធីស្រាវជ្រាវ និងអប់រំអំពីប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើបទបង្ហាញអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមដល់សិស្សទាំងអស់ដែលបានចូលរួម និងបានចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចំនួន៦០ក្បាល និងឯកសារមេរៀនពីរបបកម្ពុជាប្រជាធិបតេយ្យ ទៅដល់សិស្សទាំងអស់ក្នុងកម្មវិធីវេទិកាថ្នាក់រៀនទៀតផង។

លោក វ៉េត វ៉ាន់ ជានាយកវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោងបានលើកឡើងថា លោកពិតជាមានភាពសប្បាយរីករាយ និងពេញចិត្តដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនដល់វិទ្យាល័យរបស់លោក។ វ៉ាន់ បានបន្តថា ទាំងនេះជាការចែករំលែកបទពិសោធន៍ពីខ្មែរក្រហមកមដល់ក្មេងជំនាន់ក្រោយដែលមិនបានដឹង និងឆ្លងកាត់។ វ៉ាន់ បានបន្ថែមថា ដោយសារមជ្ឈមណ្ឌលឯកសារកម្ពុជាមានជំនាញក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហម និងមានឯកសារដែលអាចឲ្យជឿទុកចិត្តបាន ដូច្នេះអាចធ្វើឲ្យសិស្សជឿជាក់កាន់តែច្បាស់ថា របបខ្មែរក្រហមពិតជាកើតឡើងប្រាកដមែន។ របបខ្មែរកក្រហមគឺជាប្រវត្តិសាស្ត្រមួយដែលក្មេងជំនាន់ក្រោយត្រូវតែដឹង និងចងចាំ។ វ៉ាន់ និង គ្រួសារត្រូវបានខ្មែរក្រហមជម្លៀសទៅកាន់


លោក វ៉េត វ៉ាន់ នាយកវិទ្យាល័យសម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុនសែន សំរោង

ខេត្តពោធិ៍សាត់នៅដើមឆ្នាំ១៩៧៦។ វ៉ាន់ បានបាត់បង់ឪពុក និងបងប្រុសម្នាក់នៅក្នុងរបបខ្មែរក្រហម។ ចាប់តាំងពីជម្លៀសទៅពោធិ៍សាត់ វ៉ាន់ មិនដែលបាននៅជាមួយម្ដាយទេ។ នៅពេលដែលគាត់នឹកដល់ឪពុកម្ដាយ និងបងប្អូន ហើយចង់ទៅលេងក៏ខ្មែរក្រហមមិនអនុញ្ញាតឲ្យគាត់ទៅដែរ។ វ៉ាន់ បានមានប្រសាសន៍ថា ទាំងនេះជាការធ្វើបាបផ្លូវចិត្ត និងបំបិទសិទ្ធិសេរីភាព។ វ៉ាន់ បានរំឭកថា រាល់ថ្ងៃគាត់ធ្វើការអស់កម្លាំងយ៉ាងខ្លាំង និងទទន់ជើងស្ទើរដើរពុំរួច។ ថ្ងៃមួយនៅពេលកំពុងធ្វើការ វ៉ាន់ បានសុំខ្មែរក្រហមទៅបត់ជើងតូចគ្ម ឥឡូវ គ្មាន។

ផ្លូន ពេជ្ឈរាម ភេទប្រុស អាយុ១៨ឆ្នាំ ជាសិស្សថ្នាក់ទី១២«A» នៃវិទ្យាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោង បាននិយាយថា ខ្លួនពិតជាមានការសប្បាយចិត្តយ៉ាងខ្លាំង នៅពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានមកបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលធ្វើឲ្យសិស្សយល់កាន់តែច្បាស់ពីរបបនេះ។ ពេជ្ឈរាម ធ្លាប់បានស្ដាប់ឪពុកនិយាយពីរបបខ្មែរក្រហមដ៏ឃោរឃៅ ហើយនៅពេលចូលរួមវេទិកាថ្នាក់រៀនធ្វើឲ្យខ្លួនក៏នឹកឃើញដល់រឿងរ៉ាវឪពុកដែលជាជនរងគ្រោះធ្លាប់ឆ្លងកាត់របបនេះដែរ។ នៅពេលស្ដាប់រឿងឪពុក បាននិយាយប្រាប់ធ្វើ ពេជ្ឈរាម មានសេចក្ដីអាណិតអាសូរឪពុកយ៉ាងខ្លាំង។ ទោះបីយ៉ាងណា ពេជ្ឈរាម មិនស្អប់គុំគួនចំពោះកម្មាភិបាលខ្មែរក្រហមទេ ប៉ុន្តែខ្លួននៅតែមិនសប្បាយចិត្ត ដែលកម្មាភិបាលខ្មែរក្រហមបានធ្វើបាបប្រជាជនខ្មែរ។ ពេជ្ឈរា ចង់ឲ្យប្រជាជនខ្មែរមានការសាមគ្គីគ្នា និងទប់ស្កាត់កុំឲ្យមានរបបនេះកើតឡើងម្ដងទៀត ហើយខ្លួនសប្បាយចិត្តយ៉ាងខ្លាំង ពេលឃើញប្រជាជនកម្ពុជាចេះអន់ទិន។

សោមាស ភេទស្រី អាយុ១៩ឆ្នាំ ជាសិស្សថ្នាក់ទី១២«A» នៃវិទ្យាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោង បានរៀបរាប់ថា វាគឺជាឱកាសល្អដែលមជ្ឈមណ្ឌល



សិស្សវិទ្យាល័យសម្ដេច អគ្គមហាសេនាបតីតេជោ ហ៊ុនសែន សំរោង កំពុងបំពេញសំណួរស្ទាបស្ទង់មតិស្ដីពីការយល់ដឹងពីរបបខ្មែរក្រហម មុននឹងចាប់ផ្ដើមវេទិកាថ្នាក់រៀនស្ដីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

ឯកសារកម្ពុជាបានមកបង្កើតវេទិកាថ្នាក់រៀននេះឡើង ព្រោះបានធ្វើឲ្យសិស្សយល់ដឹងពីប្រវត្តិសាស្ត្រឈឺចាប់ ហើយអាចជៀសវាងកុំឲ្យប្រវត្តិសាស្ត្រនេះត្រឡប់មកវិញម្តងទៀត។ មាស ធ្លាប់បានស្តាប់រឿងរ៉ាវរបស់ម្តាយឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ មាស មានចិត្តអាណិតម្តាយរបស់ខ្លួននៅពេលដែលកម្មាភិបាលខ្មែរក្រហមបំបែកម្តាយខ្លួនចេញពីយាយ និងបងប្អូន។ មាស ខឹងចំពោះទង្វើអតីតកម្មាភិបាលខ្មែរក្រហមដែលធ្វើឲ្យប្រជាជនរងទុក្ខវេទនា និងស្លាប់យ៉ាងច្រើន។ ប៉ុន្តែ មាស មិនបានគុំគួនកម្មាភិបាលខ្មែរក្រហមនោះទេ។ មាស ក៏មិនខឹងឬស្អប់ខ្ពើម ចំពោះកូនអតីតកម្មាភិបាលខ្មែរក្រហមដែរ។ មាស បានលើកឡើងថា តាមរយៈការអប់រំនិងទប់ស្កាត់អំពើហិង្សាយើងអាចទប់ស្កាត់មិនឲ្យរបបនោះ កើតឡើងសាជាថ្មីម្តងទៀត។

ឆោម ចាន់ឌី ភេទស្រី អាយុ១៨ឆ្នាំ ជាសិស្សថ្នាក់ទី១២ «A» វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោង។ ចាន់ឌី ធ្លាប់បានដឹងរឿងរ៉ាវដែលបានកើតឡើងចំពោះប្រជាជនកម្ពុជា។ លោកយាយរបស់ ចាន់ឌី មានអាយុ៧៨ឆ្នាំ ធ្លាប់បាននិយាយប្រាប់អំពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់ និងគ្មានអាហារហូបចុកគ្រប់គ្រាន់ ចំណែករបស់របរផ្ទាល់ខ្លួនក៏មិនអាចប្រើប្រាស់បានដែរ។ ចាន់ឌី មានការអាណិតចំពោះប្រជាជនកម្ពុជាស្លូតត្រង់ ដែលត្រូវបានខ្មែរ-ក្រហមគាបសង្កត់និងធ្វើបាប ហើយសូម្បីតែកុមារក៏ត្រូវបានបង្ខិតបង្ខំឲ្យធ្វើការដែរ។ ចាន់ឌី បន្តថា លោកយាយរបស់ខ្លួនបានរត់គេចពីគ្រាប់ផ្លោង និងលួចរបស់របរអន្តការដែលចាត់ទុកជារបស់សមូហភាពហូបដើម្បីបានរស់ជីវិត។ ចាន់ឌី បាននិយាយថា «ខ្ញុំមានការកោតសរសើរចំពោះលោកយាយដែលអាចឆ្លងផុតពីរបបនេះ ហើយបាននិយាយពីព្រឹត្តិការណ៍ទាំងនោះប្រាប់ដល់ចៅ»។

ប្រវត្តិវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោង

មុននឹងឈានដល់ការបង្កើតវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោង ជាវិទ្យាល័យមួយដែលនៅជាយទីក្រុងភ្នំពេញដែលបានកាត់ចេញពីស្រុកពញាឮ ខេត្តកណ្តាល។ សាលានេះក៏បានឆ្លងកាត់នូវដំណាក់កាលតាមបត់នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ១៩៥៩ ក្រសួងបានបង្កើតសាលាបឋមសិក្សាមួយឈ្មោះថា សាលាបឋមសិក្សាសំរោងខាងជើង ស្ថិតក្រោមការផ្តួចផ្តើមរបស់ព្រះចៅអធិការវត្ត ព្រះនាម កុយ ប៉ុក។ លុះមកដល់ឆ្នាំ១៩៧០-១៩៧៩ ប្រទេសកម្ពុជាស្ថិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ សង្គ្រាម និងការបំផ្លិចបំផ្លាញ សាលាត្រូវបានបិទទ្វារលែងបានទទួល កុមារ៉ា-កុមារី ឲ្យចូលរៀន។ ក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ ដោយយល់ឃើញពីតម្រូវការរបស់ប្រជាជន និងភាពចាំបាច់នៃការអប់រំ ប្រជាជននៅក្នុងតំបន់បាននាំគ្នាខិតខំប្រឹងប្រែងក្នុងការជួសជុលសាលាចាស់ និងជញ្ជាំងធ្វើអំពីដើមកក់ ដែលមាន៣បន្ទប់ ចំណែកសិស្សមួយចំនួនទៀតបានរៀននៅលើសាលាឆាន់របស់វត្តសំរោងខាងជើង ដែលមានចំនួន៥បន្ទប់។ ក្នុងនោះមានសិស្សសរុបចំនួន៤៧៥នាក់ និងមានសិស្សស្រី២២៧នាក់ និងមានគ្រូបង្រៀន៨នាក់ ស្ថិតនៅក្រោមការដឹកនាំរបស់លោកនាយកសាលា ក្រូច ស៊ីណយ។ លោកនាយក ក្រូច ស៊ីណន បម្រើការបានពីរឆ្នាំ ក៏ប្តូរទៅបម្រើការនៅមន្ទីរអប់រំស្រុក។ នៅឆ្នាំ១៩៨១ លោក ឡៅ លឹម ត្រូវបានជ្រើសរើសឲ្យធ្វើជានាយកសាលាបន្តដោយមានលោក ខៀវ វ៉ាន់ ជានាយករង។ នៅឆ្នាំ១៩៩៧ សម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសាងសង់អគារពីរខ្នង ស្មើនឹង១០បន្ទប់បន្ថែមទៀត។

នៅក្នុងឆ្នាំ២០០០ដោយចំនួនសិស្សសាលាកើនឡើងជាលំដាប់ និងដើម្បីបំពេញតម្រូវការរបស់អាណាព្យាបាលសិស្ស និងផលពិបាកក្នុងការធ្វើដំណើរ សាលាបឋមសិក្សាឃុំសំរោង ត្រូវបានបែងចែកជា ៣មានះ សាលាបឋមសិក្សាវត្តគ្រួស សាលាបឋមសិក្សាសំរោងកណ្តាលនិងសាលាបឋមសិក្សាសំរោងជើង មានលោក ខៀវ អៃ ជានាយក និងលោក

ណាំ សុខ ជានាយករង។ នៅក្នុងឆ្នាំ២០០១ ព្រះតេជគុណ ណយ ច្រឹក ជាព្រះចៅអធិការវត្តច័ន្ទបុរីវង្ស បានដួសជុល អគារមួយខ្នងមាន៣បន្ទប់។ នៅឆ្នាំ២០០៥-២០០៦ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយឲ្យមានអនុវិទ្យាល័យតាមឃុំ ទើបលោកនាយកសាលាបឋមសិក្សាសំរោងបានបង្កើតអនុវិទ្យាល័យក្នុងឃុំសំរោង មានថ្នាក់ទី៧ មានអគារមួយខ្នងមាន៥បន្ទប់ មានសិស្សសរុបចំនួន២៦២នាក់ក្នុងនោះមានស្រី៥៧នាក់ និងមានគ្រូចំនួន៥នាក់។ លោកនាយកសាលាយល់ឃើញថា ពីដើមឡើយប្រជាជននៅក្នុងតំបន់នេះមិនមានប្រជាជនបានរៀនសូត្រជ្រៅជ្រះនោះទេ ហើយលោកយល់ឃើញថានៅក្នុងតំបន់នេះអាចបង្កើតជាវិទ្យាល័យបាន ព្រោះមានសាលាចំណុះច្រើន តែមិនមានវិទ្យាល័យ ដូចជា ព្រែកតាទែន ជ្រៃលាស់ ត្របាំងព្រាយ ភូមិធំ និងព្រែកព្នៅ។ លោកបានធ្វើផែនទីសម្រាប់សិក្សាឃើញថា មានច្រើនភូមិដែលអាចបង្កើតទៅជាវិទ្យាល័យបាន ក៏បានស្នើទៅសម្តេចសង្ឃនាយករងទី៣ ណយ ច្រឹក ជួយស្នើទៅសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ នៅឆ្នាំ២០០៧-២០០៨ សាលានេះបានប្តូរមកជាវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោង។

ឆ្នាំ២០១២-២០១៣ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោង មានអគារ៤ខ្នង មាន២៧បន្ទប់ ទីចាត់ការ១ខ្នង ៤បន្ទប់ អគារកាត់ដេរ១ខ្នង ៣បន្ទប់។ ដោយមានសិស្សសរុបចំនួន៩២០នាក់ និងស្រី៤០៧នាក់។ បុគ្គលិក ៧៦នាក់ និងស្រី២០នាក់។ ឆ្នាំ២០១៧-២០១៨ វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សំរោងមានអគារ៧ខ្នង ស្មើ៣៧បន្ទប់ ដោយមានសិស្សសរុបចំនួន៧៨៨ នាក់ សិស្សស្រី៣៨៤នាក់ និងមានចំនួន១៦ថ្នាក់ មាន៖ ទី៧ មាន៤ថ្នាក់ ទី៨មាន៣ថ្នាក់ ទី៩មាន២ថ្នាក់ ទី១០មាន៣ថ្នាក់ ទី១១មាន២ថ្នាក់ និងទី១២មាន២ថ្នាក់។

ដារ៉ារដ្ឋ មេត្តា


ទិដ្ឋភាពទីធ្លាវិទ្យាល័យសម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុនសែន សំរោង

# ឪពុកម្តាយរបស់ សន ត្រូវបានសម្លាប់ដោយសារមិនពេញចិត្ត ខ្មែរក្រហមប្រមូលសេះ ដំរី ដាក់ជារបស់រួម

ញាប សន មានឪពុកម្តាយជាជនជាតិព្នង រស់នៅក្នុងខេត្តមណ្ឌលគិរី។ សន នៅចាំថា ឪពុកម្តាយរបស់គាត់បានខឹងយ៉ាងខ្លាំងនៅពេលដែលខ្មែរក្រហម បានមកប្រមូលគោក្របី សេះ ដំរី ដែលខ្លួនខំចិញ្ចឹមដើម្បីទុកចែកឲ្យកូនៗ ដាក់ជារបស់រួម។ ឪពុកម្តាយរបស់ សន ត្រូវបានខ្មែរក្រហមយកទៅសម្លាប់។ សន មានអាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតភូមិពូទីត ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ហើយបច្ចុប្បន្នគាត់រស់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សន មានឪពុកឈ្មោះ ញាប ញាន និង ម្តាយឈ្មោះ លេ ហ្លួល។ សន ជាកូនបងគេបង្អស់នៅក្នុងគ្រួសារ ហើយមានបងប្អូនបង្កើតចំនួនបីនាក់។ នៅក្នុងឆ្នាំ១៩៧៥ សន បានរៀបការជាមួយឈ្មោះ បឿន ញ៉ ហើយរស់នៅស្រុកកោះញែក ជាមួយគ្នា និងមានកូនពីរនាក់ ស្រីមួយ និងប្រុសមួយ។ នៅឆ្នាំ១៩៩២ សន មានប្រពន្ធទី២ ជាជនជាតិព្នង ដែលមានកូនប្រាំនាក់ ប្រុសបួននាក់ និងស្រីមួយនាក់។


ញាប សន នៅផ្ទះក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

នៅឆ្នាំ១៩៧០ សន បានចូលរួមចលនាតស៊ូខ្មែរក្រហមខាងផ្នែកសិល្បៈនៅក្នុងព្រៃ ដោយមានឈ្មោះ យ៉ោ យឹម និងសុខុត ជាប្រធាន។ សន បានស្នាក់នៅស្រុកកោះញែក និងបានបើកវគ្គបំពាក់បំប៉ន អប់រំផ្នែកតស៊ូនយោបាយដល់ប្រជាជននៅទីនោះ។ សន បានបញ្ចុះបញ្ចូលប្រជាជន ដឹកនាំប្រជាជនឲ្យចេះសាមគ្គីដើម្បីរំដោះជាតិ ចេះជួយទំនុកបម្រុងគ្នាទៅវិញទៅមក នៅពេលដែលស្ថិតនៅក្នុងស្ថានភាពលំបាក។ ក្រុមសិល្បៈរបស់ សន ដែលមានសមាជិក ២០ ទៅ ៣០ នាក់ តែងតែជួយប្រជាជននៅពេលជួបទុក្ខលំបាកជានិច្ច។

នៅឆ្នាំ១៩៧៣ នៅពេលដែលខ្មែរក្រហមគ្រប់គ្រងភូមិអូរយេះ ឃុំស្រែសង្គម ស្រុក កោះញែក ខ្មែរក្រហមបានប្រមូលទ្រព្យសម្បត្តិរបស់ប្រជាជនក្នុងភូមិ ដាក់ជាកម្មសិទ្ធិរួម។ ឪពុក ម្តាយរបស់ សន មិនសប្បាយចិត្តទេ ព្រោះខ្មែរក្រហមបានប្រមូលយកក្របី៥ក្បាល ដំរី៥ក្បាល និងសេះ២ក្បាល ដែលគាត់ចិញ្ចឹមទុកសម្រាប់ចែកឲ្យកូនៗតាមប្រពៃណីជនជាតិព្នង ទៅដាក់ជា សម្បត្តិរួម។ ការប្រមូលសម្បត្តិដាក់ជារបស់រួមរបស់ខ្មែរក្រហមនេះបានធ្វើឲ្យសននិងឪពុកម្តាយមានការទាស់ទែងគ្នា។ សន បានព្យាយាមមកពន្យល់ឪពុកម្តាយរបស់គាត់ពីមាគ៌ាដឹកនាំ របស់ខ្មែរក្រហម ប៉ុន្តែឪពុកម្តាយរបស់គាត់នៅតែមិនពេញចិត្តនឹងទង្វើរបស់ខ្មែរក្រហម។

ឪពុក ម្តាយរបស់ សន ថែមទាំងស្អប់ សន ដែលបានជួយដើរបញ្ចុះបញ្ចូលប្រជាជនឲ្យចូលរួមខ្មែរ ក្រហម។ ក្រៅពីដំរី សេះ គោ ក្របី ដែលខ្មែរក្រហមប្រមូលយកទៅដាក់រួម ឪពុកម្តាយរបស់ សន បានយកទ្រព្យសម្បត្តិដែលគាត់មានដូចជាខ្សែកមាសមួយខ្សែ យកទៅបោះចោលក្នុងទឹកអូរច្បារដោយមិនទុកឲ្យខ្មែរក្រហមឡើយ។ ចាប់តាំងពីពេលនោះមក ឪពុកម្តាយ សន មានជំងឺបាក់ទឹកចិត្ត ហើយក្រោយមកខ្មែរក្រហមបានយកគាត់ទាំងពីរទៅសម្លាប់ចោល។ សន បានសោកស្តាយនិងស្រណោះឪពុកម្តាយយ៉ាងខ្លាំង។ សន មិនអាចតវ៉ាជាមួយខ្មែរក្រហមបានទេ ព្រោះខ្មែរក្ររហមបានប្រាប់គាត់ថា អ្នកណាដែលគាត់អាចកែប្រែបានគឺកែប្រែ តែបើអ្នកណាដែលគាត់កែប្រែមិនបាន គឺទុកឲ្យអង្គការជាអ្នកកែប្រែ។ បន្ទាប់ពីសម្លាប់ឪពុកម្តាយ សន រួចមក ខ្មែរក្រហមក៏ចាប់ប្អូនបង្កើតរបស់ម្តាយ សន យកទៅសម្លាប់បន្តទៀត។ ចំណែក សន ក៏ស្ថិតនៅក្នុងការសង្ស័យពីសំណាក់ខ្មែរក្រហមដែរ។

ក្រោយមក សន ត្រូវបានចាត់តាំងឲ្យមើលគោក្របីប្រមាណ១៥០ក្បាល រួមជាមួយក្មេងៗ ១០នាក់ទៀត។ ក្រៅពីនោះ មានតា៨នាក់ ជាអ្នកវេញខ្សែគោក្របី។ រៀងរាល់ថ្ងៃ សន បានចេញទៅឃ្វាលគោនៅម៉ោង១១ បន្ទាប់ពីគាត់ និងកុមារៗចេញពីរៀន និងហូបបាយថ្ងៃរួច។ បន្ទាប់ពីឃ្វាលគោឲ្យស៊ីស្មៅរួច នៅម៉ោង៣រសៀល សននិងកងកុមារបានដេញគោក្របីឲ្យចូលក្រោលវិញ។ ក្រោយពីសម្រាកពីការឃ្វាលគោ នៅម៉ោង៥ល្ងាច សន ត្រូវទៅធ្វើការដកស្ទូង បន្តទៀតរហូតដល់ម៉ោង៩យប់ទើបបានឈប់សម្រាក។

នៅឆ្នាំ១៩៧៨ បន្ទាប់ពីមានការទុកចិត្តពីខ្មែរក្រហម សន ត្រូវបានចាត់តាំងឲ្យគ្រប់គ្រងប្រជាជន១០គ្រួសារ ដោយក្នុងមួយគ្រួសារមានសមាជិកប្រហែលជាពីរទៅបីនាក់។ សន បានចាត់តាំងឲ្យប្រជាជនទាំង១០គ្រួសារ កាប់ដើមឫស្សីមកបិតធ្វើជាចម្រូង។ ចម្រូងទាំងអស់នោះធ្វើឡើងសម្រាប់ដាក់តាមបណ្តោយព្រំដែនវៀតណាម ដែលមាន តាឡេង និង តាផ្អិត ជាអ្នកគ្រប់គ្រង។ ចម្រូងដែលប្រជាជនបិតរួច ប្រជាជនត្រូវរៀបចំ និងរាប់ឲ្យគ្រប់ចំនួន ដោយក្នុងមួយដុំមានមានចម្រូង១០០ដើម និងចងជាបាច់បញ្ជូនទៅដាក់ម្តុំបន្ទាប់មកទើបមានកងផ្សេងមកទទួលយកទៅ។


សាលាឆាន់នៅវត្តរតនៈមណ្ឌលរង្សី ក្នុងភូមិស្រែសង្គម ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគីរី ឆ្នាំ២០១៦

នៅឆ្នាំ១៩៧៥ សន បានចូលរួមធ្វើផ្លូវកាត់តាមព្រៃអូរក្រាក់ អូរគ្រេញ អូរទូក អូរក្រោល។ នៅតាមផ្លូវ សន បានឃើញសត្វព្រៃ ដូចជា ដំរី សត្វខ្លា ប្រើស ទន្សោង ជាច្រើន។ ផ្លូវចេញពីខេត្ត ក្រចេះ ទៅមណ្ឌលគិរី នៅពេលនេះ ខ្មែរក្រហមប្រើសម្រាប់រថយន្តដឹកស្បៀងឲ្យកងទ័ព ខ្មែរក្រហមដែលគ្រប់គ្រងដោយ តាឈិន (ប្រធានកងពល៩២០ ភូមិភាគឦសាន) និង តាសយ ជាអនុប្រធានកងពល។ ចំណែក សន ស្ថិតនៅក្នុងកងពលតំបន់១០៥ (ស្រុកកោះញ៉ែក) ដោយមាន តាឡាំង ជាគណៈតំបន់១០៥។ បន្ទាប់ពីខ្មែរក្រហមវាយដណ្តើមបានទីក្រុងភ្នំពេញ សន បានចូលធ្វើការជាយោធាតំបន់។ សន មិនបានចូលប្រយុទ្ធនៅសមរភូមិជាមួយសត្រូវទេ គឺគាត់ ជាអ្នកដាំបាយឲ្យ តាឡេង នៅខាងមន្ទីរ។ នៅឆ្នាំ១៩៧៦ ឈ្មោះ ឃឹត ធ្វើការនៅខាងកំពង់ផែក្រចេះ ជាអ្នកភូមិជាមួយ សន បាននាំ សន ទៅធ្វើការនៅជាមួយ ហើយបានប្រគល់ភារកិច្ចឲ្យទទួលខុសត្រូវក្នុងការជ្រើសយកកម្លាំងនារីចូលធ្វើការ និងមើលការខុសត្រូវនៅពេលដែលកម្មករ កំពង់ផែមានបញ្ហា ឬមានជំងឺ។ នៅកំពង់ផែមានកងលីសែងប្រមាណជា៦០នាក់ ប្រុស ៣០ និងនារី៣០នាក់។ កំពង់ផែក្រចេះបានទទួល និងផ្ទេរទំនិញដែលដឹកមកពីមុខវាំង ក្នុងក្រុងភ្នំពេញ មកខេត្តក្រចេះ រួចដឹកបន្តពីខេត្តក្រចេះ ទៅខេត្តមណ្ឌលគិរី ដោយមានឈ្មោះ រ៉ា ជាប្រធានសេដ្ឋកិច្ចកំពង់ផែទទួលខុសត្រូវ។ ទំនិញដែលខ្មែរក្រហមដឹកទៅនៅខេត្តមណ្ឌលគិរី គឺត្រូវយកទៅដាក់ឃ្លាំង១០៥ ដែលមានឈ្មោះ វន ជាអ្នកគ្រប់គ្រង។

នៅក្នុងឆ្នាំ១៩៧៧ សន បានផ្លាស់ពីការងារកំពង់ផែ ទៅធ្វើការងារនៅសហករណ៍វិញ ព្រោះគាត់សង្កេតឃើញមានបាត់ខ្លួនមនុស្សច្រើន។ ក្នុងពេលមកធ្វើការនៅសហករណ៍ សន បានធ្វើពុតជាឈឺ ដើម្បីបានឈប់សម្រាកពីការងារ។ នៅទីនោះ សន បានឃើញខ្មែរក្រហមដឹក ប្រជាជនចេញពីភូមិទាំងឡានៗ តែ សន មិនដឹងថាដឹកយកទៅទីកន្លែងណានោះទេ។ អ្នកដែលបាត់ខ្លួនភាគច្រើនជាប្រជាជន និងយោធាដែលគ្រប់គ្រងភូមិអូរយេះ។ ប្រសិនបើយោធាគ្រប់គ្រងភូមិត្រូវអង្គការចាប់ខ្លួនហើយប្រជាជនក៏បាត់ខ្លួនទៅជាមួយដែរ។

នៅចន្លោះពីឆ្នាំ១៩៧៨ ដល់ឆ្នាំ១៩៧៩ ប្រជាជនមិនមានអាហារហូបគ្រប់គ្រាន់នោះទេ។ នៅថ្ងៃ២៥ ខែធ្នូ ឆ្នាំ១៩៧៨ វេលាម៉ោង៧ព្រឹក សន បានឃើញមនុស្សចម្លែកម្នាក់ ពាក់ស្បែកជើងផ្ទាត់ ស្លៀកខោខ្លី អាយុខ្ទង់សាមសិបឆ្នាំ ហាក់ដូចជាមកយកការណ៍ បានមកសួរ សន ធ្វើអ្វី? ហើយសួរយាយៗ ទៅណាអស់ហើយ? មនុស្សម្នាក់នោះបានបង្គាប់ សន ឲ្យទៅហៅយាយៗ ដែលកំពុងច្រូតស្រូវនៅក្នុងភូមិ។ ពេល សន ទៅដល់ស្រែ មេក្រុមមិនអនុញ្ញាតិឲ្យយាយៗមកទេ ព្រោះខ្លាចស្ទះការងារ។ ដល់ពេលល្ងាច សន បានឃើញមនុស្ស៥នាក់ ស្លៀកពាក់ខោអាវជាយោធាដើរចូលមកភូមិ។ ពេលនោះ សនបានប្រាប់ប្រពន្ធឲ្យរៀបចំដាក់អង្ករក្នុងកំសៀវទុកសម្រាប់ហូបនៅពេលដែលរត់ចូលក្នុងព្រៃម្តងទៀតនៅពេលសភាពការណ៍ច្របូកច្របល់។

ម៉ោង៨ និង ១៥នាទី សន បានឮស្នូរផ្ទុះកាំភ្លើងនៅភ្នំក្រោល ទើប សន និងប្រជាជន នៅស្រុកកោះញែក ចាប់ផ្តើមច្របូកច្របល់ និងឮតែសំឡេងស្រែករកបងប្អូន កូន និងឪពុកម្តាយ។ នៅវេលាម៉ោង៨យប់ សភាពការណ៍បានស្ងប់ស្ងាត់ នៅភ្នំក្រោល ទើបអ្នកភូមិបបួល សន ទៅរស់នៅភូមិរយ៉ែ។ សននិងអ្នកភូមិ១៥០នាក់បានទៅរស់នៅភ្នំក្រោលវិញ បន្ទាប់ពីមានកង ទ័ពវៀតណាមបានមកដល់កន្លែងដែល សន រស់នៅ។

នៅឆ្នាំ១៩៩២ សន និងប្រពន្ធ បានមករស់នៅក្នុងស្រុកអន្លង់វែងរហូតដល់បច្ចុប្បន្ន។ សន បានឆ្លងកាត់នូវភាពជូរចត់យ៉ាងច្រើនក្នុងសម័យតស៊ូ បានធ្វើឲ្យ សន មានរបួស និងបន្សល់ ស្លាកស្នាមនៅលើក្បាលមកដល់សព្វថ្ងៃ។ ទោះបី សន មានភាពភ័យខ្លាច និងបាត់ស្មារត ដោយសាររបបខ្មែរក្រហម ប៉ុន្តែគាត់រីករាយក្នុងការចែករំលែករឿងរ៉ាវរបស់គាត់ឲ្យក្មេងជំនាន់ ក្រោយបានដឹងពីប្រវត្តិសាស្ត្រដែលបានកើតឡើង និងការបាត់បង់សាច់ញាតិ និងឪពុកម្តាយ។

ដារ៉ារដ្ឋ មេត្តា

# ភាពវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ
# របស់មជ្ឈមណ្ឌលឯកសារកម្ពុជា













បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅអគារ H
នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)

វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរដ្ឋកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ស៊ាង ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥*
*អ៊ីម៉ែល truthchenda.s@dccam.org*

# សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង០០២

(តចប់)

*ការធ្វើមិនដឹងដោយលាក់ពុត ដើម្បីគេចចេញពីការទទួលខុសត្រូវ*

*ខៀវ សំផន*

ប៉ុន្តែខ្ញុំសូមសារភាពថា ខ្ញុំទើបតែឃើញលក្ខណៈដាខ្សែសង្វាក់ នៃការចាប់ចងនៅពេលថ្មីៗនេះទេ ហើយខ្ញុំនិយាយឲ្យច្បាស់តែម្តងទៅ គឺនៅពេលដែលខ្ញុំមើលខ្សែភាពយន្តរបស់លោក រិទ្ធី ប៉ាន់ ដែលមានចំណងជើងថា «ស-២១ កន្លែងខ្មែរក្រហមសម្លាប់មនុស្ស»

នួន ជា ៖

ខ្ញុំមិនដែលបានជួប មិនបានគ្រប់គ្រង ឬមិនបញ្ជា ឌុចឲ្យធ្វើបាប ឬសម្លាប់មនុស្សនោះទេ។ អស់លោកគួរតែជ្រាបហើយសារជាតិជាទាហាន ឬសន្តិសុខ គឺមិនដែលស្តាប់អ្នកណាក្រៅពីមេបញ្ជាការរបស់ខ្លួននោះទេ។ ដូច្នេះគ្មានហេតុអ្វីដែលឌុច ស្តាប់ខ្ញុំនោះទេ។ និយាយដោយត្រង់ទៅខ្ញុំទើបតែឮឈ្មោះឌុច នៅក្រោយឆ្នាំ១៩៧៩ តែប៉ុណ្ណោះ។

ចាប់តាំងពីមានការលេចឡើងថានឹងមានតុលាការមួយដើម្បីកាត់សេចក្តីអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានានៃកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានព្យាយាមធ្វើឲ្យពិភពលោកយល់ថា គាត់ជាមនុស្សស្លូតត្រង់ម្នាក់ដែលនៅ



រូបឈរកណ្តាល៖ នួន ជា អតីតប្រធានសភាជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ចុះទៅមូលដ្ឋាន

ជិតកន្លែងដែលព្រឹត្តិការណ៍មួយកើតឡើង ដែលទោះបីជាប្រធានរដ្ឋក៏ដោយ ក៏មិនមានអំណាចអ្វីនិងមិនបានដឹងអំពីអ្វីសោះនៃឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តដោយរបបដែលគាត់ជាតំណាងដែរ។ ខណៈដែលប្រជាជនកម្ពុជាធម្មតា និងកម្មាភិបាលថ្នាក់ទាបរាប់រយនាក់ បានផ្តល់សក្ខីកម្មអំពីលក្ខណ្ឌអមនុស្សធម៌ ការបាត់ខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់ទាំងឡាយដែលបានបង្កើតឡើងនូវបរិយាកាសនៃការភ័យខ្លាច ខៀវ សំផន ដែលបានធ្វើដំណើរពាសពេញផ្ទៃប្រទេស ដែលជាសមាជិកមួយរូបនៃគណៈមជ្ឈិម និងបានចូលរួមប្រជុំយ៉ាងទៀងទាត់នៅក្នុងគណៈអចិន្ត្រៃយ៍ ដែលបានទទួលរបាយការណ៍ពីបណ្តាញព័ត៌មាន និងពីរដ្ឋាភិបាលបរទេសស្តីពីការរំលោភសិទ្ធិមនុស្សជាបន្តបន្ទាប់ ហើយដែលបានរស់នៅ បានធ្វើការ និងបានហូបចុកជាប្រចាំនៅក្នុងទីជិតខាង ប៉ុល ពត និង នួន ជា ធ្លាប់អះអាងថាមិនបានដឹងពីអ្វីទាំងអស់នៃឧក្រិដ្ឋកម្មនានាដែលបានបន្តកើតឡើង។ ការអះអាងនេះ គឺមិនគួរឲ្យជឿ ហើយសេចក្តីថ្លែងមិនខ្ចាប់ខ្ជួនផ្ទាល់របស់ ខៀវ សំផន បានធ្វើឲ្យច្បាស់លាស់ថា ការប្រកែករបស់គាត់គឺមិនគួរឲ្យជឿបានទាល់តែសោះ។

នៅក្នុងបទសម្ភាសន៍មួយតាមវិទ្យុ ក្នុងឆ្នាំ២០០៧ ខៀវ សំផន ត្រូវបានសួរអំពី«គោលនយោបាយវាលពិឃាត» ហើយបាននិយាយថា «ប៉ុល ពត លោកតាមដាន ហើយលោកចាប់ចងដោយរួមជាមួយគណៈអចិន្ត្រៃយ៍ លោកមិនដែលធ្វើអ្វីម្នាក់ឯងទេ»។ វិធីតែមួយគត់ដែល ខៀវ សំផន អាចបានដឹងអំពីតួនាទីរបស់ ប៉ុល ពត និងបានដឹងអំពីតួនាទីរបស់គណៈអចិន្ត្រៃយ៍ គឺប្រសិនបើគាត់បានដឹង មិនត្រឹមតែការចាប់ខ្លួនប៉ុណ្ណោះទេ ក៏ប៉ុន្តែពីនីតិវិធីទាំងស្រុងនៃការធ្វើសេចក្តីសម្រេចចិត្តដែលនាំឆ្ពោះទៅរកការចាប់ខ្លួននោះ។ ខៀវ សំផន បាននិយាយបន្តទៀតថា នៅក្នុងភូមិ «គឺចាប់នៅពេលដែល



ហ៊ូ នឹម អតីតរដ្ឋមន្ត្រីក្រសួងឃោសនាការនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

ស្រាវជ្រាវខ្មែររបស់អ្នកដែលត្រូវចាប់ ពីព្រោះអ្នកដែលត្រូវចាប់នឹងសុទ្ធតែខ្មែរអ្នកកាន់អំណាច» ដោយបន្តថា «អ្នកណាមិនគោរពអញ អ្នកណាអញមិនសប្បាយចិត្ត អ្នកណាអញទាស់ចិត្ត អញដកចេញ» ពីព្រោះ «ទុកក៏វាមិនចំណេញ ដកចេញក៏វាមិនខាត»។ ជាថ្មីម្តងទៀត សេចក្តីថ្លែងរបស់ ខៀវ សំផន បង្ហាញថា គាត់បានដឹងយ៉ាងច្បាស់អំពីនយោបាយរបស់មេដឹកនាំខ្មែរក្រហមស្តីពីការផ្តោតគោលដៅទៅលើពួកដែលបានទាក់ទងទៅនឹង ឬបានចូលរួមជាមួយនឹងគូប្រជែងរបស់ខ្លួនជា«ខ្មែរសន្តាក់» និងការសម្លាប់មនុស្សនៅលើមូលដ្ឋាននៃការចូលរួមនេះតែប៉ុណ្ណោះ។

ការអះអាងរបស់ ខៀវ សំផន ដែលថាគាត់មិនបានដឹងអំពីភាពសាហាវនៃរបបនេះ គឺយើងជាក់ស្តែងមិនគួរឲ្យជឿបាននោះទេ។ ភ័ស្តុតាងដែលបានរាយយ៉ាងពិស្តារនៅខាងក្រោមសារណានេះបង្ហាញថា គាត់បានទៅធ្វើទស្សនកិច្ចនៅតាមសហករណ៍ និងការដ្ឋាននានា ជាដំបូងគឺការអមដំណើរសម្តេច សីហនុ ដែលជាទូទៅត្រូវបានខ្មែរក្រហមឃុំឃាំងនៅក្នុងដំណាក់របស់ព្រះអង្គ និងត្រូវបានឃុំគ្រងដូចជាអ្នកទោសដោយខ្មែរក្រហម អាចមានលទ្ធភាពពិនិត្យមើលនូវលក្ខខណ្ឌអមនុស្សធម៌ ចំពោះពួកអ្នកដែលបានធ្វើស្រែនៅតាមការដ្ឋាន ដែលពួកគាត់បានទៅធ្វើទស្សនកិច្ចជាមួយគ្នានោះ ខៀវ សំផន ពិតជាមិនអាចធ្វើមិនដឹងមិនឮបាននោះទេ។

ខៀវ សំផន បានអះអាងនៅក្នុងសៀវភៅរបស់គាត់ថា គាត់បានដឹងថាមាន ស-២១ ដែលជាមណ្ឌលធ្វើទារុណកម្ម និងសម្លាប់មនុស្សនៅទួលស្លែង គឺនៅពេលដែលគាត់បានមើលខ្សែភាពយន្ត ស-២១៖ កន្លែងខ្មែរក្រហមសម្លាប់មនុស្ស ដែលមិនត្រូវបានគេផ្សព្វផ្សាយទេ រហូតដល់ឆ្នាំ២០០៣។ យ៉ាងណាក៏ដោយ មេធាវីរបស់គាត់ថ្មីៗនេះ បានស្រង់សម្តីចេញពីបទសម្ភាសន៍ អៀង ធីរិទ្ធ មួយដែលនៅក្នុងនោះ គាត់បាននិយាយថា គាត់បានឃើញរបាយការណ៍នៅទួលស្លែង នៅពេលដែលគាត់នៅជាមួយ ខៀវ សំផន នៅទីក្រុងHavana ហើយអះអាងថា ពួកគាត់ទាំងពីរនាក់មានការភ្ញាក់ផ្អើល។ ការប្រជុំនៅទីក្រុង Havana គឺនៅខែកញ្ញា ឆ្នាំ១៩៧៩ គឺជាងពីរទសវត្សរ៍ មុន ខៀវ សំផន ឥឡូវនេះអះអាងថា បានដឹងពី ស-២១។

មិនមាននរណាម្នាក់ ដែលបានរស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យមិនបានដឹងពីការបាត់ខ្លួន និងពីបរិយាកាសនៃការភ័យខ្លាចទាំងនេះ ត្រូវបានបង្កើតឡើងនោះទេ។ ខៀវ សំផន ដែលបានធ្វើនៅមជ្ឈមណ្ឌលកណ្តាលនៃរបបនេះ បានធ្វើការ និងបានហូបអាហារពេលល្ងាចជារៀងរាល់ថ្ងៃជាមួយនឹង ប៉ុល ពត និង នួន ជា បានធ្វើដំណើរនៅក្នុងប្រទេស ហើយបានចូលរួមប្រជុំយ៉ាងទៀតទាត់នៅក្នុង«គណៈអចិន្ត្រៃយ៍» យ៉ាងជាក់ស្តែង គឺបានដឹងព័ត៌មានច្រើនជាងអ្នកភាគច្រើនទៀតអំពីឧក្រិដ្ឋកម្មទាំងនេះ។ ភាគច្រើននៃអ្នកដែលត្រូវបានបោសសម្អាត គឺជាអ្នកសេពគប់យ៉ាងជិតស្និទ្ធរបស់ ខៀវ សំផន ដែលបានធ្វើការជារដ្ឋមន្ត្រីជាមួយនឹងគាត់នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាហ្គ្រុង ខៀវ ប្រធានមន្ទីរ ៨៧០ ដែលជាសមាជិកតែម្នាក់គត់ផ្សេងទៀតរបស់ ខៀវ សំផន, ប៉ាំ ដែលបានធ្វើការជាមួយមេដឹកនាំនៅមជ្ឈមណ្ឌលកណ្តាល ក្នុងឋានៈជាប្រធានរដ្ឋបាលមន្ទីរ ស-៧១ និង វ៉ន វេត ឧបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច (ដែលបានធ្វើការជាមួយ ខៀវ សំផន ពាក់ព័ន្ធនឹងការនាំចេញ និងបញ្ហាពាណិជ្ជកម្មផ្សេងៗទៀតរបស់កម្ពុជាប្រជាធិបតេយ្យ)។ នៅក្នុងឆ្នាំ១៩៧៦ ខៀវ សំផន បានបដិសេធនូវរបាយការណ៍បរទេសស្តីពីអំពើដ៏សាហាវនៅកម្ពុជាថា «គ្មានអ្វីគួរឲ្យយើងយកចិត្តទុកដាក់នោះទេ»។

ការអះអាងរបស់ ខៀវ សំផន អំពីការធ្វើមិនដឹងនេះ គឺជាការផ្ទុយគ្នាផងដែរទៅនឹងសេចក្តីថ្លែងនានា ដែលបង្ហាញថាគាត់បានដឹងអំពីការចាប់ខ្លួន និងការសម្លាប់មនុស្សនៅពេលដែលអំពើនោះបានកើតឡើង និងបានបន្តព្យាយាមធ្វើសក្តិកម្មដល់អំពើទាំងនោះ ជាយូរក្រោយមកទៀត។ ជាឧទាហរណ៍ នៅក្នុងបទសម្ភាសន៍មួយកាលពីខែសីហា ឆ្នាំ១៩៨០ ខៀវ សំផន បានអះអាងថា ពួកភ្នាក់ងារវៀតណាម បានទទួលនូវ

មុខតំណែងសំខាន់ៗនៅក្នុងចលនាខ្មែរក្រហម នៅឆ្នាំ១៩៧៥ ថា «អ្នកខ្លះកាន់អំណាចនៅភូមិភាគសំខាន់ៗ» និង «នេះជាការវាយយើងខ្ញុំពីខាងក្នុង»។ ខៀវ សំផន បាននិយាយថា «យើងខ្ញុំក៏បានប្រយុទ្ធ ហើយប្រយុទ្ធយកឈ្នះ ហើយប្រយុទ្ធដាច់» និង«យើងខ្ញុំដោះស្រាយពួកនេះបានជាមូលដ្ឋាន»។ នៅពេលសួរពីភាគរយនៃភ្នាក់ងារខ្មាំង ដែលនៅក្នុងលំដាប់ខ្ពស់របស់បក្ស ខៀវ សំផន បាននិយាយថា «ក្នុងមជ្ឈិមមិនដល់ពាក់កណ្ដាលទេ។ ប៉ុន្តែ ក្នុងអចិន្ត្រៃយ៍វាជិតពាក់កណ្ដាល»។ ខៀវ សំផន បានទទួលស្គាល់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា«ខ្ញុំបានឃើញសមាជិកមួយចំនួនរបស់គណៈកម្មាការមជ្ឈិមបាត់ខ្លួនម្ដងមួយៗ»។ គាត់បានបកស្រាយបង្ហាញនូវការដឹងឮរបស់គាត់ អំពីយុទ្ធនាការបោសសម្អាត ដោយការពិភាក្សាស៊ីជម្រៅអំពីមូលហេតុចាប់ខ្លួន ចាន់ ចក្រី ដោយការពន្យល់ថា វាមានមូលដ្ឋាននៅលើចម្លើយសារភាពរបស់បុគ្គល ដែលត្រូវបានលើកឡើងចោទប្រកាន់ថា បានបោកគ្រាប់បែកនៅក្រោយវាំង ដែលបានឆ្លើយដាក់ពួកមន្ត្រីយោធា ហើយក៏ដល់វេនពួកវាឆ្លើយដាក់ ចាន់ ចក្រី។ ខៀវ សំផន បានសង្កត់ធ្ងន់ថា «លោក ប៉ុល ពត មិនចេះតែចាប់កម្មាភិបាលទេ។ វាមានរឿងរ៉ាវដែលត្រូវការស៊ើបអង្កេតតាមដាន ហើយឃើញច្បាស់តែម្ដង»។ នៅពេលដែលអ្នកសម្ភាសន៍បានពោលដល់ការសម្លាប់មិត្តភក្តិរបស់ ខៀវសំផន ហ៊ូ យន់ និង ហ៊ូ នឹម ជាមួយនឹងកម្មាភិបាលជា ច្រើននាក់ផ្សេងទៀត ដែលបានបម្រើការយូរមកហើយ និងក្រោយមកបានសួរថា «តាមដែលលោកដឹង មិនមានអ្នកណាស្លូតត្រង់ត្រូវបានគេចោទប្រកាន់ទេមែនទេ? ចម្លើយរបស់ ខៀវ សំផន គឺដាច់ស្រេចហើយថា «គ្មានទេ»។

តើ ហ៊ូ នឹម និង ហ៊ូ យន់ មានកំហុសអ្វីខ្លះ? ខៀវ សំផន បានដឹងថា ពួកគាត់ត្រូវបានសម្លាប់ដោយគ្រាន់តែបានទិតៀនគោលនយោបាយរបស់ប៉ុលពត។ គាត់បានប្រាប់សហចៅក្រមស៊ើបអង្កេតថា «ខ្ញុំមិនអាចរស់រានមានជីវិតបានទេ ប្រសិនបើខ្ញុំហ៊ានលើកឡើងពីការជំទាស់ណាមួយនោះ។ ឧទាហរណ៍របស់ ហ៊ូ នឹម និង ហ៊ូ យន់ ជាភ័ស្តុតាងស្រាប់«។

មុនការចាប់ខ្លួនគាត់ នួន ជា បានទទួលស្គាល់ថា គោលនយោបាយសម្លាប់មនុស្ស និងការការពារនៃរបបនេះ ដោយការបញ្ជាក់ថា គាត់នឹងពន្យល់វាទាំងអស់នៅឯសវនាការ។ យ៉ាងណាក៏ដោយនៅក្នុងសេចក្ដីថ្លែងរបស់គាត់ នៅពេលបិទសវនាការលើសំណុំរឿង០០២/០១ នួន ជា ក៏ដូចជា ខៀវសំផន ដែរ បានស្វែងរកធ្វើការបញ្ចេញមតិ (ដោយមិនអស់សេចក្តី)



ប៉ុល ពត និងគណប្រតិភូចិន នៅព្រ

ពីអំណាច និងតួនាទីរបស់គាត់នៅក្នុងរបបនោះ និងគ្រវែងនូវរាល់ការរិះគន់ទាំងអស់ដាក់ទៅលើអ្នកដទៃ។ បើទុកជាសេចក្ដីថ្លែងពីមុនរបស់គាត់ទទួលស្គាល់ថា គាត់ជាមនុស្សទីពីរនៅក្នុងរបបនោះក៏ដោយ ហើយថាគាត់បានពិភាក្សា និងឯកសារលើគ្រប់គោលនយោបាយទាំងអស់ជាមួយនឹង ប៉ុល ពត ក៏ដោយ ក៏ នួន ជា បានប្រាប់តុលាការថា នៅអំឡុងពេលនៃ

របបកម្ពុជាប្រជាធិបតេយ្យ «ខ្ញុំមិនមានអំណាចអ្វី» ទេ។ នួន ជា ក្រោយមកបានអះអាងថា គាត់មិនធ្លាប់បានឲ្យបញ្ជាណាមួយដល់ ឌុច នោះទេ មិនធ្លាប់បានជួប ឌុច និងទើបតែបានឮឈ្មោះរបស់ ឌុច នៅក្រោយឆ្នាំ១៩៧៩ ប៉ុណ្ណោះ។ នៅក្នុងបទសម្ភាសន៍មុនៗ នួន ជា បាននិយាយអំពីការបានពិភាក្សាយ៉ាងវែងជាមួយនឹង ឌុច ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានពិភាក្សារឿងរបស់ ឌុច ជាមួយនឹង តាម៉ុក។



លានយន្តហោះអន្តរជាតិពោធិចិនតុង

នួន ជា ធ្លាប់បានបញ្ជាក់បន្ថែមរឿងរ៉ាវរបស់ ឌុច ថាពួកគាត់បានពិភាក្សាយ៉ាងជាក់លាក់នូវចម្លើយសារភាពមួយ នៅ ស-២១ ដែលបានឆ្លើយដាក់ ខៀវ សំផន ដែលគាត់ធ្លាប់បានបញ្ជាដល់ ឌុច ឲ្យធ្វើមិនដឹងមិនឮ ហើយគាត់បានអះអាងថា «ឌុច មិនពេញចិត្តនឹងខ្ញុំឡើយ ពីព្រោះខ្ញុំតែងតែស្តីបន្ទោសគាត់ ដោយសារគាត់បានប្រព្រឹត្តកំហុសជាច្រើន»។

*ការធ្វើយុត្តិកម្មលើការធ្វើមនុស្សឃាតយ៉ាងរង្គាល*

*ថេត សម្បត្តិ ម្ចាស់ខ្សែភាពយន្តឯកសារ នៅពីក្រោយវាលពិឃាតៈ*

នួន ជា បាននិយាយថា គាត់មិនយកចិត្តទុកដាក់ជាពិសេសអ្វីឡើយ នៅពេលដែលមានការសម្លាប់សមមិត្ត និងមិត្តភក្តិពីមុនរបស់គាត់នោះៈ «បក្សបានសម្រេចមេដឹកនាំទាំងនេះ ព្រោះពួកគេក្បត់បក្ស និងជាតិ។ ខ្ញុំមិនរន្ធត់ ឬពិបាកចិត្តឡើយនៅពេលដឹងពីការសម្លាប់ពួកគេ។ ពួកគេមានកំហុស ហើយក្បត់ពួកយើងដូច្នេះពួកគេត្រូវតែទទួលទោសតាមទង្វើរបស់ពួកគេ»។

នួន ជា បានជជែកថាៈ

ភ័ស្តុតាងនៃការរៀបចំ និងចេតនាក្នុងការបង្ករឲ្យមានការបះបោរប្រឆាំងនឹងបក្ស កុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ...បើទោះបីជា នួន ជា អាចត្រូវបានសម្រេចថាទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទចោទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការសម្លាប់រង្គាល...នៅតាមមន្ទីរសន្តិជាច្រើន។

អំណះអំណាងទាំងនេះ គឺពុំមានមូលដ្ឋានតាមផ្លូវច្បាប់ទេ និងត្រូវបានគេស្អប់ខ្ពើមយ៉ាងខ្លាំងតាមផ្លូវចិត្ត។ អំណះអំណាងទាំងនេះ កើតមានបន្តបន្ទាប់ពីអំណះអំណាងរបស់ នួន ជា ដែលថារបបផ្តាច់ការណាក៏ដោយ គឺសេរីក្នុងការធ្វើទារុណកម្ម និងសម្លាប់ក្រៅអំណាចតុលាការនូវការទិតៀនដែលខ្លួនបានយល់ឃើញ ដែលគ្រាន់តែឈរទៅលើការសង្ស័យដែលថាពួកវា គឺមិនស្មោះត្រង់ទៅនឹងមេដឹកនាំរបបនោះ។

វាពុំមានភ័ស្តុតាងដែលពុំគួរឲ្យជឿជាក់បានថា ជនរងគ្រោះរាប់ពាន់នាក់ត្រូវបានជាប់ឃុំឃាំងត្រូវបានធ្វើទារុណកម្ម និងត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខកម្ពុជាប្រជាធិបតេយ្យភាគច្រើននៃពួកគាត់គឺជាក្មេងៗ កំពុងរៀបផែនការខុទ្ទាមកម្មមួយទេ។ ផ្ទុយទៅវិញ ភ័ស្តុតាងបង្ហាញថា របបនេះឃុំខ្លួនដោយមិនរើសមុខ និងសម្លាប់អស់រាប់សែននាក់នូវបុរសស្ត្រី និងក្មេងៗ តែនៅលើអង្គហេតុពិតដែលថា ពួកគាត់ត្រូវបាន

គេឆ្លើយដាក់នៅក្នុង «ចម្លើយសារភាព» ដែលមកដោយសារការធ្វើទារុណកម្មប៉ុណ្ណោះ។ អន្ដហេតុដែលថាពួកគាត់ជាអតីតមន្ដ្រីរាជការ លន់ នល់ ឬជាទាហាននៅក្នុងអន្ដភាពដែលមេបញ្ជាការរបស់ពួកគាត់ ត្រូវបានរបបនេះសង្ស័យថាមិនស្មោះត្រង់។ ជាមូលដ្ឋានដែលពួកគាត់ជាជាតិចាម ឬវៀតណាម។ អន្ដហេតុដែលថាពួកគាត់ធ្លាប់បានទិតៀនការគ្រប់គ្រងរបស់ខ្មែរក្រហម។ ឬអន្ដហេតុដែលថាពួកគាត់ត្រូវបានជាប់ទាក់ទងក្នុងកម្រិតណាមួយ ឬមានជាប់ទាក់ទិនទៅនឹងបុគ្គលណាម្នាក់នៅក្នុងប្រភេទទាំងនេះ។ របបនេះសម្លាប់មនុស្សកាន់តែច្រើន កាលណាការមិនសប្បាយចិត្តទៅនឹងគោលនយោបាយកាន់តែច្រើន ហើយយុត្តិកម្មកាន់តែច្រើនឡើងសម្រាប់មេដឹកនាំកំពូលដែលមានអារម្មណ៍នៅក្នុងអន្ដភាពដែលចេះតែគិតផ្តេសផ្តាស។

មេដឹកនាំខ្មែរក្រហម បានលុបចោលនូវរាល់តុលាការទាំងអស់នៅក្នុងប្រទេសកម្ពុជា ហើយមិនបានឈានទៅរកការបង្កើតថ្មីនោះទេ។ សភាតំណាងប្រជាជនដែលដឹកនាំដោយ នួន ជា និងមានអំណាចធ្វើច្បាប់ផ្ដាច់មុខ យោងទៅតាមរដ្ឋធម្មនុញ្ញបានជួបប្រជុំតែម្ដងគត់ ហើយសូម្បីតែគាត់បានព្រមទទួល ក៏មិនដែលបានអនុម័តច្បាប់ណាមួយឡើយ។ នៅក្នុងបរិយាកាសដែលគ្មានច្បាប់នេះ វាមិនមានលទ្ធភាពនៃនីតិវិធីត្រឹមត្រូវហើយរបបនេះមិនបានគិតនោះទេសូម្បីតែព្យាយាមគិតថាវាមានក៏ដោយ។

នួន ជា ដែលធ្លាប់បានប្ដឹងតវ៉ាដោយចំអកឡកឡឺយថាកិច្ចដំណើរការនីតិវិធីនៅអ.វ.ត.កត្រូវបានបដិសេធនូវសវនាការត្រឹមត្រូវមួយហើយ «សិទ្ធិត្រូវបានធានានៅក្រោមច្បាប់ជាតិ និងអន្តរជាតិ» ដោយការអះអាងថា ការចាប់ខ្លួន និងការឃុំខ្លួននៅ ស-២១ គឺស្របច្បាប់ ហើយថារបបនោះមានសិទ្ធិសម្លាប់ប្រជាជនរាប់ពាន់នាក់ ដោយមិនមានការជំនុំជម្រះដោយមិនមានការពិនិត្យឡើងវិញតាមផ្លូវតុលាការ និងដោយមិនមានសក្ខីកម្មដែលគួរឲ្យជឿជាក់បាននៃការប្រព្រឹត្តកំហុស។

នួន ជា បានជជែកថា ភ័ស្តុតាងណាក៏ដោយដែលប្រជាជនបានតវ៉ា និងប្រឆាំងនឹងការបោសសម្អាត ឬជំទាស់ទៅនឹងការគ្រប់គ្រងរបស់ ប៉ុល ពត គឺបានធ្វើយុត្តិកម្មទៅលើយុទ្ធនាការនៃរបបដែលបានសម្លាប់«ខ្មាំង» នៅក្រៅប្រព័ន្ធតុលាការរបស់ខ្លួន។ មានក្រុម និងបុគ្គលខ្លះដែលបានប្រឆាំង។ អ្នកខ្លះគ្រាន់តែប៉ុនប៉ងរត់គេចយកអាយុ អ្នកខ្លះទៀតស្វែងរករំដោះសហគមន៍ផ្ទាល់របស់ពួកគេចេញពីការគ្រប់គ្រងដ៏សាហាវនៃរបប ប៉ុល ពត។ សាក្សីនានានៅក្នុងសវនាការនេះ ធ្លាប់បានរៀបរាប់ថា ពួកចាមបះបោរនៅភូមិកោះផល និងភូមិស្វាយឃ្លាំង ដែលមានបុរស និងក្មេងប្រុស បំពាក់ទៅដោយសាស្ត្រាវុធគឺកាំបិត និងដាវវាយប្រឆាំងទៅនឹងអាវុធស្វ័យប្រវត្តិ និងកាំភ្លើងធំទាំងអស់សង្ឃឹមរក្សាការពារនូវសវនាការរបស់ពួកគេ។ អ្នកដទៃទៀតបានរៀបរាប់ពីការតស៊ូរបស់អតីតទាហានខ្មែរក្រហម ដែលបានវាយប្រយុទ្ធនៅក្នុងព្រៃនៅពាក់កណ្ដាលឆ្នាំ១៩៧៨ បានរត់គេចចេញពីការសម្លាប់យ៉ាងរង្គាលនៃរបបនេះ ទៅលើកងកម្លាំងភូមិភាគបូព៌ា។ ភ័ស្តុតាងដទៃទៀតបង្ហាញថា មានប្រជាជននៅស្រុកជីក្រែងក្នុងតំបន់១០៦ បានបះបោរនៅខែមេសា ឆ្នាំ១៩៧៧ បន្ទាប់ពីមានពាក្យចចាមអារ៉ាមផ្សព្វផ្សាយថា សម្ដេច សីហនុ វិលវិញ និងការសម្លាប់នៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងពេលឆាប់ៗនេះ។ គេប៉ាន់ប្រមាណថា ការបះបោរនេះ ជាលទ្ធផលបណ្ដាលឲ្យមានការបាត់បង់អាយុជីវិតប្រមាណពីប្រាំបីទៅដប់ពាន់នាក់។ អ្នកភូមិគួយ (ក្រុមជាតិពន្ធុភាគតិចដែលគេនិយាយហៅជាទូទៅ) បានបះបោរ ហើយប្រជាជនទាំងស្រុងប្រមាណជា៧០០នាក់ ត្រូវបានសម្លាប់។

វាជាការពិតផងដែរ ដែលថាមានបុគ្គលខ្លះបានចេញទៅវៀតណាម និងបានធ្វើសហប្រតិបត្តិការជាមួយនឹងការឈ្លានពានរបស់វៀតណាម ដែលនាំមកនូវការបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ នួន ជា បានបិទស្លាកថា នរណាក៏ដោយដែលបានធ្វើសហប្រតិបត្តិការជាមួយនឹងវៀតណាម ដើម្បីរំដោះប្រទេសកម្ពុជាពីនឹមគ្រប់គ្រងខ្មែរក្រហម ដែលបានធ្វើឲ្យទៅជាទាសករ និងបានសម្លាប់ប្រជាជនកម្ពុជារាប់

លានាក់ថាជាជនក្បត់ៗ នៅឡើយ នួន ជា ផ្ទាល់ត្រូវបានជ្រើសរើសដោយកម្មាភិបាលវៀតណាមម្នាក់ ដើម្បីឲ្យចូលរួមនៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលដឹកនាំដោយវៀតណាម ហ្វីកហាត់អស់ពេលពីរឆ្នាំនៅវៀតណាម ហើយក្រោយមកបានជួយដឹកនាំចលនាមួយដែលបានចិញ្ចឹម និងបានដឹកនាំដោយវៀតណាម ដោយមានគោលបំណងផ្តួលរំលំរដ្ឋាភិបាលជាប់ឆ្នោត និងរាជាធិបតេយ្យនៅកម្ពុជា។ បន្ទាប់ពីរដ្ឋប្រហាររបស់លោក លន់ នល់ អ្នកការទូតវៀតណាមម្នាក់ បានពន្យល់ពីវត្តមាននៃចំនួនដ៏ច្រើននៃកងទាហានរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ដោយការនិយាយថា«លោក នួន ជា បានស្នើសុំជំនួយ ហើយយើងបានរំដោះខេត្តចំនួន៥ ក្នុងរយៈពេល១០ថ្ងៃ។

ការអះអាងរបស់ នួន ជា ដែលថាពួកដែលត្រូវបានសម្លាប់នៅ ស-២១ និងនៅទីកន្លែងសម្លាប់មនុស្សដទៃទៀត គឺជាឧបករណ៍របស់វៀតណាម រកមិនឃើញមានការគាំទ្រនៅក្នុងភ័ស្តុតាងនោះទេ។ មេដឹកនាំជាន់ខ្ពស់ជាច្រើននាក់ដែលត្រូវបានបោសសម្អាត បានបញ្ជាកងកម្លាំងប្រដាប់អាវុធដ៏សំខាន់ តែនៅឡើយទេមិនមាននរណាម្នាក់ដែលបានដឹកនាំប្រតិបត្តិការយោធាណាមួយប្រឆាំងនឹងរបប ប៉ុល ពត នោះទេ។ បើមេបញ្ជាការទាំងនេះ តាមពិតទៅជាភ្នាក់ងាររបស់វៀតណាម គេនឹងរំពឹងថាពួកគេនឹងបានជួយដល់ការជ្រៀតចូលក្នុងទម្រង់ធំរបស់វៀតណាមទៅក្នុងប្រទេសកម្ពុជានាចុងឆ្នាំ១៩៧៧ ជាមិនខាន។ ក៏ប៉ុន្តែការណ៍នេះមិនបានកើតឡើងនោះទេ។ ផ្ទុយទៅវិញ សោ ភឹម និងកងកម្លាំងភូមិភាគបូព៌ារបស់ខ្លួន ដោយឡែកបានដឹកនាំការតស៊ូនៃកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងការជ្រៀតចូលនេះ។

មិនមានមេដឹកនាំភូមិភាគណាម្នាក់បានប្រឆាំងនឹងការចាប់ខ្លួន ឬបានធ្វើការប៉ុនប៉ងដើម្បីរត់គេចចេញនោះឡើយ។ ដូចដលែបានអះអាងដោយសាក្សីបានឃើញផ្ទាល់ក្នុនកែនៅក្នុងសវនាការនេះថា នៅចុងខែឧសភា ឆ្នាំ១៩៧៨ នៅពេលដែលកងកម្លាំងមជ្ឈិមចុះធ្វើការចាប់ខ្លួនក្នុងកម្រិតធំ ទៅ



រូបខាងស្តាំបង្អស់៖ នួន ជា អតីតប្រធានសភាជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងមេដឹកនាំខ្មែរក្រហមមួយចំនួនទៀតចុះទៅមូលដ្ឋាន ,

លើពួកមេបញ្ជាការភូមិភាគបូព៌ារបស់ សោ ភឹម គឺ សោ ភឹម មិនបានរត់គេចចេញឆ្លងកាត់ព្រំដែនវៀតណាមដែលនៅក្បែរនោះទេ ប៉ុន្តែផ្ទុយទៅវិញបានចូលមកភ្នំពេញដោយមានកងការពារពីរបីនាក់ប៉ុណ្ណោះ ដើម្បីនិយាយជាមួយនឹង ប៉ុល ពត និងដោះស្រាយបញ្ហាផ្សេងៗ។ ទោះបីជាការណ៍នេះបកស្រាយបង្ហាញពីកក្តីភាពក៏ដោយ ក៏នៅពេលដែល សោ ភឹម បានមកដល់ឆ្លងទន្លេនៅមុខព្រះរាជវាំង កងកម្លាំងរបស់ ប៉ុល ពត បានវាយប្រហារទៅលើគាត់ ហើយជាយថាហេតុ សោ ភឹម ក៏បានធ្វើអត្តឃាត ដោយហេតុថាកងកម្លាំងមជ្ឈិមបានព័ទ្ធពួកគាត់ជិត។

ឯកសារសហកាល ដែលនៅសល់នៅក្នុងបណ្ណសាររបស់សូវៀត និងអាល្លឺម៉ង់ខាងកើត បានច្បាស់លាស់ហើយថា វៀតណាមពុំមានភ្នាក់ងារណាម្នាក់ ជ្រៀតចូលទៅក្នុងកម្រិតខ្ពស់នៃបកក នោះទេ។ ជាការហួសចិត្តឯកសារទាំងនេះបង្ហាញសក្ខីកម្មថា រដ្ឋាភិបាលវៀតណាមបានគិតថា អ្នកគាំទ្រដ៏ធំរបស់ខ្លួននៅក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ គឺ នួន ជា ផ្ទាល់តែម្តង។ សេចក្តីទុកចិត្តខុសរបស់វៀតណាមនៅក្នុងមិត្តភាពរបស់ នួន ជា គឺប្រហែលជាអាចយល់បាន ដោយសារ នួន ជា បានចំណាយពេលវេលារៀនសូត្រនៅវៀតណាម គាត់ចេះវៀតណាមយ៉ាងស្ទាត់ជំនាញ ការអួតអាងផ្ទាល់របស់គាត់អំពីការដែលអាចបានទទួលជំនួយយោធាពីហាណូយ និងសហប្រតិបត្តិការយ៉ាងយូរអង្វែងជាមួយនឹងវៀតណាម ដើម្បីផ្តួលរំលំរដ្ឋាភិបាលកម្ពុជា។ តាមពិតទៅ នួន ជា មិនមែនជាមិត្តជាមួយនឹងវៀតណាមទេ ហើយការខកខានរបស់រដ្ឋាភិបាលទីក្រុងហាណូយ ក្នុងការបានដឹងពីរឿងនេះបញ្ជាក់ថាពួកគាត់មិនមានការយល់ច្បាស់លាស់ចូលទៅក្នុងកិច្ចការផ្ទៃក្នុងរបស់ បកក ឬរដ្ឋាភិបាល កម្ពុជាប្រជាធិបតេយ្យ។ បើរដ្ឋាភិបាលវៀតណាមមានភ្នាក់ងារនៅក្នុង បកក មែននោះៗ ពួកគាត់នឹងយល់ច្បាស់ថា នួន ជា មិនមែនជាអ្នកគាំទ្រដល់ពួកគេនោះទេ។



ខៀវ សំផន គណប្រធានរដ្ឋរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជួបជាមួយគណប្រតិភូឡាវ

គោលនយោបាយរបស់ បកក ដោយឡែក ការវាយប្រយុទ្ធរបស់ខ្មែរក្រហមដែលបានផ្តោតគោលដៅទៅលើពួកប្រជាជនស៊ីវិលនៅក្នុងប្រទេសវៀតណាម បានជំរុញឲ្យប្រទេសវៀតណាមធ្វើការឈ្លានពាន។ ការទទួលអាហារមិនគ្រប់គ្រាន់ជាទូទៅ និងការងារហួសកម្រិតនៅតាមសហករណ៍ និងការដ្ឋាននានា និងការសម្លាប់យ៉ាងរង្គាលនូវកងកម្លាំងភូមិភាគបូព៌ារាប់ពាន់នាក់ដែលបានវាយប្រយុទ្ធនៅខ្សែត្រៀមជួរមុខ ដើម្បីប្រឆាំងនឹងការឈ្លានពានរបស់វៀតណាម ក្នុងឆ្នាំ១៩៧៧ បានធ្វើឲ្យចុះខ្សោយនូវឱកាសណាមួយក៏ដោយ នៃការតស៊ូខាងយោធា។ ដូចអ្វីដែល ខៀវ សំផន ទើបតែបានទទួលស្គាល់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះថា «នយោបាយជ្រុលហួសរបស់ប៉ុល ពត និងវិធីបង្ខំដោយកំរោលយ៉ាងនេះ បានធ្វើឲ្យជាតិយើងខ្សោះឈាម មិនអាចការពារខ្លួនទប់ទល់វៀតណាមបាន។

ការប៉ុនប៉ងរបស់ នួន ជា ដើម្បីធ្វើយុត្តិកម្មលើយុទ្ធនាការបោសសម្អាតរបស់គាត់ ត្រូវបានទទួលបរាជ័យ។ វាមិនមានអ្វីដែលស្នេហាមាតុភូមិនោះទេ ក្នុងការដែលបានសម្លាប់ក្រៅប្រព័ន្ធតុលាការនូវបុរស ស្ត្រី និងកូនក្មេងកម្ពុជារាប់ម៉ឺននាក់ ដោយមិនមាននីតិវិធីច្បាប់ត្រឹមត្រូវ នៅក្នុងការប៉ុនប៉ងមួយដើម្បីរក្សាការពារនូវការគ្រប់គ្រងរបស់ ប៉ុល ពត និងស្រមោលរបស់គាត់។ ការសម្លាប់ទាំងនេះមិនអាចធ្វើយុត្តិកម្មខាងផ្លូវចិត្ត ឬផ្លូវច្បាប់បាននោះទេ គឺវាជាការសម្លាប់យ៉ាងរង្គាលតែប៉ុណ្ណោះ។

## *សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង០០២/០២*

ទិដ្ឋភាពរួមនេះ គឺជាសេចក្តីសង្ខេបខ្លីមួយនៃភស្តុតាងដ៏ច្រើនធំធេងនៅក្នុងរឿងក្តីនេះ ដែលត្រូវបានពិភាក្សាលម្អិតបន្ថែមទៀត នៅក្នុងផ្នែកដែលនៅសល់នៃសារណានេះស្ទើរតែ៨០០ទំព័រ។ ក្នុងរយៈពេលនៃសំណុំរឿង០០២ ក្នុងអំឡុងពេល៤៩៩ថ្ងៃសវនាការ មានបុគ្គលចំនួន២៧៨នាក់ បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ដោយរួមមានសាក្សីចំនួន១៧៣នាក់ អ្នកជំនាញចំនួន១១នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩៥នាក់។ អង្គជំនុំជម្រះបានទទួលយកឯកសារចំនួន១៦,៩៩១ ដោយរួមបញ្ចូលទាំងសម្ភារសហកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ស្នាដៃវិភាគឯកសារជាវីឌីអូ និងជាខ្សែអាត់សំឡេង និងកំណត់ហេតុស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារទាំងអស់នេះមានតាមទំហំ ចាប់ពីទូរលេខ ឬរូបថតកម្ពុជាប្រជាធិបតេយ្យមួយទំព័រ ទៅសៀវភៅមានកម្រាស់រាប់រយទំព័រ។ ដោយសារទំហំរបស់វា គេមិនអាចពិភាក្សាទៅលើភស្តុតាងទាំងអស់បាននោះទេ។ ហេតុដូច្នេះ អ្វីដែលមាននេះ គឺជាការពិនិត្យមើលសក្ខីកម្ម និងឯកសារសំខាន់បំផុត និងពិភាក្សាថា តើភស្តុតាងនេះបង្ហាញសក្ខីកម្មឲ្យបានហួសពីវិមតិសង្ស័យ ដែលថា នួន ជា និង ខៀវ សំផន ត្រូវមានពិរុទ្ធភាពពីបទចោទប្រកាន់នានា នៅក្នុងសំណុំរឿង ០០២/០២ ដែរឬទេ។



*ហ៊ូ យន់ អតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហករណ៍ និងកែទម្រង់ជនបទ នៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)*

# ឯកសារសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា

## សេចក្តីថ្លែងការណ៍ដោយសហព្រះរាជអាជ្ញាអន្តរជាតិលើករណីរបស់ យឹម ទិត្យ នៅក្នុងតុលាការខ្មែរក្រហម

យឹម ទិត្យ ហៅ តាទិត្យ គឺជាអតីតកម្មាភិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការខ្មែរក្រហម) កំពុងធ្វើការចោទប្រកាន់លើបទឧក្រិដ្ឋកម្មជាច្រើនក្នុងសំណុំរឿង០០៤។ យឹម ទិត្យ មានទីកន្លែងកំណើតនៅស្រុកត្រាំកក់ ខេត្តតាកែវ ក្នុងភូមិភាគនិរតីនៃប្រទេសកម្ពុជា។ យឹម ទិត្យ បានរៀបការជាមួយប្អូនស្រីរបស់តាម៉ុក ដែលជាអតីតលេខាបក្សនៅភូមិភាគពាយ័ព្យ ឈ្មោះ អ៊ុង គេន និងជាអតីតប្រធានមន្ទីរពេទ្យគិរីវង្ស ស្ថិតនៅក្នុងស្រុកគិរីវង្ស ខេត្តតាកែវ។ ក្មួយប្រុសបង្កើតរបស់ យឹម ទិត្យ បាននិយាយថា យឹម ទិត្យ និងប្រពន្ធរបស់គាត់មានកូនចំនួន៦នាក់ គឺស្រី១នាក់ និងប្រុស៥នាក់ ហើយកូន២នាក់ក្នុងចំណោមកូន៦នាក់បានស្លាប់ ដែលម្នាក់ក្នុងចំណោមនោះគឺស្លាប់ដោយសាររងការទម្លាក់គ្រាប់បែក។ យឹម ទិត្យ បានចូលរួមជាមួយបដិវត្តន៍ចាប់តាំងពីការចាប់ផ្តើម និងក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបម្រើការងារក្នុងជួរដឹកនាំដែលតួនាទីផ្សេងៗគ្នា។



លោកស្រី ជា លាង សហព្រះរាជអាជ្ញាជាតិ

នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ តុលាការខ្មែរក្រហម បានចោទប្រកាន់ទៅលើអតីតកម្មាភិបាលខ្មែរក្រហមពាទាក់គឺ យឹម ទិត្យ, អោ អាន និង អ៊ឹម ចែម នៅក្នុងសំណុំរឿង០០៤ លើបទឧក្រិដ្ឋដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។ សំណុំរឿង០០៤នៅតែជារឿងក្តីប្រឆាំងនឹងយឹម ទិត្យ បន្ទាប់ពីមានការបំបែកសំណុំរឿង និងការបង្កើតសំណុំរឿង០០៤/០១និង០០៤/០២។ នៅថ្ងៃទី៤ខែមិថុនាឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿង០០៤ដែលទាក់ទងទៅនឹងការស៊ើបអង្កេតជនជាប់ចោទ យឹម ទិត្យ។ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ សេចក្តីសង្ខេបអំពីការសន្និដ្ឋានជាស្ថាពរលើករណី០០៤បានដាក់បង្ហាញជាសាធារណៈ ដែលនៅក្នុងនោះរួមមានសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីយុត្តាធិការរបស់តុលាការខ្មែរក្រហមទៅលើជនជាប់ចោទ យឹម ទិត្យ ពីទិដ្ឋភាពទូទៅនៃឧក្រិដ្ឋកម្ម ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានចោទប្រកាន់ យឹម ទិត្យ អំពីការទទួលខុសត្រូវ ក៏ដូចជាសេចក្តីថ្លែងការណ៍បន្ថែមទៀត ទៅលើសំណុំរឿងនេះ ដែលអាចធ្វើឲ្យសហព្រះរាជអាជ្ញាអន្តរជាតិជឿជាក់ថា គួរតែធ្វើការទៅលើសំណុំរឿង០០៤បន្តទៀត។

តាមរយៈយុត្តាធិការរបស់តុលាការខ្មែរក្រហម លើករណី០០៤ សហព្រះរាជអាជ្ញាអន្តរជាតិបានថ្លែងថា ផ្អែកលើភស្តុតាងដលសមស្របទៅនឹងលក្ខណៈវិនិច្ឆ័យដែលចាំបាច់ក្នុងការជំនុំជម្រះក្តីរបស់តុលាការ។ តាមរយៈមុខតំណែងទាំងអស់របស់ យឹម ទិត្យ សហព្រះរាជអាជ្ញាអន្តរជាតិ បាន



អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហម នៅខេត្តតាកែវ

ថ្លែងថា យឹម ទិត្យ គឺជាកម្មាភិបាលដ៏មានអំណាចបំផុតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយមើលខុសត្រូវទៅលើភូមិភាគចំនួន២គឺភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដែលគាត់បានត្រួតត្រាលើចំណែកដ៏ធំនៃប្រជាជនសរុបក្នុងរបបខ្មែរក្រហម។ នៅក្នុងភូមិភាគទាំងពីរ សហព្រះរាជអាជ្ញាអន្តរជាតិបានរកឃើញថា មានមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សជាច្រើន ក៏ដូចជាទីតាំងផ្សេងទៀត ដែលឧក្រិដ្ឋកម្មជាច្រើនត្រូវបានបង្កឡើង។ យឹម ទិត្យ គឺជាលេខាតំបន់១៣ប្រចាំនៅភូមិភាគនិរតី ហើយគាត់ក៏ជាអនុលេខាភូមិភាគពាយ័ព្យ ដែលជារឿយៗ យឹម ទិត្យ បានធ្វើជាលេខាភូមិភាគស្តីទី នៅពេលដែល តាម៉ុក អវត្តមាននៅក្នុងភូមិភាគ។

ជាការបន្ថែមលើ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតាមភូមិភាគទាំងពីរនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានចាត់ទុកថា យឹម ទិត្យ គឺជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ការបោសសម្អាតអតីតមេដឹកនាំខ្មែរក្រហម គ្រួសារ និងអ្នកដែលនៅក្រោមបង្គាប់នៅភូមិភាគពាយ័ព្យ និងឧក្រិដ្ឋកម្មនៃការបង្ខំឲ្យរៀបការ និងការរំលោភសេពសន្ថវៈ។ យឹម ទិត្យ បានជួយបង្កើតឲ្យចេញជារូបរាងនិងធ្វើឲ្យកាន់តែដុះដាលនូវគោលនយោបាយឧក្រិដ្ឋកម្មផ្សេងៗ ព្រមទាំងធានាឲ្យបានថា គោលនយោបាយទាំងនោះត្រូវបានអនុវត្តដោយអ្នកដែលនៅក្រោមបង្គាប់របស់គាត់។ ក្នុងលក្ខខណ្ឌនៃអំពើប្រល័យពូជសាសន៍សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា យឹម ទិត្យ គួរតែត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ជនជាតិវៀតណាម និងខ្មែរក្រោមនៅប្រទេសកម្ពុជា។ លើសពីនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានថ្លែងថា សហព្រះរាជអាជ្ញាអន្តរជាតិមានភស្តុតាង ដែលអាចបង្ហាញពីការជាប់ពាក់ព័ន្ធដោយផ្ទាល់របស់ យឹម ទិត្យ ចំពោះការបញ្ជាផ្ទាល់លើការសម្លាប់។

តាមរយៈសេចក្តីសន្និដ្ឋាន របស់សហព្រះរាជអាជ្ញាអន្តរជាតិ បានចាត់ទុកថា យឹម ទិត្យ បានចូលរួមចំណែកទទួលខុសត្រូវទៅលើមន្ទីរសន្តិសុខចំនួន១៧កន្លែង ទីតាំងសម្លាប់មនុស្ស៨កន្លែង ការដ្ឋានការងារ៤កន្លែង និងទីតាំងបន្ថែម៣កន្លែងទៀត ដូចជា រោងចក្រស្ករសកំពង់គល់ ឃុំរាំងកេសី និងការអនុញ្ញាតឲ្យមានអំពើហិង្សាផ្លូវភេទកើតឡើងនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ មន្ទីរសន្តិសុខវត្តព្រះធាតុ ជាមន្ទីរសន្តិសុខមួយកន្លែងស្ថិតនៅក្នុងស្រុកគិរីវង្ស ខេត្តតាកែវ ភូមិភាគនិរតីនៃប្រទេសកម្ពុជាដែលមានជនរងគ្រោះប្រហែល ៩០០នាក់ គឺជាខ្មែរក្រោមនិងប្រជាជន ១៧ មេសា ត្រូវបានឃុំឃាំង និងសួរចម្លើយ ហើយក្រោយមកត្រូវបានសម្លាប់។ យឹម ទិត្យ ធ្លាប់បានសួរចម្លើយអ្នកជាប់ឃុំដោយផ្ទាល់នៅក្នុងមន្ទីរសន្តិសុខនោះ។ នៅទីតាំងផ្សេងទៀតក្នុងភូមិភាគនិរតី ដូចជាមន្ទីរសន្តិសុខ វត្តអង្គស្រីមុន្នី និងទីកន្លែងសម្លាប់មនុស្សព្រៃសុខុន ដែលស្ថិតក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ មានប្រជាជន១៧ មេសា អតីតមន្ត្រីរដ្ឋការ លន់ នល់ និងខ្មែរក្រោម ត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ និងខេត្តតាកែវទីកាន់ទីនោះ។ អ្នកជាប់ឃុំឃាំងត្រូវបានសម្លាប់ជារៀងរាល់ថ្ងៃ ហើយមានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីនោះ។

យឹម ទិត្យ ត្រូវបានចោទប្រកាន់ទៅលើបទឧក្រិដ្ឋជាច្រើនទៀតដែលបានប្រព្រឹត្តឡើងនៅភូមិភាគពាយ័ព្យ។ ក្រៅពីការទទួលខុសត្រូវទៅលើការស្លាប់របស់ប្រជាជនរាប់ពាន់នាក់នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជាច្រើនកន្លែង យឹម ទិត្យ បានត្រួតពិនិត្យទៅលើការសាងសង់ទំនប់ដង្កួតស្ថិតក្នុងស្រុកសង្កែ ខេត្តបាត់ដំបង។ ប្រជាជនជាច្រើនត្រូវបានបង្ខំឲ្យធ្វើការ និងជារឿយៗត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរសន្តិសុខផ្សេងៗរួមមានមន្ទីរឃុំឃាំងស-២១ នៅទីក្រុងភ្នំពេញដែរ។ នៅក្នុងស្រុកសង្កែ យឹម ទិត្យ ក៏បានត្រួតពិនិត្យមើលទៅលើរោងចក្រស្ករសកំពង់គល់ ដែលគ្រប់កម្មកររោងចក្រនៅភាគពាយ័ព្យ ក៏ដូចជាកម្មករខ្មែរក្រោម និងកម្មករវៀតណាម ទាំងអស់ត្រូវបានបោសសម្អាត។ ចំណែកឯនៅមន្ទីរសន្តិសុខវត្តសម្តេច ស្ថិតក្នុងឃុំបាក់ព្រាវិញ មានប្រជាជនរាប់ពាន់នាក់ត្រូវបានសម្លាប់ ដោយមានរណ្តៅកប់សពចំនួន១១ ត្រូវបានរកឃើញ ដោយរណ្តៅធំជាងគេបំផុតមានសាកសពលើស

ពី២,០០០ នាក់។

សហព្រះរាជអាជ្ញាអន្តរជាតិ បានបញ្ចប់ដីកាសន្និដ្ឋានជាស្ថាពរទៅលើទៅលើទិដ្ឋភាពទូទៅនៃការទទួលខុសត្រូវរបស់ យឹម ទិត្យ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ការបោសសម្អាតអតីតមេដឹកនាំខ្មែរក្រហមនៅភូមិភាគពាយ័ព្យ និងឧក្រិដ្ឋកម្ម នៃការបង្ខំឲ្យរៀបការ និងការរំលោភសេពសន្ថវៈ។ ចំពោះការទទួលខុសត្រូវទី១ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ សហព្រះរាជអាជ្ញាអន្តរជាតិ បានចាត់ទុកថា យឹម ទិត្យ បានទទួលខុសត្រូវចំពោះការអនុវត្តផែនការរបស់បក្សដើម្បីកម្ទេចវៀតណាម ក៏ដូចជាមានបំណង និងមានការសម្លាប់រង្គាលទៅលើខ្មែរក្រោមនៅតាមតំបន់ក្រោមការគ្រប់គ្រងរបស់ខ្លួន។ ចំណែកឯការទទួលខុសត្រូវទី២ លើការបោសសម្អាតអតីតមេដឹកនាំខ្មែរក្រហម



មាស មុត

នៅភូមិភាគពាយព្យ សហព្រះរាជអាជ្ញាអន្តរជាតិ បានចាត់ទុកថា យឹម ទិត្យ បានធ្វើការជាមួយ តាម៉ុក ក្នុងការបោសសម្អាតជាបន្តបន្ទាប់នូវកម្មាភិបាលភូមិភាគពាយ័ព្យរួមជាមួយគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ។ ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ ក៏បានរកឃើញថា យឹម ទិត្យ បានចូលរួមចំណែកក្នុងគោលនយោបាយរបស់បក្សកុម្មុយនីស្ត ចំពោះការបង្ខំប្រជាជនកម្ពុជារៀបការ និងរួមសង្វាសដើម្បីបង្កើនអត្រាប្រជាជន។ សហព្រះរាជអាជ្ញាអន្តរជាតិ កំពុងតែធ្វើការចោទប្រកាន់ថា បុរសនិងស្ត្រីដែលត្រូវបានបង្ខំឲ្យរួមភេទដោយមិនមានការព្រមព្រៀងពិតប្រាកដ គឺជាការរំលោភសេពសន្ថវៈ។

ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិបានថ្លែងថា បច្ចុប្បន្ននេះ វាអាស្រ័យទៅលើសហចៅក្រមស៊ើបអង្កេត សម្រេចទៅតាមច្បាប់ ថាតើបទឧក្រិដ្ឋដែលបង្កឡើងដោយ យឹម ទិត្យ ស្ថិតក្រោមយុត្តាធិការរបស់តុលាការខ្មែរក្រហម និងបន្ទាប់មកត្រូវបញ្ជូនខ្លួនរបស់គាត់ទៅជំនុំជម្រះ ឬយ៉ាងណា ប្រសិនបើសំណុំរឿង០០៤នេះនឹងបន្ត។ លើសពីនេះ សហព្រះ-រាជអាជ្ញាអន្តរជាតិមិនជឿថា បទចោទប្រកាន់ទៅលើ យឹម ទិត្យ នឹងធ្វើឲ្យមានការប៉ះពាល់ដល់ការផ្សះផ្សាជាតិ ស្ថិរភាព សន្តិភាព ឬសន្តិសុខក្នុងប្រទេសកម្ពុជានោះទេ។ បន្ទាប់ពីការប្រមូលភ័ស្តុតាងសម្រាប់សំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅឌុច និងសំណុំរឿង០០២/១ ប្រឆាំងជាមួយ នួន ជា និង ខៀវ សំផន មិនមានផលអវិជ្ជមានណាមួយបានកើតឡើង និងប៉ះពាល់លើការផ្សះផ្សាជាតិ ស្ថិរភាព សន្តិភាព ឬសន្តិសុខក្នុងប្រទេសកម្ពុជាឡើយ។ ផ្ទុយទៅវិញ ការនាំយកថ្នាក់ដឹកនាំកំពូល ក៏ដូចជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម នឹងជួយដល់ប្រទេសកម្ពុជា ក្នុងដំណើរការនៃការស្វែងរកយុត្តិធម៌ និងការផ្សះផ្សា។

*អ៊ុន សុដាវី និង អាលីសុន វ៉ែលខេស*

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណៈជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង មី បូរមី តាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthborey.m@dccam.org។





















# ទំនាក់ទំនងប្រចាំថ្ងៃរវាងប្រជាជនកម្ពុជា និងប្រជាជនវៀតណាម

ដោយសារតែបញ្ហាទឹកដី និងភាពខុសគ្នានៃមនោគមវិជ្ជា ជម្លោះរវាងប្រទេសកម្ពុជា និងវៀតណាមបានផ្ទុះឡើងជារឿយៗនៅក្នុងអំឡុងពេល៥០ឆ្នាំកន្លងមកនេះ ក្នុងរូបភាពជាសង្គ្រាម ការនិរទេស ឃាតកម្ម និងកុប្បកម្មៗ ប្រទេសកម្ពុជា និងប្រទេសវៀតណាមមានព្រំប្រទល់ជាប់គ្នាប្រវែងប្រមាណជា១,០០០គីឡូម៉ែតៗ ប្រវែងព្រំប្រទល់នេះមានការផ្លាស់ប្តូរយ៉ាងខ្លាំងនៅក្នុងអតីតកាល ហើយក៏នៅតែបន្តផ្លាស់ប្តូរក្នុងកម្រិតមួយនៅបច្ចុប្បន្នៗ ការវាតយកទឹកដីកម្ពុជារបស់ប្រទេសវៀតណាមដែលគួរឲ្យកត់សម្គាល់មួយនោះគឺ តំបន់ដីសណ្តរទន្លេមេគង្គ ឬតំបន់កម្ពុជាក្រោមៗ តំបន់នេះគឺជាកន្លែងដែលប្រជាជនខ្មែរកម្ពុជាក្រោមរស់នៅតាំងពីយូរលង់ណាស់មកហើយ ដែលជាប់នៅចំណុចកណ្តាលនៃជម្លោះ ហើយជាលទ្ធផល ទទួលរងនូវការគាបសង្កត់សិទ្ធិសេរីភាពផ្នែកជំនឿសាសនា និងការបញ្ចេញមតិៗ ភាពតានតឹងអំពីជម្លោះប្រវត្តិសាស្ត្រនេះកាន់តែមានភាពធ្ងន់ធ្ងរឡើងនៅឆ្នាំ២០១៨ នាពេលដែលមន្ត្រីវៀតណាមម្នាក់បានមានមតិថា «ទឹកដីកម្ពុជាក្រោម គឺជាទឹកដីរបស់វៀតណាមតាំងពីយូរលង់ណាស់មកហើយ»ៗ ប្រជាជនកម្ពុជាបានបញ្ចេញប្រតិកម្មប្រកបដោយហិង្សា តាមរយៈការធ្វើឃាតកម្មដោយដុតទង់ជាតិវៀតណាម ព្រមទាំងវាយបុរសជនជាតិវៀតណាមពីរនាក់រហូតដល់ស្លាប់ៗ អ្នកនយោបាយខ្មែរមួយចំនួនបានប្រើប្រាស់ភាពតានតឹងនេះ ដោយផ្សព្វផ្សាយពីការលើកកម្ពស់ការប្រឆាំងនឹងប្រទេសវៀតណាម ដើម្បីទទួលបានការគាំទ្រពីប្រជាជនៗ ឧទាហរណ៍ អតីតគណបក្សប្រឆាំង គណបក្ស


ឡឹ វ៉ាន់មិញ នៅផ្ទះក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

សង្គ្រោះជាតិ ដែលត្រូវបានរំលាយនៅឆ្នាំ២០១៨។

បើទោះបីទំនាក់ទំនងផ្នែកនយោបាយរបស់ប្រទេសទាំងពីរមានភាពតានតឹងយ៉ាងណាក៏ដោយ ក៏ទំនាក់ទំនងប្រចាំថ្ងៃរវាងប្រជាជនកម្ពុជា និងប្រជាជនវៀតណាមមិនពោរពេញដោយការរើសអើង និងស្អប់ខ្ពើមនោះឡើយ។ ប្រជាជនវៀតណាមជាច្រើន បានរស់ក្នុងភូមិរបស់ប្រជាជនកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំដោយគ្មានភាពរកាំរកូស។ អ្នកទាំងនោះរស់នៅជាមួយគ្នាយ៉ាងចុះសម្រុង ដោយមិនខ្វាយខ្វល់អំពីជម្លោះប្រវត្តិសាស្ត្ររវាងប្រទេសទាំងពីរ។ ឧទាហរណ៍ ជនជាតិវៀតណាមអាយុ៥៨ឆ្នាំម្នាក់ ឈ្មោះ ឡឺ វ៉ាន់មិញ ដែលជាអតីតទាហានវៀតណាម។

បច្ចុប្បន្ន ឡឺ វ៉ាន់មិញ រស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ជាមួយនឹងភរិយាជនជាតិខ្មែរនិងកូនៗ។ ឡឺ វ៉ាន់មិញ និងភរិយាមានកូនចំនួន៦នាក់ ស្លាប់ម្នាក់ ហើយបីនាក់ទៀតរស់នៅប្រទេសវៀតណាម។ ឡឺ វ៉ាន់មិញ បានមកដល់ប្រទេសកម្ពុជានៅឆ្នាំ១៩៨១ នៅពេលដែលគាត់មានអាយុ២១ឆ្នាំ។ តាំងពីពេលនោះមក ឡឺ វ៉ាន់មិញ បានរស់នៅក្នុងប្រទេសកម្ពុជារហូត លើកលែងតែពេលដែល ឡឺ វ៉ាន់មិញ និងក្រុមគ្រួសារភៀសខ្លួនទៅប្រទេសវៀតណាមអស់រយៈពេលពីរ ឬបីខែដោយភាពភ័យខ្លាចអំពីការផ្ទុះជម្លោះនៅកម្ពុជា។ ឡឺ វ៉ាន់មិញ ជាអតីតទាហានវៀតណាមផ្នែកវិស្វកម្ម ដែលមានតួនាទីដោះមីន សង់ស្ពាន និងសំណង់។ នៅពេលដែល ឡឺ វ៉ាន់មិញមកដល់ប្រទេសកម្ពុជាដំបូង គាត់មិនចេះភាសាខ្មែរទាល់តែសោះ ប៉ុន្តែគាត់បានរៀនភាសាខ្មែរដោយកត់ត្រាពាក្យខ្មែរដែលគាត់មិនចេះ១០ពាក្យក្នុងមួយថ្ងៃ។ មិនយូរប៉ុន្មានគាត់ក៏ចាប់យកភាសានេះបាន។ បើទោះបីជា ឡឺ វ៉ាន់មិញ មិនអាចទំនាក់ទំនងជាភាសាខ្មែរក៏ដោយ ក៏ ឡឺ វ៉ាន់មិញ បានរៀបការជាមួយភរិយាជនជាតិខ្មែរ ពីរឆ្នាំក្រោយមកដល់ប្រទេសកម្ពុជា ដោយគ្មានការអនុញ្ញាតពីមេបញ្ជាការយោធារបស់គាត់។

ឡឺ វ៉ាន់មិញ បានចំណាយពេលស្ទើរពាក់កណ្ដាលជីវិតរបស់ខ្លួនក្នុងប្រទេសកម្ពុជា។ ឡឺ វ៉ាន់មិញ បាននិយាយថា



ឡឺ វ៉ាន់មិញ កំពុងផ្តល់បទសម្ភាសន៍នៅផ្ទះក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ខ្លួនមិនដែលទទួលការរើសអើងពីអ្នកជិតខាងដែលជាជនជាតិខ្មែរឡើយ។ ឡឹ វ៉ាន់ម៉ិញ បាននិយាយទៀតថា ខ្លួនជឿជាក់ថា ប្រសិនបើបុគ្គលម្នាក់ជាមនុស្សល្អ នោះអ្នកជុំវិញប្រាកដជាយកអាសាបុគ្គលនោះជាមិនខាន។ ហេតុដូច្នេះហើយទើប ឡឹ វ៉ាន់ម៉ិញ អាចចុះសម្រុងជាមួយអ្នកជិតខាង។

សាច់រឿងរបស់ ឡឹ វ៉ាន់ម៉ិញ ជាឧទាហរណ៍ដ៏ល្អពីព្រោះ ឡឹ វ៉ាន់ម៉ិញ មានទីលំនៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ដែលជាក្រុមប្រឆាំង និងរើសអើងជនជាតិវៀតណាមជាប្រវត្តិសាស្ត្រ។ នៅអំឡុងរបបខ្មែរក្រហម ប្រទេសកម្ពុជាបានធ្វើសង្គ្រាមជា-មួយប្រទេសវៀតណាម។ អង្គការ (**ដែលសំដៅទៅលើបក្សកុម្មុយនីស្តកម្ពុជា**) ថែមទាំងបានចោទប្រកាន់ប្រជាជនកម្ពុជាមួយចំនួនថា មាន«ក្បាលយួនខ្លួនខ្មែរ» និងប្រើប្រាស់ការចោទប្រកាន់នេះជាលេសដើម្បីធ្វើទារុណកម្ម និងសម្លាប់អ្នកទាំងនោះ។ ខ្មែរក្រហមតែងតែធ្វើការស៊ើបអង្កេតស្វែងរកគិញសម្លាត់យួន ហើយកំណត់គោលដៅលើជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា។ សង្គ្រាមនេះបាននាំឲ្យរបបខ្មែរក្រហមដួលរលំ ហើយខ្មែរក្រហមដែលនៅសេសសល់បានភៀសខ្លួនទៅអន្លង់វែង។ ជាលទ្ធផល វៀតណាមបានតាំងមូលដ្ឋានទ័ពរបស់ខ្លួននៅកម្ពុជាពីឆ្នាំ១៩៧៩ ដល់ ១៩៨៩។ ទង្វើនេះបានបង្កើតភាពរកាំរកូសកាន់តែខ្លាំងរវាងប្រទេសទាំងពីរ ដោយប្រជាជនខ្មែរជាច្រើនយល់ថាទង្វើនេះជាការកាន់កាប់ជាជាងការរំដោះ។

បើទោះបីជា ឡឹ វ៉ាន់ម៉ិញ គឺជាជនជាតិវៀតណាមម្នាក់ ហើយអ្នកជិតខាងរបស់គាត់ភាគច្រើនជាអតីតកម្មាភិបាលខ្មែរក្រហមយ៉ាងណាក៏ដោយ អ្នកទាំងអស់រស់នៅចុះសម្រុងនឹងគ្នាដោយគ្មានភាពរកាំរកូស។ ឧទាហរណ៍ នៅពេលដែលក្រុមការងារទៅដល់ផ្ទះរបស់ ឡឹ វ៉ាន់ម៉ិញ ដើម្បីធ្វើការសម្ភាសន៍ ឡឹ វ៉ាន់ម៉ិញ និងក្រុមគ្រួសារបានស្វាគមន៍ក្រុមការងារទាំងអស់ដោយរីករាយ។ ផ្ទះរបស់ ឡឹ វ៉ាន់ម៉ិញ ពោរពេញដោយភ្ញៀវជនជាតិខ្មែរ ដែលអ្នកទាំងអស់នោះកំពុងជួយជញ្ជូនគ្រឿងសង្ហារិមដែល ឡឹ វ៉ាន់ម៉ិញ បានធ្វើដាក់ក្នុងរថយន្តដឹកជញ្ជូន។ អ្នកទាំងអស់មានភាពស្និទ្ធស្នាលនឹងគ្នាយ៉ាងខ្លាំង នៅពេលជួយគ្នាលើកគ្រឿងសង្ហារិមដែលមានទម្ងន់ធ្ងន់ៗដាក់ក្នុងរថយន្ត។

សាច់រឿងរបស់ ឡឹ វ៉ាន់ម៉ិញ ប្រហែលជាឧទាហរណ៍ពិសេសមួយ ហើយគាត់ប្រហែលជាចុះសម្រុងជាមួយអ្នកដទៃដោយសារតែគាត់ជាមនុស្សល្អ។ ប៉ុន្តែតាមរយៈសាច់រឿងរបស់គាត់ យើងអាចសន្និដ្ឋានបានថា នយោបាយរបស់ប្រទេសទាំងពីរ មិនផ្តល់ផលប៉ះពាល់ដល់ទំនាក់ទំនងរបស់ប្រជាជនកម្ពុជា និងវៀតណាមឡើយ។ ទោះបីជាការសន្និដ្ឋាននេះធ្វើឡើង ដោយយោងតាមសាច់រឿងរបស់អតីតទាហានវៀតណាមតែម្នាក់យ៉ាងណាក៏ដោយ សម្តីរបស់ក្រុមការងារម្នាក់ ដែលកំពុងប្រចាំការនៅស្រុកអន្លង់វែងបានពង្រឹងការសន្និដ្ឋាននេះ។ គាត់បាននិយាយថា«ហាងលក់ទឹកក្រឡុកដែលល្បីជាងគេក្នុងស្រុក មានម្ចាស់ជាជនជាតិវៀតណាម កន្លែងផ្សេងទៀតមិនសូវមានមនុស្សចូលឡើយ»។ នេះបញ្ជាក់ថាភាពរកាំរកូសរវាងប្រទេសទាំងពីរមិនជះឥទ្ធិពលដល់ទំនាក់ទំនងរវាងប្រជាជនធម្មតាឡើយ។ ផ្ទុយទៅវិញ បញ្ហាដែលគួរឲ្យព្រួយបារម្ភសម្រាប់ប្រជាជនអន្លង់វែង ជាពិសេសជាងធ្វើគ្រឿងសង្ហារិមដូច ឡឹ វ៉ាន់ម៉ិញ គឺជាការកាប់ព្រៃឈើនៅតាមបណ្តោយព្រំដែនកម្ពុជាថៃ ក៏ដូចជាទូទាំងប្រទេសកម្ពុជា។ បញ្ហានេះផ្តល់ផលប៉ះពាល់ប្រជាជនទាំងអស់ មិនថាសញ្ជាតិណាមួយឡើយ។ ការខ្វះខាតឈើមានផលប៉ះពាល់យ៉ាងខ្លាំងសម្រាប់ការធ្វើជំនួញរបស់អ្នកធ្វើគ្រឿងសង្ហារិម ហើយមិនថាសម្រាប់អ្នកធ្វើគ្រឿងសង្ហារិម កសិករ ឬម្ចាស់ហាងទឹកក្រឡុក ការកាប់ឈើខុសច្បាប់ និងអំពើហិង្សាដោយប្រើគ្រឿងញៀន ឬជម្លោះព្រំដែន តែងតែប៉ះពាល់ដល់តម្លៃអចលនទ្រព្យ វិស័យទេសចរណ៍។ល។ ជាចុងក្រោយមនុស្សគ្រប់រូបគួរគោរពតាមជំនឿរបស់ ឡឹ វ៉ាន់ម៉ិញ ហើយវាយតម្លៃមនុស្សតាមរយៈចរិកលក្ខណៈរបស់បុគ្គល ជាជាងតាមរយៈពូជសាសន៍ សាសនា ឬសញ្ជាតិ។ **អាលីសុន វែលខេស**

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

(តពីលេខមុន)

កែវ ដានី មានអាយុ២២ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុកព្រៃវែង ខេត្តព្រៃវែង ជាកូនរបស់ពូ កែវ អ៊ុក និងមីង សំ ស៊ុ ចាប់ខ្លួនថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៦ និងមកដល់គុកទួលស្លែងនៅថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ កែវ ដានី នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦។ កែវ ដានី ជាប់ឃុំឃាំងនៅក្នុងគុកទួលស្លែងអស់រយៈ ៤៧ថ្ងៃ។

កែវ ពៅ អាយុ២០ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅគងពិសី ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូ កែវ ញៀម និងមីង ឌី ណៃ ត្រូវបានខ្មែរក្រហមចាប់ខ្លួនខេត្តបាត់ដំបង ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក៧ បន្ទប់ធំ២៤។ ខ្មែរក្រហមសម្លាប់ កែវ ពៅ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៧៦។

កែវ មុត ជាកម្មករទំនប់ទឹក ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្ទឹងប្រាលក្នុងឆ្នាំ១៩៧៦ ហើយចូលមកដល់គុកទួលស្លែងនៅថ្ងៃទី៧ ខែកញ្ញា។ កែវ មុត ត្រូវខ្មែរក្រហមសម្លាប់នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៤៤ថ្ងៃ។

កែវ មឿន ហៅ កែវ នី ហៅ ដា មានអាយុ២៤ឆ្នាំគិតត្រឹមឆ្នាំ១៩៧៥ មានស្រុកកំណើត នៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ កែវ ប្រាក់ និងមីង ម៉ឹក យេន ធ្វើការនៅពាណិជ្ជកម្មរដ្ឋ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅផ្សារអូរឫស្សី ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧៥ និងយកទៅឃុំឃាំង នៅគុកទួលស្លែងក្នុងផ្ទះក៦ បន្ទប់ធំ៩។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់ឡើយ។

កែវ យន់ ហៅ ប្រការសេនា មានអាយុ២៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ អតីតជាអ្នកថតវិទ្យុ ទូរទស្សន៍ ស្រុកកំណើតនៅខេត្តតាកែវ ជាកូនរបស់ពូ កែវ សានិត និងមីង គន់ ហង់ ត្រូវបាន ជម្លៀសទៅនៅភូមិលេខ៣ ឃុំត្រើយស្លា ស្រុក២០ តំបន់២៥ ខេត្តកណ្ដាល និងចាប់ខ្លួនថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៦ នៅស្រុក២០(ស្រុកស្អាង)បញ្ជូនមកដាក់ឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ច បន្ទប់តូច ១៣។ ខ្មែរក្រហមសម្លាប់ កែវ យន់ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។

កែវយ៉ាន ហៅ វ៉ែន មានអាយុ២៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់លែង ខេត្តកំពង់ឆ្នាំង ជាកូនរបស់ពូ យ៉ប និងមីង ជិន ជាពេទ្យកងទ័ព មានប្រពន្ធឈ្មោះ ម៉ប់ រ៉ាន់ ហៅ រ៉ាត់ មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅផែកំពង់សោម ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ២ បន្ទប់តូច ១៤។ កែវ យ៉េន ត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ ឃុំឃាំងអស់រយៈពេល ១៣២ ថ្ងៃ។

កែវ រីម ហៅ កែវ រ៉ុម មានអាយុ២៣ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ កែវ រិន និងមីង ប្រេស វេង ជាយុទ្ធជនក្នុងកងពល៣១០ ត្រូវបាន ខ្មែរក្រហមចាប់ខ្លួននៅក្រុងភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៦ ហើយបញ្ជូនមកដល់គុកទួលស្លែងក្នុងផ្ទះ ច បន្ទប់ធំ៨ បន្ទប់តូច ១៣ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៦។ កែវរីម ត្រូវបាន ខ្មែរក្រហមសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ ក្រោយពីការចាប់ខ្លួនបាន ១៥៥ ថ្ងៃ។

កែវ រុន ជាកម្មកររោងចក្រភ្លើង ត្រូវបានខ្មែរក្រហមចាប់ខ្លួន

ក្នុងឆ្នាំ១៩៧៦។ កែវ រុន ហៅ សំ ស្តី មានអាយុ២៦ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅដីក្រែង ខេត្តសៀមរាប ជាកូន របស់ពូ ឡាយ ជន និងមីង សន សន ជាមេក្រុមនៅកំពង់ផែកំពង់សោម ត្រូវបានខ្មែរក្រហមចាប់ ខ្លួននៅកំពង់ផែកំពង់សោម ថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៧ និងបញ្ជូនមកឃុំឃាំងនៅគុកទួល ស្លែងក្នុងផ្ទះ ង បន្ទប់ធំ ៣ បន្ទប់តូច ១។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថាមានកាលបរិច្ឆេទ២ទាក់ទិននឹងការសម្លាប់ ទី១ កែវ រុន ត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ និងទី២គឺនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៨។

កែវ លឹម មានអាយុ៣៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅត្រាំកក់ ខេត្តតាកែវ ជាកូនរបស់ពូ កែវ ណុច និងមីង គុប ផាន់ ជាកម្មកររទេះភ្លើង មានប្រពន្ធឈ្មោះ ដួង នី អ្នកកំពង់ស្ពឺ មានកូនប្រុស២នាក់ និងស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៤ បន្ទប់តូច ៣។

កែវ វ៉ែន មាននាទីជាកងវរយនៃកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល ៥០២ក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារ នៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថាមានកាលបរិច្ឆេទ២ទាក់ទិននឹងការបញ្ជូនមកដល់គុកទួលស្លែង ទី១ ថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧៥ និងទី២គឺនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៥។ ខ្មែរក្រហមសម្លាប់ កែវ វ៉ែន នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៧៦។

កែវ វៃ ហៅ រ៉ាត មានអាយុ២៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបាភ្នំ ខេត្ត ព្រៃវែង ជាកូនរបស់ពូ កែវ វ៉ន និងមីង ខេង រិន ជាយុទ្ធជនកងពល១៧០ ត្រូវបានខ្មែរក្រហម ចាប់ខ្លួននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៧ នៅកងពល១៧០។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

កែវ សារី ហៅ មាស សំអុល មានអាយុ២៣ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅ បន្ទាយស្រី ខេត្តសៀមរាប ជាកូនរបស់ពូ ធិប កែវ និងមីង ជិន ប៉ោយ ជាមេក្រុមកម្មករលីសែងនៅរោងចក្រ ក១ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅរោង ចក្រ ក១ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ៤ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ កែវ សារី នៅថ្ងៃទី១៨ ខែមីនា ១៩៧៧ បន្ទាប់ពីឃុំឃាំងអស់រយៈពេល ១២៣ថ្ងៃ។

កែវ សារុន មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅសង្កែ (ខេត្តបាត់ដំបង) ជាកូនរបស់ពូ កែវ ឃឿន និងមីង ប៊ិច នឿន ជាកម្មកររទេះភ្លើង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៦ នៅរទេះភ្លើង ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃ បន្ទាប់នៅក្នុងផ្ទះ យ បន្ទប់ធំ ១ បន្ទប់តូច ៣។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

កែវ សុភី ជាប្រពន្ធរបស់ ទិត គង់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ នៅ ស.២១យ ក្រោយការចាប់ប្តី ទិត គង់ រួចហើយនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៥។ ពុំមានឯកសារបង្ហាញពីកាលបរិច្ឆេទនៃការសម្លាប់ទេ។

កែវ ហួរ មានអាយុ៣៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់ស្វាយ ខេត្តកំពង់ធំ ជាកូនរបស់អ៊ំ កែវ សៀង និងអ៊ំស្រី អ៊ុច ទូច មាននាទីជាភស្តុភារៈសេនាធំក្នុងកងពល៣១០ មានប្រពន្ធឈ្មោះ លាវ ប៉ាក់ ហៅ ទៀង ជាអនុលេខាកងធំ ពេទ្យកងពល៣១០ មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូន មកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ យ បន្ទប់ធំ ៥ បន្ទប់តូច ៤។ ខ្មែរក្រហមសម្លាប់ កែវ ហួរ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧។ ចំណែកឯប្រពន្ធឈ្មោះ លាង ប៉ាក់ ហៅ ទៀង

ត្រូវបានខ្មែរក្រហមចាប់ខ្លួនបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង នៅថ្ងៃទី៤ ខែមីនា និងស្លាប់នៅថ្ងៃទី៤ ខែមេសា ១៩៧៧។

កែវ អ៊ុន មានអាយុ៤៧ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់លែង ខេត្ត កំពង់ឆ្នាំង ជាប្រជាជន មានប្រពន្ធឈ្មោះ នង រីម ត្រូវបានខ្មែរក្រហមចាប់ខ្លួនភូមិថ្នល់ឈើទាល (ឃុំផ្លូវទូក ស្រុកកំពង់លែង) ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅក្នុងគុកទួលស្លែង ក្នុងបន្ទប់ធំ ៧ បន្ទប់តូច ១០។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា មានកាលបរិច្ឆេទ២ ទាក់ទិននឹងការបញ្ជូនមកដល់គុកទួលស្លែង ទី១ ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៤ និងទី២ គឺនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ កែវ អ៊ុន នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦។

កែវ អេត ជាកម្មករចាស់ ត្រូវបានខ្មែរក្រហមចាប់ខ្លួន នៅរទេះភ្លើង ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

កែវ សុដារ៉ា មានអាយុ៣១ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ កែវ ដូវ និងអ៊ំស្រី ញ៉ែម កូឡាប មានប្តីឈ្មោះ គុង បុណ្យសិរី អ្នកបាត់ដំបង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ ក១៥ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ កែវ សុដារ៉ា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។ ១០។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា កែវ សុដារ៉ា អាច មានឈ្មោះហៅថា ស៊ុយ តូយ៉ាណា ហើយ គុង បុណ្យសិរី អាចមានឈ្មោះហៅថា ម៉ុក សុវណ្ណ។ គុង បុណ្យសិរី ឬ ម៉ុក សុវណ្ណ ក៏ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃជាមួយគ្នា នឹងប្រពន្ធដែរ ក៏ប៉ុន្តែត្រូវបានខ្មែរក្រហមសម្លាប់ក្រោយប្រពន្ធគឺនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។

កែ យ៉េន ហៅ យាន មានអាយុ ២១ឆ្នាំ គិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូ កៅ ភោគ និងមីង មុខ លួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពាណិជ្ជកម្មរដ្ឋ ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការ សម្លាប់នៅឡើយ។

កោ យឿន ហៅ អាត មានអាយុ ២៤ឆ្នាំ គិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់ពូ កោ អឿន និងមីង ដួន ជាប្រធានវរៈសេនាតូចនារី កងពល៣១០ មានប្តីឈ្មោះ សំ វឿន ហៅ ផេង ប្រធានវរៈសេនាធំ១២ កងពល៣១០ មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមចាប់ បញ្ជូន សំ វឿន មកគុកទួលស្លែង នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៧៨ និងសម្លាប់នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៨។

កោ វិត ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

កោះ ស៊ូ ហៅ រិន មានអាយុ២៦ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅពញាឮ ខេត្តកណ្តាល ជាកូនរបស់ពូ កោះ អ៊ុន និងមីង យ៉ឹម ជាយុទ្ធជនក្នុងកងពល៣១០ មានប្រពន្ធឈ្មោះ ដាន់ រ៉ុង ហៅ ឡាប ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ៤ បន្ទប់តូច ៣។ ខ្មែរក្រហមសម្លាប់ កោះ ស៊ូ នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់ រយៈពេល ៥៥ ថ្ងៃ។

កោះ ឡាយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្ថានីយរថភ្លើង ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា មានកាលបរិច្ឆេទ៣ផ្សេងគ្នា ទាក់ទិននឹងការបញ្ជូនមកដល់គុក

ទួលស្លែង ទី១ ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៦ ទី២ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៦ និងទី៣ គឺថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ កោះ ឡាយ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។

កៅ កែវ មានអាយុ២២ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសង្កែ ខេត្តបាត់ដំបង ជាកូនរបស់ពូ អ៊ុំ យឿង និងមីង កៅ រ៉េន ជាយុទ្ធជនក្នុងក្រសួងការបរទេស ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅក្រសួងការបរទេស ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

កៅ គួន ហៅ មិន មានអាយុ៤២ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទូកមាស ខេត្តកំពត ជាកូនរបស់អ៊ំ កៅ និងអ៊ំស្រី ហ៊ិន ជាយុទ្ធជន មានប្រពន្ធឈ្មោះ ពុទ្ធ ដាន ហៅ ហ៊ួន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅបឹងត្របែក ថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ ៥ បន្ទប់តូច ៥។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

កៅ យី ជាមេក្រុមកង១១នៅស២១យ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅ ស២១យ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូន កៅ យី មកដល់គុកទួលស្លែងនៅថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៦១ថ្ងៃ។

កៅ សៀង ជាប្រពន្ធរបស់ឈ្មោះ ប៉ាត ប៊ុន ត្រូវបានខ្មែរក្រហមឃាត់ខ្លួនជាមួយប្តី នៅកន្លែងរទេះភ្លើង ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ កៅ សៀង នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ គឺមួយថ្ងៃក្រោយពីជាប់ឃុំឃាំងនៅគុកទួលស្លែង។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់ ប៉ាត ប៊ុន នៅឡើយ។

កៅ ហាយ មានអាយុ២៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ អតីតវិស្វករអណ្តូងរ៉ែ មានស្រុកកំណើត នៅគីរីវង្ស ខេត្តតាកែវ ជាកូនរបស់ពូ កៅ ឆាយ និងមីង ហ៊ី ចាត់ មានប្រពន្ធឈ្មោះ ឡឹក ស៊ីមា (អ្នកស្វាយរៀង) ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៦ នៅភូមិផ្សារ ឃុំ ព្រះនេត្រព្រះ ហើយបានបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ដាក់ ឃុំឃាំងក្នុងផ្ទះ ក បន្ទប់ធំ ១ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ កៅ ហាយ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦។

ក្រូច រឿន មានអាយុ៣៦ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅជីក្រែង ខេត្ត សៀមរាប ជាកូនរបស់អ៊ំ ក្រូច លុយ និងអ៊ំស្រី ជុំ ស៊ាម ធ្វើការនៅផែកំពង់សោម មានប្រពន្ធឈ្មោះ គឹម រ៉ែត មានកូនប្រុស៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ នៅផែកំពង់សោម។ ខ្មែរក្រហមសម្លាប់ ក្រូច រឿន នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងនៅគុកទួលស្លែងអស់រយៈពេល ១០៧ថ្ងៃ។

ក្លូត សោម ហៅ លួត អាយុ៤០ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅខេត្ត សៀមរាប ជាកូនរបស់អ៊ំ សព្វ ក្លូត និងអ៊ំស្រី គ្រឹម ប៉ិ មេក្រុមខាងឋាមពល មានប្រពន្ធឈ្មោះគាល មានកូនប្រុស២នាក់ និងកូនស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឋាមពល ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៧ និងសម្លាប់នៅថ្ងទី៣០ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៣៨ថ្ងៃ។ ចំណែក គាល ត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកគុកទួលស្លែងនៅថ្ងៃទី២ ខែឧសភា និងសម្លាប់នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៨ ក្រោយពីជាប់ឃុំឃាំងបាន ៤ថ្ងៃ។

ខាក់ សាខន ជាជំនួយការវរៈសេនាធំ កងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុង ឆ្នាំ១៩៧៦ នៅកងពល១៧០។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

(តទៅលេខក្រោយ)

វ៉ាន់ថាន់ ពៅដារ៉ា

# អ៊ឹង សុភ័ក្រ ៖ ក្រឡាបញ្ជី

*ណុប ស្រៀង ជាភរិយារបស់ អ៊ឹង សុភ័ក្រ បានរៀបរាប់ថា ៖*

*ប្ដីរបស់ខ្ញុំបានបួសជាព្រះសង្ឃ នៅពេលដែលគាត់មានអាយុ១៨ឆ្នាំ។ គាត់បានប្រឡងជាប់មធ្យមសិក្សាទុតិយភូមិភាសាបាលី។ ព្រះសង្ឃរាជ ជួន ណាត បានបង្គាប់ឲ្យគាត់បង្រៀន ព្រះសង្ឃឯទៀត ប៉ុន្តែគាត់បានប្រឈមនឹងបញ្ហាហិរញ្ញវត្ថុ ដូចនេះគាត់ក៏លាចាកសិក្ខាបទ ហើយបានប្រឡងចូលធ្វើការជាក្រឡាបញ្ជី។ គាត់បានទទួលពិន្ទុកម្រិតខ្ពស់ទីបី និងតំណែងមួយនៅទីក្រុងភ្នំពេញ។ យើងតែងតែព្យាយាមតស៊ូជាមួយគ្នា នៅក្នុងជីវិតអាពាហ៍ពិពាហ៍។ ដំបូងឡើយយើងមានម៉ូតូមួយគ្រឿង និងរស់នៅក្នុងផ្ទះជួលមួយ ក្រោយមកយើងមានផ្ទះផ្ទាល់ខ្លួនមួយនៅភ្នំពេញ និងទិញបានរថយន្តតូចមួយគ្រឿង។ ប្ដីរបស់ខ្ញុំចូលចិត្តធ្វើអំពើល្អ។ រាល់ពេលដែលខ្ញុំទៅផ្សារគាត់បានប្រាប់ខ្ញុំថាកុំឲ្យទិញឬចម្អិនសត្វដែលមានជីវិត។ គាត់បានធ្វើអំពើបាបពីរដងគត់ លើកទីមួយនៅពេលដែលគ្រួសារយើង មិនមានម្ហូបគ្រប់គ្រាន់ ហើយគាត់បានសម្រេចចិត្តទៅនេសាទ គាត់ចាប់បានត្រីមួយ។ គាត់មិនចង់សម្លាប់ត្រីនោះទេ ប៉ុន្តែត្រូវតែសម្លាប់ទើបយើងអាចបរិភោគបាន។ លើកទីពីរ គាត់បានទៅបន្ទប់ទឹក ជាចៃដន្យគាត់ជាន់កូនមាន់មួយក្បាល។ ប្ដីរបស់ខ្ញុំមិនធ្លាប់ផឹកគ្រឿងស្រវឹងទេ យប់មួយនោះគាត់បានចូលរួមពិធីជប់លៀងមួយ មិត្តភ័ក្តិគាត់បានបង្ខំឲ្យគាត់ផឹក។ នៅពេលត្រឡប់មកផ្ទះវិញគាត់និយាយថា «គាត់បានប្រព្រឹត្តល្មើសសីលធម៌ប្រត្តិបត្តិផ្ទាល់ខ្លួន»។ ប្ដីរបស់ខ្ញុំមិនដែលធ្លាប់ប្រើពាក្យអាក្រក់ជាមួយខ្ញុំ និងទន់ភ្លន់ចំពោះអ្នកគ្រប់ៗគ្នា។ នៅពេលដែលគាត់កំពុងធ្វើការជាក្រឡាបញ្ជីតុលាការនៅតាខ្មៅ គាត់មិនធ្លាប់ទារប្រាក់ពី*



អ៊ឹង សុភ័ក្រ អាយុ២០ឆ្នាំ នៅខេត្តតាកែវ



អ៊ឹង សុភ័ក្រ ឈរទីពីរាប់ពីខាងស្តាំ ឆ្នាំ១៩៦២ ខេត្តកណ្ដាល។ ព្រះសង្ឃរាជ ជួន ណាត គង់នៅកណ្ដាល ជាទីកន្លែងដែល អ៊ឹង សុភ័ក្រ ធ្លាប់បានរស់នៅ

ប្រជាជនក្រីក្រឡើយ។

ចៅហ្វាយរបស់គាត់ហ៊ួត ម៉ាន់ គឺជាអ្នកស្មោះត្រង់ចង់ឲ្យប្ដីរបស់ខ្ញុំក្លាយទៅជាអ្នកទទួលខុសត្រូវរកភ័ស្ដុតាង សម្រាប់ករណីក្ដីក្ដាំជាច្រើនមុនពេលឡើងតុលាការប៉ុន្តែប្ដីរបស់ខ្ញុំបានបដិសេធគាត់គិតថា គាត់មិនដែលអារកាត់ចំពោះភារកិច្ចបែបនោះទេ អ៊ីចឹងគាត់ បានធ្វើការងារ ជាអ្នកចុះបញ្ជីអត្រានុកូលដ្ឋានសំបុត្របញ្ជាក់កំណើតជំនួសវិញ។ គ្រួសារយើងមិនទាន់បានជម្លៀសចេញ រហូតដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ពីព្រោះផ្ទះយើងស្ថិតនៅជាយក្រុងភ្នំពេញ។ យើងចង់ទៅផ្ទះយើងនៅក្នុងក្រុងតាខ្មៅណាស់ ប៉ុន្តែត្រូវខ្មែរក្រហមបង្ខំឲ្យទៅខេត្តតាកែវជំនួសវិញ។ ខ្ញុំមានសាច់ញាតិរស់នៅខេត្តតាកែវ។ នៅពេលដែល ខ្មែរក្រហមបានសួរអំពីប្រវត្តិរូបរបស់យើង ប្ដីខ្ញុំបានប្រាប់ខ្ញុំថាកុំឲ្យនិយាយកុហក ព្រោះអីប្រជាជននៅក្នុងភូមិបានស្គាល់គ្រួសាររបស់យើងអស់ហើយ។ នៅពេលដែលខ្មែរក្រហមបានបញ្ជាប្ដីរបស់ខ្ញុំ និងមនុស្សបំណាស់ពីរនាក់ទៀតឲ្យទៅកាប់ឈើនៅក្នុងព្រៃស្បាតមួយអាទិត្យជាការពិតណាស់ ខ្ញុំមិនសង្ឃឹមថាគាត់ អាចវិលត្រឡប់មកវិញទេ។ ប៉ុន្តែប្រាំពីរថ្ងៃក្រោយមកគាត់បានត្រឡប់មកផ្ទះវិញ។

ជាលើកទីពីរ ប្ដីរបស់ខ្ញុំ បានត្រឡប់មកវិញដោយសុវត្ថិភាពទៀត។ គាត់មានគំនិតថា ត្រូវតែរត់ទៅប្រទេសវៀតណាម។ នៅពេលដែលខ្មែរក្រហមបានបញ្ជាប្ដីរបស់ខ្ញុំឲ្យទៅកាប់ឫស្សី គាត់បានប្រាប់ខ្ញុំថា ប្រសិនបើគាត់មិនត្រឡប់មកវិញ ក្នុងរយៈ



អ៊ីង សុភ័ក្រ នៅខាងស្ដាំបង្អស់ នៅក្នុងកម្មវិធីមង្គលការសាច់ញាតិ ឆ្នាំ១៩៧៣

ពេលយូរ មានន័យថាគាត់ប្រហែលចេញទៅប្រទេសវៀតណាមហើយ។ ប៉ុន្តែបីថ្ងៃក្រោយមក គាត់បានត្រឡប់មកវិញ និយាយថា ស្ថានការណ៍តឹងតែងខ្លាំងណាស់ គាត់មិនអាចរត់គេចខ្លួនបានទេ។

នៅចុងឆ្នាំ១៩៧៥ អង្គការបានបញ្ជូនយើងតាមរថភ្លើងទៅខេត្តបាត់ដំបង។ ប្តីរបស់ខ្ញុំមានចិត្តរីករាយណាស់ ព្រោះអីបាត់ដំបងនៅជិតព្រំដែនខ្មែរ-ថៃ។ យើងត្រូវបានបញ្ជូនទៅកាន់ភូមិមួយមានវាលស្រែពណ៌បៃតងខ្ចី។ នៅទីនោះ ប្តីរបស់ខ្ញុំបានជួបមិត្តភក្តិឈ្មោះ លាង ជាអតីតអធិការពន្ធដារ។ លាង បានបញ្ចុះបញ្ចូលគាត់ឲ្យរត់ចេញ ប៉ុន្តែវាជិតដល់ពេលដែលខ្ញុំត្រូវសម្រាលកូន។ ដូចនេះ ប្តីរបស់ខ្ញុំបាននិយាយថា គាត់នឹងពិចារណាឡើងវិញបន្ទាប់ពីខ្ញុំឆ្លងទន្លេរួច។ អ្នកដែលបានរត់ចេញមិនដែលត្រឡប់មកផ្ទះវិញទេ។ កូនស្រីរបស់ខ្ញុំឈ្មោះ រក្ខា ធ្វើការសាងសង់ទំនប់ធារាសាស្រ្ត ហើយមកលេងយើងនៅ ឆ្នាំ១៩៧៦។ ខ្ញុំព្យាយាមបញ្ចុះបញ្ចូលវាមិនឲ្យត្រឡប់ ទៅអង្គភាពវិញទេ ប៉ុន្តែ រក្ខា វាភ័យខ្លាច ប្រធានអង្គភាពរបស់វាដាក់ទោសប្រសិនជាវាមិននៅក្នុងអង្គភាព។ អ៊ីចឹង វាបានត្រឡប់ទៅអង្គភាពវិញ ប៉ុន្តែខ្ញុំ មិនបានឃើញវាម្តងទៀតឡើយ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ ខ្ញុំបានដឹងថា វាស្លាប់ដោយសារការអត់ឃ្លាន។

ក្នុងឆ្នាំ១៩៧៧ សាច់ញាតិឆ្ងាយរបស់ប្តីខ្ញុំម្នាក់ ឈ្មោះ ជួប បានព្យាយាមបញ្ចុះបញ្ចូលប្តីខ្ញុំឲ្យរត់ចេញ។ ជួប ធ្លាប់ធ្វើជាទាហាន បានបង្ហាញប្តីខ្ញុំនូវកាំភ្លើងវែងមួយដើមដែលគាត់បានលាក់ទុកជាយូរមកហើយ។ ប្តីរបស់ខ្ញុំនិយាយថា អត់ទេ គាត់ភ័យខ្លាច ប្រសិនបើគាត់រត់ចេញទៅ កូនៗ និងប្រពន្ធរបស់គាត់ប្រាកដជាអង្គការសម្លាប់ចោលមិនខាន។ ជួបបានភៀសខ្លួនជាមួយអ្នកភូមិ បីនាក់ទៀត។ តាំងពីពេល នោះមកមិនមាននរណាម្នាក់បានឃើញអ្នកទាំងបីឡើយ។

យប់មួយនោះ ប្តីរបស់ខ្ញុំបានយល់សប្តិឃើញរឿងចម្លែកមួយថា គាត់កំពុងថ្លែងសុន្ទរកថានៅក្នុងអង្គប្រជុំមួយ ពេលនោះ ស្រាប់តែប្រជាជនបានរត់ចូលមក រួចចាប់ចងដៃគាត់ក្រៀកទៅក្រោយ។ រំពេចនោះមានសូរទះដៃប្រាវ បន្ទាប់មកប្រទេសជាតិមានសន្តិភាព។ នៅពេលដែលគាត់ភ្ញាក់ឡើង គាត់បានប្រមូលប្លង់ផ្ទះ កូនសោរថយន្ត និងប័ណ្ណបើកបរយកទៅដុតចោល។

បីថ្ងៃក្រោយមក គណៈសហករណ៍បានហៅប្តីខ្ញុំឲ្យទៅចូលរួមប្រជុំមួយ។ ខ្ញុំបានឲ្យក្រម៉ាគាត់មួយ ប៉ុន្តែគាត់ប្រាប់ខ្ញុំថា ទុកវិញចុះ។ គាត់ថា«មិនចាំបាច់រកខ្ញុំទេ ឥឡូវនេះវាជាជីវិតចុងក្រោយរបស់ខ្ញុំ សូមជួយថែរក្សាកូនៗយើងទាំងអស់ឲ្យបានល្អផង»។ គាត់បានដើរចេញពីផ្ទះពីរបីជំហ៊ានរួចត្រឡប់មកវិញហុចដែកកេះឲ្យខ្ញុំគាត់និយាយថា គាត់មិនត្រូវការវាទៀតទេ។ ក្រោយមកខ្ញុំបានឮថា ប្តីរបស់ខ្ញុំត្រូវបានដាក់នៅក្នុងវត្តព្រះនេត្រព្រះ។ ខ្ញុំគិតថាក្មួយប្រុសរបស់ខ្ញុំបានរាយការណ៍អំពីគាត់ ប៉ុន្តែបន្ទាប់មកក្មួយរបស់ខ្ញុំក៏ត្រូវបានអង្គការចាប់យកទៅដែរ។

## ដំណឹងស្វែងរកពូ

*នាងខ្ញុំឈ្មោះ ឡូរ៉ា សាន។ ម្តាយរបស់នាងខ្ញុំឈ្មោះ សាន ង៉ែត មកពីខេត្តកំពង់ចាម។ គាត់មានបងស្រីម្នាក់ដែលបានជួបគ្នានៅមុនពេលបងស្រីរបស់គាត់បានស្លាប់ទៅ។ ប៉ុន្តែ ម្តាយនាងខ្ញុំនៅតែមានចម្ងល់អំពីប្អូនរបស់គាត់ម្នាក់ ដែលខ្ញុំមិនដឹងប្រកបតាមភាសាអង់គ្លេសយ៉ាងណានោះទេ គ្រាន់តែដឹងថាអាចជាឈ្មោះ សារុន ឬ សារឿន និងត្រកូល ង៉ែត។ ព័ត៌មានមួយទៀត ដែលអាចជួយបង្ហាញអត្តសញ្ញាណរបស់គាត់ គឺគាត់បានត្រឡប់មករៀននៅវិទ្យាល័យពោធិ៍វាល មួយរយៈ។ ម្តាយរបស់ខ្ញុំបាននិយាយថា មកដល់បច្ចុប្បន្ន ពូរបស់ខ្ញុំមានអាយុជាង៥០ឆ្នាំហើយ។ ប៉ុន្តែមានរឿងមួយ គឺម្តាយខ្ញុំបានប្រាប់ខ្ញុំថា ពូរបស់ខ្ញុំអាចត្រូវបាននាំទៅប្រទេសថៃ។*

*ដូច្នេះប្រសិនបើបងប្អូនណាបានស្គាល់ពូរបស់ខ្ញុំ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរសព្ទលេខ ០២៣ ២១១ ៨៧៥។*

*សូមអរគុណ!*

# ស្វែងរកបងប្អូនដែលបានបាត់ខ្លួន

ខ្ញុំឈ្មោះ រស់ ប៊ុណ្ណារិទ្ធិ បច្ចុប្បន្នរស់នៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំមានអាយុប្រហែល១៥ឆ្នាំ។ ខ្ញុំបានចាកចេញពីប្រទេសកម្ពុជា ជាមួយគ្រួសារមិត្តភក្តិរបស់ខ្ញុំម្នាក់ ដែលមានឪពុកជាអ្នកបម្រើការងារនៅស្ថានទូតអាមេរិកក្នុងទីក្រុងភ្នំពេញ។ ខ្ញុំជាកូនប្រុសច្បងក្នុងចំណោមបងប្អូនបង្កើត៥នាក់ដែលរស់នៅសង្កាត់ទួលគោក ស្ថិតនៅកាច់ជ្រុងមហាវិថីម៉ៅសេទុង និងផ្លូវរថភ្លើង មុនពេលទៅដល់រង្វង់មូលទួលគោក។ ឆ្លងពីផ្ទះរបស់ខ្ញុំមានសាកលវិទ្យាល័យ២ឬ៣កន្លែងទៀត។

ខ្ញុំនិងគ្រួសាររបស់មិត្តភក្តិរបស់ខ្ញុំ បានធ្វើដំណើរតាមយន្តហោះដែលចុះចតនៅព្រលានយន្តហោះអូរតាប៉ៅ (Utapao) ព្រំដែនប្រទេសថៃ ហើយគឺជាកន្លែងដែលយើងបានស្នាក់នៅក្នុងជំរំនៅទីនោះអស់រយៈពេល២ខែ មុនពេលទទួលបានការជួយឧបត្ថម្ភឲ្យចាកចេញទៅកាន់រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក។ យើងបានស្នាក់នៅ សាន អូនូហ្វ្រី រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិកអស់រយៈពេលប្រហែល១ខែ ហើយក៏បានផ្លាស់ទៅរស់នៅទីក្រុងវ៉ាស៊ីនតោន ឌីស៊ី វិញ។ ក្រោយមកទៀតយើងបានផ្លាស់ប្តូរទៅរស់នៅក្នុងរដ្ឋហ្វូរីដា ក្នុងទីក្រុងលែកម៉ារី ហ្វូរីដា (រដ្ឋហ្វូរីដាកណ្តាល) ចាប់តាំងពីឆ្នាំ១៩៩៦។

ខ្ញុំកើតនៅអង្គស្នួល ខេត្តកណ្តាល។ កាលពីនៅវ័យកុមារ ខ្ញុំបានរស់នៅ និងចូលរៀននៅសាលា ក្នុងស្រុកអង្គស្នួល រហូតដល់វ័យប្រហែល១១ទៅ១២ឆ្នាំ ទើបខ្ញុំផ្លាស់ទៅរស់នៅសង្កាត់ទួលគោក ក្នុងក្រុងភ្នំពេញ។ ខ្ញុំធ្លាប់បានជិះកង់ទៅលេងសាលារបស់ខ្ញុំ នៅស្រុកអង្គស្នួល។

ខ្ញុំមានឪពុកឈ្មោះ រស់ ហួន កើតនៅឆ្នាំ១៩៣៣ និងម្តាយឈ្មោះ អាញ់ សូហ៊ុន កើតឆ្នាំ ១៩៣៩ និងមានបងប្អូនបង្កើតដែលមានរាយឈ្មោះដូចខាងក្រោម៖

១) រស់ ប៊ុណ្ណាវ៉ា ភេទស្រី

២) រស់ ប៊ុណ្ណា ភេទស្រី

៣) រស់ ប៊ុណ្ណេ ភេទប្រុស

៤)រស់ ប៊ុណ្ណរដ្ឋាណា ភេទប្រុស

មុនពេលខ្មែរក្រហមចូលមកក្រុងភ្នំពេញ ខែមេសា ឆ្នាំ១៩៧៥ លោកយាយរបស់ខ្ញុំរស់នៅជាមួយបងប្អូនជីដូនមួយរបស់ខ្ញុំ ដែលបានរៀបការរួច ហើយមានកូនចំនួន២នាក់។ គាត់រស់នៅជិតខ្ញុំ។ ខ្ញុំមានមីង និងពូមួយចំនួនទៀត ដែលរស់នៅក្នុងទីក្រុងភ្នំពេញ។ បងប្អូនជីដូនមួយរបស់ខ្ញុំម្នាក់គឺជាតារាភាពយន្ត ហើយបងប្អូនជីដូនមួយរបស់ខ្ញុំពីរនាក់ផ្សេងទៀតគឺជាអ្នករាំរបាំអប្សរា។

អស់រយៈពេលជិត៤៣ឆ្នាំមកហើយ ដែលខ្ញុំមិនធ្លាប់បានទំនាក់ទំនងជាមួយសមាជិកគ្រួសាររបស់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែមានសង្ឃឹមថាខ្ញុំនឹងអាចជួបសាច់ញាតិរបស់ខ្ញុំម្តងទៀត។ ខ្ញុំកំពុងតែរៀបចំគម្រោងទៅប្រទេសកម្ពុជានៅដើមឆ្នាំ២០១៩នេះ។

ប្រសិនបើបងប្អូនណាបានស្គាល់ឈ្មោះដូចការរៀបរាប់របស់ខ្ញុំខាងលើ សូមមេត្តាទំនាក់ទំនងមកខ្ញុំបាទឈ្មោះ រស់ ប៊ុណ្ណារិទ្ធិ គ្រប់ពេលវេលា តាមរយៈអាសយដ្ឋាន ៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរសព្ទលេខ ០២៣ ២១១ ៨៧៥។ សូមអរគុណ!






LEE-
MT. VERNON



# ដំណឹងស្វែងរកកូនប្រុស ផាន់ សុធា បាត់ខ្លួននៅសម័យខ្មែរក្រហម



ខ្ញុំបាទឈ្មោះ ផាន់ សុខុម មានទីកន្លែងកំណើតនៅខាងជើងវត្តទួលទំពូង ក្នុងក្រុងភ្នំពេញ។ ពីមុនសម័យខ្មែរក្រហម ខ្ញុំមានតួនាទីជាទាហានជើងទឹក នៅជ្រោយចង្វារ។ នៅពេលដែលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥ ខ្មែរក្រហម បានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំ ទៅព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំបានរស់នៅខេត្តតាកែវបានមួយរយៈ ទើបខ្មែរក្រហមបានបញ្ជូនគ្រួសារខ្ញុំឲ្យទៅរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ សុផារី ពីមុនជាគ្រូបង្រៀននៅជ្រោយចង្វារ និងម្តាយឈ្មោះ ញឹម យ៉ា ព្រមទាំងកូនប្រុសរបស់ខ្ញុំម្នាក់ឈ្មោះ ផាន់ សុធា អាយុ៣ឆ្នាំ។ កូនខ្ញុំ ផាន់ សុធា កើតថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៣។

ក្រោយមក ប្រពន្ធរបស់ខ្ញុំបានកើតពិស និងបានស្លាប់នៅពេលខ្មែរក្រហមចាត់តាំងគាត់ ឲ្យទៅធ្វើការនៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ខណៈដែលខ្ញុំត្រូវបានខ្មែរក្រហមបំបែក ចេញពីគ្រួសារឲ្យទៅនេសាទត្រី នៅខាងស្ទឹងសង្កែ ខេត្តបាត់ដំបង។ ចំណែកកូនប្រុសរបស់ខ្ញុំ ដោយសារនៅក្មេងពេកមិនដឹងថាម្តាយស្លាប់ទេ គឺនៅយំឱបសាកសពម្តាយ។

នៅពេលវៀតណាមវាយចូលប្រទេសកម្ពុជាឆ្នាំ១៩៧៩ ខ្ញុំបានទទួលដំណឹងថា មានតាចាស់ម្នាក់បានយកកូនរបស់ខ្ញុំទៅចិញ្ចឹម។ នៅឆ្នាំ១៩៨០ ខ្ញុំបានភៀសខ្លួនទៅនៅជំរំខាវអ៊ីដាង ក្នុងទឹកដីថៃ។ ក្រោយមក ខ្ញុំបានចេញទៅរស់នៅសហរដ្ឋអាមេរិក ប៉ុន្តែមិនដែលបានទទួលដំណឹងពីកូនប្រុសរបស់ខ្ញុំឡើយ។

ដូច្នេះ ប្រសិនបើបងប្អូនណាបានដឹងដំណឹង ឬស្គាល់កូនប្រុសរបស់ខ្ញុំ ផាន់ សុធា សូមទាក់ទងមកខ្ញុំបាទឈ្មោះ ផាន់ សុខុម តាមរយៈអាសយដ្ឋាន៖ #1419 Red Field Rodd, Bel Air, MD (Marry Land) 2115, USA អ៊ីម៉ែល Sxphann@yahoo.com ទូរសព្ទនៅប្រទេសកម្ពុជាលេខ 015 971 144 ទូរសព្ទនៅកន្លែងធ្វើការងារលេខ 41 436 2592 និងទូរសព្ទដៃ 4434184314 ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរសព្ទលេខ ០២៣ ២១១ ៨៧៥។

សូមអរគុណ!




មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 21 358
◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 223, 2018 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 291 P.M/99, 2 August 1999.